**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale deDroit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# យន្តការនៃការការពារគំនូរឧស្សាហកម្មជាតិ និងអន្តរជាតិ

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៦

រៀបរៀងដោយ៖ | សាស្ត្រាចារ្យណែនាំ៖
និស្សិតឈ្មោះ៖ **ក. លូ គីមហួយ** | **ឃឹម គិរី**
**ក. លឹម សុភាវី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ក្រុម **L4B2** | ឆ្នាំសិក្សា ២០១២ - ២០១៦

ជំនាន់ទី **២១** | ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៦

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីររូបឈ្មោះ **លូ គីមហួយ** និង **លឹម សុតាវី** ជានិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

យើងខ្ញុំទាំងអស់គ្នាជាកូនៗ សូមលំឱនកាយថ្វាយបង្គំគោរព ដោយកិច្ចប្រណិបត្តន៍ និងសម្តែងនូវកិច្ចកតញ្ញូតាធម៌យ៉ាងជ្រាវជ្រៅជាទីបំផុត ជូនចំពោះ **លោកឪពុកអ្នកម្តាយ** ដែលបានបង្កើតរូបរាងកាយ និងចិញ្ចឹមបីបាច់ អប់រំទូន្មាន និងឲ្យកូនបានរៀនសូត្រមានចំណេះដឹង រហូតដល់ពេលបច្ចុប្បន្នដែលជាគុណូបការៈគុណយ៉ាងអនេកប្បការ ពុំអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងទ្វេ។

មួយវិញទៀត យើងខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណ ចំពោះ **លោកគ្រូ អ្នកគ្រូ លោក/លោកស្រីសាស្រ្តាចារ្យ** ទាំងអស់ ជាពិសេសលោកសាស្រ្តាចារ្យ **ឃឹម គីរី** នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលលោកតែងតែផ្តល់នូវចំណេះដឹង និងបទពិសោធន៍ល្អៗដល់យើងខ្ញុំ ក៏ដូចជាដល់និស្សិតដទៃទៀតផងដែរ ដែលនេះជាគុណូបការៈវិសេសវិសាល ដែលយើងខ្ញុំមិនអាចបំភ្លេច។ លើសពីនេះទៀត លោកបានខិតខំចំណាយអស់ពីកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃបំផុតរបស់លោក ក្នុងការជួយណែនាំ ជម្រុញ លើកទឹកចិត្ត និងដឹកនាំសារណា ព្រមទាំងជួយកែតម្រូវ និងបង្ហាញពីរបៀបរៀបចំសារណាមួយនេះ ឲ្យកាន់តែល្អប្រសើរឡើង។

ទៀតសោត ដែលញុំាងឲ្យការចងក្រងសៀវភៅសារណាមួយនេះ អាចដំណើរការបានកាន់តែងាយស្រួល ដោយសារមានការជួយសម្រួលពី **ឯកឧត្តម លុយ ចន្ណា** ដែលជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងការផ្តល់ការអនុញ្ញាតដល់យើងខ្ញុំទាំងពីរ អាចចុះស្រាវជ្រាវឯកសារនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងនោះដែរក៏មានលោក **ខ៉េត វិបុល** ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និងលោក **ឈុំ ពុទ្ធី** ប្រធានការិយាល័យចុះបញ្ជីគំនូរឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម លោកទាំងពីរបានខិតខំធ្វើការពន្យល់ណែនាំ និងជួយផ្តល់នូវឯកសារទាំងឡាយ ដែលពាក់ព័ន្ធនឹងប្រធានបទសារណារបស់យើងខ្ញុំ ថែមទាំងផ្តល់នូវអនុសាសន៍ល្អៗ និងវិធីសាស្រ្តងាយៗក្នុងការសិក្សាស្វែងយល់ លើផ្នែកគំនូរឧស្សាហកម្មនេះ។

បន្ថែមពីនេះទៅទៀត យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ **និស្សិតផ្នែកនីតិសាស្រ្ត ក្រុម L4B2 ឆ្នាំសិក្សា ២០១៥ - ២០១៦** ផងដែរ ដែលកន្លងមកតែងតែលើកទឹកចិត្ត ជម្រុញ គាំទ្រ ផ្តល់ជាយោបល់ល្អៗ និងពិភាក្សាផ្លាស់ប្តូរចំណេះដឹងគ្នាទៅវិញទៅមក ប្រកបដោយភាពស្និតស្នាលរួសរាយរាក់ទាក់ ដែលនេះជាអនុស្សាវរីយ៍ដ៏ល្អមួយក្នុងជីវិតយើងខ្ញុំ

# អារម្ភកថា

សួស្តីលោកគ្រូអ្នកគ្រូ និងមិត្តអ្នកអានទាំងឡាយ ក្រោមការគាំទ្រ ជម្រុញ លើកទឹកចិត្ត និងជួយបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ពីសំណាក់លោកឪពុកអ្នកម្តាយ មិត្តភ័ក្ត លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ ទាំងក្នុងក្រសួងគំនូរឧស្សាហកម្ម និងសិប្បកម្ម និងក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិសេសលោកគ្រូសាស្ត្រាចារ្យ **ឃឹម គិរី** ទីបំផុតសៀវភៅ សារណាមួយនេះក៏បានចាប់បដិសន្ធិឡើង។ សៀវភៅដែលមិត្តអ្នកអាន កំពុងតែកាន់នៅនឹងដៃពេលនេះ គឺជាសមិទ្ធិផលថ្មីស្រឡាងមួយ ដែលយើងខ្ញុំទាំងពីរ ជានិស្សិតផ្នែកនីតិសាស្ត្រ L4B2 បានខិតខំប្រឹងប្រែងរួបរួមគ្នាបង្កើតឡើង ក្រោមប្រធានបទ « **យន្តការនៃការការពារគំនូរឧស្សាហកម្មជាតិ និងអន្តរជាតិ** »។ ដូចអ្វីដែលមិត្តទាំងអស់គ្នាធ្លាប់បានដឹង និងបានលឺរួចមកហើយថា វិស័យកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជាយើង គឺនៅមានកម្រិតនៅឡើយ ពិសេសគឺពាក់ព័ន្ធនឹងគំនូរឧស្សាហកម្មនេះតែម្តង។ ជាក់ស្តែង ដូចជាបញ្ហានៃការចុះបញ្ជីគំនូរឧស្សាហកម្ម សិទ្ធិដែលម្ចាស់កម្មសិទ្ធិមានលើគំនូរឧស្សាហកម្ម ព្រមទាំងយន្តការនៃការដោះស្រាយបញ្ហា យន្តការនៃការការពារជាតិ និងអន្តរជាតិ នៅពេលដែលគំនូរមួយត្រូវបានគេលួចចម្លង ដោយពុំមាននូវការអនុញ្ញាតពីម្ចាស់សិទ្ធិជាដើម ដែលសុទ្ធសឹងជារឿងសំខាន់ គម្បីយើងត្រូវតែយល់ដឹងទាំងអស់គ្នា។ ម៉្យាងវិញទៀត មូលហេតុដែលយើងខ្ញុំទាំងពីរសម្រេចចិត្តរើសយកប្រធានបទមួយនេះ ដោយសារយើងខ្ញុំគិតថា ប្រធានបទនេះជាប្រធានបទមួយថ្មីស្រឡាងសម្រាប់មិត្តនិស្សិត និងសិស្សប្អូនជំនាន់ក្រោយៗ អាចសិក្សា និងស្រាវជ្រាវបន្ថែមពី កម្មសិទ្ធិបញ្ញា និងគំនូរឧស្សាហកម្មក្នុងប្រទេសយើង។ ទោះបីជាមានការខិតខំចងក្រងនូវសៀវភៅនេះល្អយ៉ាងណាក្តី ក៏យើងខ្ញុំនៅតែជឿជាក់ថា កំហុសនៅតែមាន ដោយសារតែស្នាដៃនេះនៅមានភាពក្មេងខ្ចីពេក។ ដូច្នេះហើយប្រសិនបើសៀវភៅនេះមានកំហុសឆ្គងយ៉ាងណា សូមលោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានទាំងអស់គ្នាមេត្តាខន្តីអភ័យទោសដល់យើងខ្ញុំផង។ យើងខ្ញុំទាំងពីរនឹងព្រមទទួលនូវរាល់ពាក្យពេជន៍ទាំងឡាយក្នុងន័យរិះគន់ដើម្បីស្ថាបនា ព្រោះយើងខ្ញុំតែងតែសង្ឃឹមជឿជាក់ថា សៀវភៅមួយក្បាលនេះ នឹងអាចក្លាយជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយៗទៀត ប្រៀបដូចជា ប្រទីបសម្រាប់បំភ្លឺដល់ការសិក្សា និងជាយានដើម្បីឆ្លងអោយដល់ត្រើយនៃបញ្ញាវន្ត័។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីររូប សូមលើកដៃបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងអស់នៅក្នុងលោក សូមគោរពជូនពរដល់ឪពុកអ្នកម្តាយ មិត្តភ័ក្ត លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ទាំងនៅក្នុងក្រសួងគំនូរឧស្សាហកម្ម និងសិប្បកម្ម និងនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ពិសេសលោកគ្រូសាស្ត្រាចារ្យ **ឃឹម គិរី** ក៏ដូចជាមិត្តអ្នកអានទាំងអស់អោយជួបតែពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................ ១

## ជំពូកទី១

## សញ្ញាណគតិយុត្តនៃគំនូរឧស្សាហកម្មជាតិ និងអន្តរជាតិ

ផ្នែកទី១ សញ្ញាណគតិយុត្តនៃគំនូរឧស្សាហកម្មជាតិ ........................................ ៤
កថាខណ្ឌទី១ ប្រវត្តិនៃគំនូរឧស្សាហកម្ម ........................................ ៤
ក. និយមន័យ ........................................ ៤
ខ. ប្រភេទនៃគំនូរឧស្សាហកម្ម ........................................ ៥
កថាខណ្ឌទី២ លក្ខខណ្ឌដើម្បីទទួលបានការការពារគំនូរឧស្សាហកម្ម ........................................ ៦
ក. គំនូរឧស្សាហកម្មដែលអាចការពារបាន ........................................ ៧
ខ. ការរក្សាការសម្ងាត់នៃគំនូរឧស្សាហកម្មមុននឹងចុះបញ្ជី ........................................ ៧
គ. លក្ខខណ្ឌគ្រឹះសម្រាប់ការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ........................................ ៧
គ.១ គំនូរឧស្សាហកម្មដែលអាចចុះបញ្ជីបាន ........................................ ៧
គ.២ គំនូរឧស្សាហកម្មដែលពុំអាចចុះបញ្ជីបាន ........................................ ៩
ឃ. លក្ខខណ្ឌទម្រង់សម្រាប់ការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ........................................ ៩
ឃ.១ អ្នកតំណាង ឬភ្នាក់ងារទទួលសិទ្ធិចុះបញ្ជីគំនូរឧស្សាហកម្ម ........................................ ១០
ឃ.២ សញ្ញាណនៃម្ចាស់គំនូរឧស្សាហកម្ម ........................................ ១០
ផ្នែកទី២ សញ្ញាណគតិយុត្តនៃគំនូរឧស្សាហកម្មជាអន្តរជាតិ ........................................ ១១
កថាខណ្ឌទី១ សញ្ញាណទូទៅនៃគំនូរឧស្សាហកម្ម ........................................ ១១
ក. ប្រវត្តិ និងគោលបំណង ........................................ ១១
ខ. ការក្លាយជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ........................................ ១៣
ខ.១ ការប្រកាសដោយរដ្ឋហត្ថលេខី ........................................ ១៦
ខ.២ ការហាមឃាត់ចំពោះការជ្រើសតាំងខ្លួនឯង ........................................ ១៦
ខ.៣ ការរួមបញ្ចូលនៃគំនូរ ........................................ ១៦
ខ.៤ ផលប៉ះពាល់ដែលកើតចេញពីការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ ........................................ ១៧

ខ.៥ សុវត្ថិភាពនៃការអនុញ្ញាត ........ ១៧
គ. ការហាមឃាត់ចំពោះការបញ្ជូនតាមរយៈការិយាល័យជាតិ ........ ១៧
ឃ. ការិយាល័យជាក់លាក់មួយសម្រាប់រដ្ឋច្រើន ........ ១៧
**កថាខណ្ឌទី២ ការប្រព្រឹត្តទៅនៃពាក្យសុំអន្តរជាតិ** ........ ១៨
ក. ការកំណត់នៃច្បាប់ដែលគ្រប់គ្រងពាក្យសុំអន្តរជាតិទាំងស្រុង ........ ១៨
ក.១ មាតិកាចាំបាច់នៃពាក្យសុំអន្តរជាតិ ........ ១៨
ក.២ ការតម្រូវពិសេសដែលទាក់ទងទៅនឹងអ្នកដាក់ពាក្យសុំ និងអ្នកបង្កើត ........ ១៩
ក.៣ បុគ្គលដែលអាចដាក់ពាក្យសុំ ........ ១៩
ក.៤ អានុភាពនៃការចុះបញ្ជីជាអន្តរជាតិ ........ ២០
ខ. រយៈពេលនៃការការពារ ........ ២០
គ. ការពន្យារការចុះផ្សាយសម្រាប់រយៈពេលមួយដែលតិចជាងរយៈពេលកំណត់ ........ ២១
ឃ. កម្រៃស្តង់ដានៃការបង្កើត ........ ២១

## ជំពូកទី២

## យន្តការនៃការការពារគំនូរឧស្សាហកម្មជាតិ

**ផ្នែកទី១ នីតិវិធីនៃការសុំចុះបញ្ជីគំនូរឧស្សាហកម្មជាតិ** ........ ២៣
**កថាខណ្ឌទី១ ការរៀបចំពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម** ........ ២៣
ក. សមត្ថកិច្ចទទួលបន្ទុកការដាក់ពាក្យស្នើសុំ ........ ២៣
ក.១ ការបង្កើត និងតួនាទីនៃនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ........ ២៣
ក.២ រចនាសម្ព័ន្ធនៃនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ........ ២៤
ខ. ការរៀបចំសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ........ ២៥
គ. ការចុះលេខ ការគូសសញ្ញា និងការត្រួតពិនិត្យលើទម្រង់ពាក្យសុំ ........ ២៩
ឃ. កាលបរិច្ឆេទអានុភាព ........ ៣១
**កថាខណ្ឌទី២ ដំណើរប្រព្រឹត្តទៅនៃគំនូរឧស្សាហកម្ម** ........ ៣២
ក. ដំណើរការចុះបញ្ជីគំនូរឧស្សាហកម្ម ........ ៣២
ក.១ នីតិវិធីរបស់មន្ត្រីកាន់កាប់បញ្ជី ........ ៣២

ក.២ ការចុះបញ្ជីសារជាថ្មី ........ ៣៣
ខ. ការចុះផ្សាយគំនូរឧស្សាហកម្មក្នុងព្រឹត្តិបត្រ ........ ៣៤
**ផ្នែកទី២ អត្ថប្រយោជន៍ និងសិទ្ធិដែលទទួលបានពីចុះបញ្ជីគំនូរឧស្សាហកម្ម ការរំលោភ សិទ្ធិនិងយន្តការដោះស្រាយវិវាទ** ........ ៣៤
**កថាខណ្ឌទី១ អត្ថប្រយោជន៍ និងសិទ្ធិដែលទទួលបានពីចុះបញ្ជីគំនូរឧស្សាហកម្ម** ........ ៣៤
ក. អត្ថប្រយោជន៍ និងសិទ្ធិដែលទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម....... ៣៤
ខ. ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាប័ណ្ណ ........ ៣៦
**កថាខណ្ឌទី២ ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ** ៤០
ក. ការរំលោភសិទ្ធិនៃគំនូរឧស្សាហកម្ម ........ ៤០
ក.១ និយមន័យនៃការរំលោភ ........ ៤០
ក.២ ទោសប្បញ្ញត្តិ ........ ៤០
ខ. យន្តការដោះស្រាយវិវាទ ........ ៤១
ខ.១ យន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ ........ ៤១
ខ.២ យន្តការដោះស្រាយវិវាទតាមផ្លូវតុលាការ ........ ៤១

**ជំពូកទី៣**

**យន្តការនៃការការពារគំនូរឧស្សាហកម្មជាអន្តរជាតិ**

**ក្រោមកិច្ចព្រមព្រៀងទីក្រុងឡាអេ** (០៦. ១១. ១៩២៥)

**ផ្នែកទី១ នីតិវិធីនៃការសុំចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិ** ........ ៤៤
**កថាខណ្ឌទី១ ខ្លឹមសារនៃសំណុំលិខិតស្នើសុំ ទម្រង់នៃពាក្យសុំ** ........ ៤៤
ក. ខ្លឹមសារនៃសំណុំលិខិតស្នើសុំ ........ ៤៤
ខ. ពាក្យសុំ ........ ៤៤
គ. រូបថត ឬគំនូសតាង ........ ៤៧
ឃ. កម្រៃកំណត់ ........ ៤៧
**កថាខណ្ឌទី២ ទម្រង់នៃពាក្យសុំ** ........ ៤៩
ក. ទម្រង់ជាផ្លូវការ ........ ៤៩
ខ. ទម្រង់មិនផ្លូវការ ........ ៥០

**ផ្នែកទី២ នីតិវិធីមុន និងបន្ទាប់ទទួលបានការការពារ** ..................................... ៥០

**កថាខណ្ឌទី១ នីតិវិធីមុនទទួលបានការការពារ** ..................................... ៥០

ក. ការបញ្ជូនពាក្យសុំ ..................................... ៥០

ក.១ ការបញ្ជូនដោយផ្ទាល់ទៅការិយាល័យអន្តរជាតិ ..................................... ៥១

ក.២ ការបញ្ជូនដោយមិនផ្ទាល់ទៅការិយាល័យអន្តរជាតិ ..................................... ៥១

ខ. ការទំនាក់ទំនងជាមួយនឹងការិយាល័យអន្តរជាតិ ..................................... ៥១

ខ.១ ទំនាក់ទំនងបញ្ជូនតាមរយៈប្រៃសនីយ៍ ..................................... ៥២

ខ.២ ទំនាក់ទំនងតាមរយៈទូរសារ ..................................... ៥២

ខ.៣ ទំនាក់ទំនងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ..................................... ៥៣

គ. ការតំណាងនៅមុខការិយាល័យអន្តរជាតិ ..................................... ៥៣

គ.១ នៅក្នុងពាក្យសុំអន្តរជាតិ ..................................... ៥៤

គ.២ នៅក្នុងសំណើនៃការផ្លាស់ប្តូរ ..................................... ៥៤

គ.៣ ការចាត់តាំងនៅក្នុងទំនាក់ទំនងផ្សេងទៀត ..................................... ៥៤

ឃ. ការត្រួតពិនិត្យជាផ្លូវការដោយការិយាល័យអន្តរជាតិ ..................................... ៥៦

ង. ការត្រួតពិនិត្យពាក្យសុំដោយការិយាល័យជាតិនៃរដ្ឋហត្ថលេខី ..................................... ៦៦

**កថាខណ្ឌទី២ នីតិវិធីបន្ទាប់ពីទទួលបានការការពារ** ..................................... ៥៨

ក. ការចុះផ្សាយ ..................................... ៥៨

ក.១ ការបកប្រែ ..................................... ៥៩

ក.២ ការពន្យារការចុះផ្សាយ ..................................... ៥៩

ខ. ការផ្លាស់ប្តូរនៅក្នុងការចុះឈ្មោះជាអន្តរជាតិ ..................................... ៦១

គ. រយៈពេលនៃការការពារ និងការចុះបញ្ជីសារឡើងវិញ ..................................... ៦២

ឃ. កាលបរិច្ឆេទនៃការតម្កល់ ..................................... ៦៣

ង. ការបោះបង់ការតម្កល់ ..................................... ៦៣

**សេចក្តីសន្និដ្ឋាន** ..................................... ៦៤

**ឯកសារពិគ្រោះ**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍លើគ្រប់វិស័យ ជាពិសេសវិស័យអប់រំ (ច្បាប់) ដែលជាវិស័យមានតួនាទីសំខាន់ ក្នុងការចូលរួមដោះស្រាយបញ្ហា ឬវិវាទដែលកើតមានឡើង។ ដូចនេះ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍផ្នែកច្បាប់ ស្ថាប័ននីតិប្បញ្ញត្តិបានបង្កើតនូវក្រមច្បាប់ជាច្រើន ដែលមានរដ្ឋសភាជាអ្នកអនុម័ត និងព្រឹទ្ធសភាជាអ្នកពិនិត្យ ដើម្បីចង្អុលបង្ហាញនូវអត្ថន័យនៃមាត្រា ផ្តល់ភាពងាយស្រួលដល់បុគ្គលដែលអនុវត្តច្បាប់ បានយល់ពីសិទ្ធិ កាតព្វកិច្ច ការទទួលខុសត្រូវ យន្តការដោះស្រាយការពារ និងរៀបចំគ្រប់គ្រងសណ្តាប់ធ្នាប់នៅក្នុងប្រទេសឲ្យកាន់តែមានភាពល្អប្រសើរឡើង។ ហើយដើម្បីឲ្យក្រម ច្បាប់ និងឯកសារគតិយុត្តទាំងឡាយមិនអធមនុញ្ញភាព ត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់គ្រឹះ និងច្បាប់កំពូលរបស់ប្រទេស។ ក្រៅពីនេះ ព្រះរាជាណាចក្រកម្ពុជាយើង បានចូលជាសមាជិករបស់អង្គការអន្តរជាតិជាច្រើន ដូចជា អង្គការសហប្រជាជាតិ អង្គការពាណិជ្ជកម្មពិភពលោក អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងអង្គការអន្តរជាតិផ្សេងៗទៀត។

ក្រោយពីព្រះរាជាណាចក្រកម្ពុជាយើង ចូលជាសមាជិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ មក យើងបានបង្កើតនូវច្បាប់ស្តីអំពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ និងចូលជាធរមាននៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣។ ច្បាប់នេះមានគោលដៅការពារការបង្កើតថ្មី ដែលបានទទួលប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះដែរ មានគោលបំណងសំខាន់ៗ ដូចជា ១.លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី ការស្រាវជ្រាវ និងការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា ២.ជំរុញ និងលើកទឹកចិត្តការធ្វើពាណិជ្ជកម្មក្នុង និងក្រៅប្រទេស និងការវិនិយោគផ្សេងៗ ៣.លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិទ្យាមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ៤.ផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងធ្វើការប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើ ក៏ដូចជាប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់។

តាមច្បាប់នេះដែរ ក៏ជាប់ពាក់ព័ន្ធទៅនឹងសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង និងច្បាប់អន្តរជាតិជាច្រើន ក្នុងនោះក៏មានអនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ចុះ

ថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣ ដែលបានធ្វើការកែប្រែចំនួន ៦ដង គឺ ១.នៅទីក្រុងប្រុយសែល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩០០ ២.នៅទីក្រុងវ៉ាស៊ីនតោង ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩១១ ៣.នៅទីក្រុងឡាអេ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩២៥ ៤.នៅទីក្រុងឡុង ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៣៤ ៥.នៅទីក្រុងលីស្បោន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥៨ និង៦.នៅទីក្រុងស្តុកហូម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ ហើយបានធ្វើវិសោធនកម្ម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៩។ មិនតែប៉ុណ្ណោះ បើយើងក្រឡេកមើលច្បាប់របស់ចក្រភពអង់គ្លេសឆ្នាំ១៧៨៧ ដែលជាច្បាប់ដំបូងបង្អស់ក្នុងការផ្តល់នូវកិច្ចការពារក្នុងអំឡុងពេលពីរខែ ដល់ម្ចាស់គំនូរឧស្សាហកម្មលើផ្នែកឧស្សាហកម្ម ដូចជាការរៀបចំ និងការបោះពុម្ពនៃអំបោះ ក្រណាត់សំពត់ ក្រណាត់ខ្មើយ ឬពូកជាដើម។ ហើយក្រោយពីមានការវិវត្តន៍ជាបន្តបន្ទាប់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៨០៦ ប្រទេសបារាំងក៏បានអនុម័តច្បាប់ស្តីពីការការពារគំនូរឧស្សាហកម្មផងដែរ។ ផ្ទុយមកវិញ ដោយសារគំនូរឧស្សាហកម្ម ជាវិស័យមួយថ្មីសម្រាប់ប្រទេសកម្ពុជាយើង ទើបតាំងពីការបោះឆ្នោតឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ន ប្រទេសកម្ពុជាយើងមានតែច្បាប់មួយ និងប្រកាសពីរតែប៉ុណ្ណោះ ដែលបានថែងទាក់ទងទៅនឹងគំនូរឧស្សាហកម្ម នោះគឺច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងប្រកាសដែលបានចេញដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដូចជា ប្រកាសស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម ដែលចូលជាធរមាននៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ និងប្រកាសស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ដែលចូលជាធរមាននៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១។ រីឯនីតិវិធីក្នុងការចុះបញ្ជីគំនូរឧស្សាហកម្មរបស់មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តតាមចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលបានអនុម័តក្រោមកិច្ចព្រមព្រៀងទីក្រុងឡូកាណូ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៦៨ និងធ្វើវិសោធនកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩ ហើយបានកែសម្រួលបោះពុម្ពជាបន្តបន្ទាប់ សម្រាប់បម្រើគោលបំណងពាក់ព័ន្ធនឹងការចុះបញ្ជី និងការបោះពុម្ពផ្សាយនូវគំនូរឧស្សាហកម្ម ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវរកឯកសារ ដែលបានរក្សាទុកតាមចំណាត់ថ្នាក់អន្តរជាតិ រួមមាន៖ ១.បញ្ជីនៃក្រុម និងអនុក្រុម ២.បញ្ជីទំនិញតាមអក្ខរក្រមដែលមានបញ្ចូលគំនូរឧស្សាហកម្ម ដោយមានការបង្ហាញអំពីក្រុម និងអនុក្រុម និង៣.កំណត់ពន្យល់។

ទោះបីជាមានការខិតខំបញ្ជ្រាបនូវចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា ជាពិសេសពាក់ព័ន្ធទៅនឹងគំនូរឧស្សាហកម្មនេះ ដល់ម្ចាស់កម្មសិទ្ធិនៃគំនូរឧស្សាហកម្មយ៉ាងណាក៏ដោយ ការរំលោភបំពានលើគំនូរឧស្សាហកម្ម និងបញ្ហាផ្សេងៗទៀតរមែងកើតមានឡើង។ ដូច្នេះ តើយន្តការនៃការការពារគំនូរឧស្សាហកម្មជាតិ និងអន្តរជាតិមានន័យយ៉ាងម្តេចដែរ? ហើយបានចង្អុលបង្ហាញ និងផ្តល់នូវ

ការយល់ដឹងអ្វីខ្លះដល់ម្ចាស់សិទ្ធិគំនូរឧស្សាហកម្ម? ដើម្បីអាចទទួលបាននូវភាពងាយស្រួល នៅពេលមានការរំលោភបំពានកើតឡើង។

ហេតុនេះហើយ ដើម្បីធ្វើការសិក្សាឲ្យកាន់តែលម្អិត និងស៊ីជម្រៅចំពោះប្រធានបទនេះ យើងខ្ញុំបានធ្វើការបែងចែកសារណានេះជា ៣ជំពូក៖ ដោយជំពូកទី១ បង្ហាញអំពី **សញ្ញាណគតិយុត្តនៃគំនូរឧស្សាហកម្មជាតិ និងអន្តរជាតិ** ជំពូកទី២ និយាយអំពី **យន្តការនៃការការពារគំនូរឧស្សាហកម្មជាតិ** និងជំពូកទី៣ និយាយអំពី **យន្តការនៃការការពារគំនូរឧស្សាហកម្មជាអន្តរជាតិក្រោមកិច្ច ព្រមព្រៀងទីក្រុងឡាអេ ចុះថ្ងៃទី០៦ ខែ១១ ឆ្នាំ១៩២៥**។

# ជំពូកទី១ សញ្ញាណគតិយុត្តនៃគំនូរឧស្សាហកម្មជាតិ និងអន្តរជាតិ

## ផ្នែកទី១ សញ្ញាណគតិយុត្តនៃគំនូរឧស្សាហកម្មជាតិ

### កថាខណ្ឌទី១ ប្រវត្តិនៃគំនូរឧស្សាហកម្ម

ការកកើតឡើងនូវគំនូរឧស្សាហកម្ម មានជាប់ពាក់ព័ន្ធទៅនឹងការកកើត និងការលូតលាស់ផ្នែកឧស្សាហូបនីយកម្ម និងវិធីសាស្ត្រសម្រាប់ការផលិតមួយចំនួន ដែលផ្ដល់ការការពារលើវិស័យវាយ្យនភណ្ឌ ដែលមានរយៈពេលតែ ២ខែ ប៉ុណ្ណោះ នៅក្នុងចក្រភពអង់គ្លេសក្រោមច្បាប់ឆ្នាំ១៧៨៧ ដែលជាច្បាប់ទីមួយក្នុងការផ្ដល់ការការពារផ្នែកឧស្សាហកម្ម មានដូចជា ក្រណាត់សំពត់ ក្រណាត់ខ្មៅ ឬពូកជាដើម។ ក្រោយមកវិស័យទាំងនេះ បានវិវត្តន៍ជាបន្តបន្ទាប់ រហូតបង្កើតឲ្យមានបទដ្ឋានគតិយុត្តសម្រាប់ការការពារគំនូរឧស្សាហកម្មនេះ ដែលមានប្រវិត្តនៃការការពារកើតឡើង ដោយការផ្ដល់ការការពារគំនូរឧស្សាហកម្មនៅក្នុងប្រទេសបារាំង និងបានអនុម័តច្បាប់ឡើងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៨០៦ ហើយតាមរយៈច្បាប់នេះ បានបង្កើតឲ្យមានក្រុមប្រឹក្សាពិសេសមួយ នៅក្នុងទីក្រុងលីយ៉ុង (Lyon) ដែលមានតួនាទីក្នុងការតម្កល់នូវគំនូរឧស្សាហកម្ម និងធ្វើការដោះស្រាយវិវាទរវាងផលិតករ និងផលិតករដែលទាក់ទងនឹងគំនូរឧស្សាហកម្មនេះ។[1] ចំណុចដែលគួរឲ្យយកចិត្តទុកដាក់គឺសកម្មភាពដែលទាក់ទងនឹងសិល្បៈនៃការឆ្លាក់រូប ឬសកម្មភាពរចនាចេញជារូបរាងផ្សេងៗ ដូចជា ចាន ឆ្នាំង ការដេរប៉ាក់ តម្បាញ ដែលរំលេចឲ្យចេញនូវការរចនាជារូបរាង ដែលបង្កប់ដោយការគូសដែលប្រើដោយទឹកថ្នាំ ទោះជាការធ្វើដោយដៃ ឬដោយប្រើប្រាស់គ្រឿងម៉ាស៊ីន ឬជាការរួមផ្សំនូវជាតិគីមី ដែលទាំងនេះអាចនឹងទទួលបានការការពារ ដោយសារតែវាគឺជាធាតុផ្សំមួយនៃផលិតផល ហើយសកម្មភាពទាំងនេះ បានក្លាយជាគំនិត ឬកម្មវត្ថុ ដើម្បីបង្កើតច្បាប់សម្រាប់ការការពារស្នាដៃទាំងអស់នោះ។

**ក. និយមន័យ**

តាមន័យទូទៅ គំនូរឧស្សាហកម្មគឺជាសកម្មភាព ដែលប្រកបទៅដោយការច្នៃប្រឌិតនៃការបង្កើត ឬជាសកម្មភាពនៃការតាក់តែង ឲ្យចេញនូវរូបរាងសម្រាប់វត្ថុធាតុ ដែលគេផលិតចេញមក ហើយបំពេញតម្រូវការសម្រាប់ការមើលឃើញវត្ថុនោះដោយភ្នែកទទេ ឬសំដៅទៅលើសិទ្ធិដែលគេបានផ្ដល់ឲ្យទៅតាមប្រព័ន្ធនៃការចុះបញ្ជី ដើម្បីការពារនូវប្រភពដើមដែលគេបានបង្កើតឡើង។

ការកំណត់និយមន័យនេះ អាចអាស្រ័យទៅតាមប្រទេសនីមួយៗផងដែរ។ ហេតុនេះហើយទើបអាចនាំឲ្យមានលក្ខណៈខុសគ្នាខ្លះ ក្នុងការកំណត់អំពីលក្ខខណ្ឌនៃការការពារ។ ចំពោះគំនូរ

[1] WIPO INTELLECTUAL PROPERTY HANDBOOK (WIPO HANDBOOK), Industrial Design, Page113។

ឧស្សាហកម្មតាមន័យរបស់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺជាការផ្គុំនៃបន្ទាត់ ឬពណ៌ ឬទម្រង់បីខ្នាត ឬសម្ភារៈណាមួយ ទោះបីជាមាន ឬពុំមានការផ្គុំរួមជាមួយបន្ទាត់ ឬពណ៌ក៏ដោយ ឲ្យតែការផ្គុំទម្រង់ ឬសម្ភារៈទាំងនោះ រំលេចឡើងជារូបរាងពិសេសរបស់ផលិតផល ឬសិប្បកម្ម ដែលអាចធ្វើជាគំនូរផលិតផលឧស្សាហកម្ម ឬសិប្បកម្ម និងអាចសំគាល់បានដោយចក្ខុ។[2]

តាមអត្ថន័យខាងលើ លក្ខណៈពិសេសរបស់គំនូរឧស្សាហកម្ម គឺសំដៅទៅលើរូបរាងខាងក្រៅរបស់វត្ថុ ឬផលិតផលដែលយើងអាចមើលឃើញនឹងភ្នែក ហើយមិនផ្ដោតទៅលើលក្ខណៈបច្ចេកទេសដូចប្រកាសនីយបត្រតក្កកម្មទេ។ នេះជាលក្ខណៈពិសេស ដែលធ្វើឲ្យគំនូរឧស្សាហកម្ម និងប្រកាសនីយបត្រតក្កកម្មមានលក្ខណៈខុសគ្នាដាច់ស្រឡះ។

គំនូរឧស្សាហកម្មស្ដែងឡើងតាមរូបភាពជាច្រើនយ៉ាង ដូចជា គ្រឿងសង្ហារិម ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះបាយ គ្រឿងអលង្ការ រថយន្ត គំនូរប្លង់ សំណង់ ស្ថាបត្យកម្ម វាយ្យនភណ្ឌ ជាអាទិ៍។

**ខ. ប្រភេទនៃគំនូរឧស្សាហកម្ម**

គំនូរឧស្សាហកម្មត្រូវបានបែងចែកជាបីទម្រង់ដូចខាងក្រោម៖

- លក្ខណៈជាទម្រង់បីខ្នាត (3D) នៃផលិតផល ដូចជារូបរាងនៃផលិតផល។
- លក្ខណៈជាទម្រង់ពីរខ្នាត (2D) នៃផលិតផល ដូចជាការតុបតែង គំរូ បន្ទាត់ ឬ ពណ៌។
- បង្គុំមួយ ឬច្រើននៃទម្រង់ពីរខ្នាត ឬបីខ្នាត។

រីឯប្រភេទនៃម្ចាស់គំនូរឧស្សាហកម្ម អាចជារូបវន្តបុគ្គលម្នាក់ ឬច្រើននាក់។ ប្រសិនបើគំនូរឧស្សាហកម្មមួយ បង្កើតឡើងដោយរូបវន្តបុគ្គលម្នាក់ រូបវន្តបុគ្គលនោះនឹងទទួលបានសិទ្ធិជាម្ចាស់ផ្ទាល់លើគំនូរឧស្សាហកម្មនោះ ប៉ុន្តែប្រសិនបើគំនូរឧស្សាហកម្មមួយ ដែលបង្កើតឡើងដោយបុគ្គលពីរ ឬច្រើននាក់វិញ សិទ្ធិជាម្ចាស់នៃគំនូរឧស្សាកម្មនោះ ត្រូវតែជាកម្មសិទ្ធិរួមគ្នានៃបុគ្គលទាំងអស់នោះ។[3] ដូចនេះការចុះបញ្ជី និងការអនុវត្តន៍សិទ្ធិ ត្រូវតែមានការយល់ព្រមពីម្ចាស់គំនូរឧស្សាហកម្មទាំងអស់ជាមុនសិន។

មួយវិញទៀត បើបុគ្គលពីរ ឬច្រើននាក់បានបង្កើតស្នាដៃដោយឡែកពីគ្នា នូវប្រភេទគំនូរឧស្សាហកម្មមួយដូចគ្នា បុគ្គលណាដែលបានដាក់សំណុំលិខិតស្នើសុំ ដែលមានកាលបរិច្ឆេទសុំចុះបញ្ជីមុនគេបង្អស់ ឬមានកាលបរិច្ឆេទអាទិភាពមុនគេបង្អស់ ហើយបានប្រកាសពីសុពលភាពនៃកាលបរិច្ឆេទនោះ ត្រូវទទួលបានសិទ្ធិជាម្ចាស់នៃគំនូរឧស្សាហកម្មនោះ ក្នុងករណីដែលសំណុំ

---

[2] មាត្រា៨៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[3] មាត្រា១១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

លិខិតស្នើសុំខាងលើ មិនត្រូវបានដកយកទៅវិញ ឬបោះបង់ចោល ឬក៏ត្រូវបដិសេធ។[4] ក្នុងករណីនេះ យើងអាចធ្វើការកំណត់បានយ៉ាងច្បាស់ថា កម្ពុជាបានជ្រើសរើសយកគោលការណ៍នៃការចុះបញ្ជីមុនគេ ក្នុងការកំណត់ពីម្ចាស់សិទ្ធិ ឬកាលបរិច្ឆេទអាទិភាពរបស់ម្ចាស់សិទ្ធិ។[5]

ចំពោះការផ្ទេរសិទ្ធិជាម្ចាស់នៃគំនូរឧស្សាហកម្មវិញ អាចប្រគល់ ឬផ្ទេរទៅឲ្យបុគ្គលដទៃដើម្បីស្នងជំនួសបាន។[6] ប្រសិនបើគំនូរឧស្សាហកម្មមួយ ដែលធ្វើឡើងនៅក្នុងប្រតិបត្តិទៅតាមកិច្ចសន្យាការងារ រាល់គំនូរឧស្សាហកម្មដែលបង្កើតឡើយដោយនិយោជិតក្រោមកិច្ចសន្យាការងារ សិទ្ធិជាម្ចាស់នៃគំនូរឧស្សាហកម្ម ត្រូវតែជាកម្មសិទ្ធិរបស់និយោជកដោយស្វ័យប្រវត្តិតែម្តង បើសិនបើនៅក្នុងកិច្ចសន្យានោះ ពុំមានប្រការអ្វីចែងផ្ទុយអំពីនោះ។[7]

## កថាខណ្ឌទី២ លក្ខខណ្ឌដើម្បីទទួលបានការការពារគំនូរឧស្សាហកម្ម

ជាទូទៅ គំនូរឧស្សាហកម្មដែលអាចទទួលបាននូវការការពារ គឺត្រូវតែថ្មី ឬភាពដើមរបស់វាមានរូបរាងច្បាស់លាស់ និងអាចអនុវត្តបានក្នុងឧស្សាហកម្ម ឬសិប្បកម្ម។

**ថ្មី៖** ត្រូវបានគេផ្តល់ការការពារ ចំពោះគំនូរឧស្សាហកម្មណាដែលថ្មី ឬមានប្រភពដើមរបស់វា មានន័យថា គំនូរឧស្សាហកម្មនោះ ពុំទាន់ត្រូវបានជនណាម្នាក់ បានបង្កើតវាពីមុនឡើយ ឬខុសពីគំនូរឧស្សាហកម្មមុនៗ ដែលត្រូវបានធ្វើឡើងនៅគ្រប់ទិសទីក្នុងពិភពលោក ដែលនេះជាការកំណត់ដែលមានលក្ខណៈដាច់ខាត។[8]

គំនូរឧស្សាហកម្មត្រូវចាត់ទុកថាថ្មី ប្រសិនបើគំនូរឧស្សាហកម្មនោះ មិនទាន់ត្រូវបានគេដឹងឮ ឬត្រូវបានគេបញ្ចេញឲ្យដឹងដល់សាធារណៈជន នៅកន្លែងណាមួយលើពិភពលោក មុនកាលបរិច្ឆេទសុំចុះបញ្ជី ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើ។[9]

**រូបរាងច្បាស់លាស់៖** ជាទូទៅគំនូរឧស្សាហកម្មដែលតម្រូវលើវត្ថុ ឬផលិតផល គឺដាច់ខាតត្រូវតែមានរូបរាងអាចធ្វើការវិនិច្ឆ័យដោយភ្នែកបាន។ ការតម្រូវនេះ គឺដើម្បីបញ្ជាក់ថា ការការពារចំពោះគំនូរឧស្សាហកម្មដោយផ្អែកទៅលើរូបរាង ឬទិដ្ឋភាពនៃវត្ថុនោះ មិនមែនជាមុខងាររបស់វាឡើយ។ មូលហេតុដែលនាំឲ្យមាននូវការកំណត់បែបនេះ ពីព្រោះថា វត្ថុធាតុដែលត្រូវគេយកមក

---

[4] មាត្រា១២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[5] ដើម្បីកំណត់អំពីម្ចាស់នៃស្នាដៃតក្កកម្ម ឬគំនូរឧស្សាហកម្ម គេអនុវត្តគោលការណ៍ពីរ គឺគោលការណ៍ចុះបញ្ជីមុន (First to file/ register) និងគោលការណ៍នៃការបង្កើតស្នាដៃមុន (first to invent)។

[6] មាត្រា១៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[7] មាត្រា១៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[8] មាត្រា៩១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[9] មាត្រា៩២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

ប្រើជាគំនូរឧស្សាហកម្ម មិនមែនជាវត្ថុធាតុដែលថ្មីនោះទេ ប៉ុន្តែវានឹងផលិតចេញនូវរូបរាងអ្វីមួយផ្សេងទៀត។ ឧទាហរណ៍ ក្រវ៉ាត់ពីស្តុង ឬ ទូឡឺរីស ជាអាទិ៍ ត្រូវបានផលិតដោយផលិតកររាប់ពាន់នាក់ ហើយដែលវត្ថុធាតុទាំងនោះ ត្រូវបានយកមកប្រើក្នុងមុខងារដូចៗគ្នា។

**អនុវត្តបានក្នុងឧស្សាហកម្ម ឬសិប្បកម្ម៖** មានន័យថា អាចយកទៅផលិតបាន ឬប្រើប្រាស់បានក្នុងប្រភេទណាមួយនៃឧស្សាហកម្មដូចជា ឧស្សាហកម្មរថយន្ត ម៉ូតូ ជាអាទិ៍។ ចំណែកឯវិស័យសិប្បកម្មវិញ ការកែច្នៃឲ្យចេញនូវរូបរាងផ្សេងៗ ដូចជា តុ ទូ កៅអី តម្បាញ ការឆ្លាក់រូប ជាដើម។

**ក. គំនូរឧស្សាហកម្មដែលអាចការពារបាន**

គ្រប់គំនូរឧស្សាហកម្មទាំងអស់ អាចនឹងទទួលបានការការពារ លុះត្រាតែគំនូរឧស្សាហកម្មនោះ មានរូបរាងច្បាស់លាស់ និងមិនមានគោលបំណងសម្រាប់បម្រើឲ្យតែទទួលបាននូវលទ្ធផលបច្ចេកទេស។[10] ហើយការការពារគំនូរឧស្សាហកម្មនេះ អាចការពារទៅបានតាមរយៈការចុះបញ្ជី។

**ខ. ការរក្សាការសម្ងាត់នៃគំនូរឧស្សាហកម្មមុននឹងចុះបញ្ជី**

ការរក្សានូវការសម្ងាត់ នៃគំនូរឧស្សាហកម្មមុនពេលចុះបញ្ជី គឺពិតជាមានសារៈសំខាន់ណាស់។ ដើម្បីការពារនូវគំនូរឧស្សាហកម្មមួយបាន លុះត្រាគំនូរឧស្សាហកម្មនោះថ្មី។ ដូចនេះ ប្រសិនបើអ្នកបានធ្វើការបង្ហាញ ឬប្រាប់ទៅកាន់អ្នកដទៃពីគំនូរឧស្សាហកម្មរបស់ខ្លួន គប្បីធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ដោយឲ្យជននោះរក្សាការសម្ងាត់នូវគំនូរឧស្សាហកម្មនោះ។ ព្រោះគំនូរឧស្សាហកម្មដែលបានបង្ហាញដល់សាធារណៈជន តាមរយៈការផ្សព្វផ្សាយជារូបភាព នៅក្នុងព្រឹត្តិបត្រណាមួយ ឬនៅក្នុងកាតាឡុករបស់ក្រុមហ៊ុនណាមួយ នោះមិនអាចត្រូវបានចាត់ទុកថាគំនូរឧស្សាហកម្មនោះថ្មីទេ ហើយក៏មិនអាចទទួលបានកិច្ចការពារដែរ លុះណាតែមានសេចក្តីអះអាងពីអាទិភាពនៃសំណុំលិខិតស្នើសុំដំបូង។

**គ. លក្ខខណ្ឌគ្រឹះសម្រាប់ការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម**

**គ.១ គំនូរឧស្សាហកម្មដែលអាចចុះបញ្ជីបាន**

គំនូរឧស្សាហកម្មដែលអាចចុះបញ្ជីបាន មានលក្ខខណ្ឌមួយចំនួន ហើយវាក៏អាស្រ័យទៅតាមច្បាប់នៃប្រទេសនីមួយៗបានកំណត់ ដូចជា៖

**- លក្ខខណ្ឌនៃភាពថ្មី (New/ Novelty)** [11]: គំនូរឧស្សាហកម្មថ្មីមានន័យថា គំនូរនោះមិនទាន់បានបញ្ចេញឲ្យសាធារណៈជន នៅគ្រប់ទីកន្លែងលើពិភពលោក ដឹងឮមុនកាលបរិច្ឆេទសុំចុះបញ្ជី ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ តាមរយៈការផ្សព្វផ្សាយដោយប្រើរូបភាព

[10] មាត្រា៩០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[11] មាត្រា៩១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

ដាក់ស្តែង ឬតាមរយៈការប្រើប្រាស់ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត។[12] ប៉ុន្តែមានករណីមួយចំនួនដែលមិនចាត់ទុកថា បានដឹងឮដល់សាធារណៈជនទេ ដូចជា ៖

- គំនូរឧស្សាហកម្មដែលបានដឹងឮដល់សាធារណៈជន ក្នុងអំឡុងពេលដប់ពីរខែ (១២ខែ) មុនពេលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ។
- ការធ្វើឲ្យលេចឮ ខ្ទរខ្ទាយពត៌មានអំពីគំនូរឧស្សាហកម្ម តាមរយៈអ្នកដាក់ពាក្យសុំ តាមរយៈអ្នកស្នងរបស់បុព្វជន ឬតាមរយៈការរំលោភរបស់ភាគីទី៣ ទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជន ដែលបណ្តាលឲ្យលេចឮ ខ្ទរខ្ទាយនូវពត៌មាននេះ។[13]

- **លក្ខខណ្ឌនៃលំនាំដើម ឬប្រភពដើម (Original):** គំនូរឧស្សាហកម្មដែលត្រូវបានចាត់ទុកថាមានលក្ខណៈដើម គឺសំដៅទៅលើគំនូរទាំងឡាយណា ដែលបានបង្កើតឡើងដោយឯករាជ្យដោយម្ចាស់គំនូរ ដោយមិនបានចម្លង ឬក៏យកគំរូតាមគំនូរដែលមានស្រាប់។

- **លក្ខខណ្ឌនៃលក្ខណៈដោយឡែក ឬលក្ខណៈឯកត្តជន (Individual Character)**[14] **:** ប្រទេសមួយចំនួនបានបន្ថែមនូវលក្ខខណ្ឌនេះ ដើម្បីឲ្យគំនូរឧស្សាហកម្មមួយ អាចធ្វើការចុះបញ្ជីទៅបាន។ ហើយគំនូរមួយត្រូវបានគេកំណត់ថា ជាគំនូរដែលមានលក្ខណៈដោយឡែក គឺជាគំនូរដែលម្ចាស់គំនូរបានធ្វើឲ្យសាធារណៈជន ឬអ្នកប្រើប្រាស់យល់ថា គំនូររបស់ខ្លួនមានលក្ខណៈខុសពីគំនូរដែលអ្នកដទៃបានគេច្នៃ ឬរចនាឡើង។ លក្ខណៈឯកត្តជននេះ គឺភាគច្រើនស្ថិតនៅក្នុងក្រសែភ្នែកនៃអ្នកមើល។ បុគ្គលទាំងឡាយអាចបង្ហាញថា គំនូរទាំងនោះមិនមែនជាគំនូរថ្មី ឬមិនមែនជាគំនូរដើម ប្រសិនបើវាពុំមានការខុសប្លែកអ្វី ពីគំនូរទាំងឡាយដែលគេបានស្គាល់រួចហើយ ឬពីបង្គុំទាំងឡាយនៃផ្នែកផ្សេងៗរបស់គំនូរ ដែលគេបានស្គាល់រួចហើយនោះ។

លក្ខខណ្ឌទាំងបីខាងលើនេះ ពុំមានលក្ខណៈដាច់ស្រឡះពីគ្នានោះទេ។ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា គំនូរឧស្សាហកម្មដែលអាចចុះបញ្ជីបាន ត្រូវបានកំណត់យ៉ាងច្បាស់នូវ**លក្ខខណ្ឌតែមួយគត់គឺថ្មី**។[15]

---

[12] មាត្រា៩២ (១) នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[13] មាត្រា៩២ (២) នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[14] ដកស្រង់ចេញពីសៀវភៅ IP PANORAMA page22។

[15] មាត្រា៩១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

**គ.២ គំនូរឧស្សាហកម្មដែលពុំអាចចុះបញ្ជីបាន**

គំនូរឧស្សាហកម្មដែលពុំអាចចុះបញ្ជីបាន ត្រូវផ្អែកទៅលើចំណុចដូចខាងក្រោមៈ

- គំនូរឧស្សាហកម្មដែលមិនបានបំពេញនូវលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌបីខាងលើនេះ។

- គំនូរឧស្សាហកម្មដែលចាត់ទុកថា មានតួនាទីបច្ចេកទេសនៃផលិតផល ដែលអាចនឹងត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញាដទៃទៀត ដូចជា តក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ ឬការសម្ងាត់ពាណិជ្ជកម្មជាដើម។[16]

- គំនូរឧស្សាហកម្មដែលប៉ះពាល់ដល់សញ្ញា ឬរូបភាពជាតិ ដូចជា ទង់ជាតិជាដើម។

- គំនូរឧស្សាហកម្មដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ សីលធម៌របស់សង្គម។[17]

ទាក់ទងនឹងការបដិសេធមិនចុះបញ្ជីណាមួយ ដែលឈរលើហេតុផលនេះ គឺទាញចេញពីការយល់ឃើញរបស់សាធារណៈជន។ ជាឧទាហរណ៍ គំនូរឧស្សាហកម្មទាំងឡាយ ដែលបង្ហាញនូវរូបភាពនៃការរើសអើង មិនអាចទទួលយកបានទេ។

**ឃ. លក្ខខណ្ឌទម្រង់សម្រាប់ការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម**

លក្ខខណ្ឌទម្រង់សម្រាប់ចុះបញ្ជីគំនូរឧស្សាហកម្ម គឺសំដៅការដាក់ពាក្យស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មជាមួយមន្ត្រីកាន់កាប់បញ្ជី ដោយបំពេញនូវសំណុំលិខិតស្នើសុំចុះបញ្ជីឲ្យបានត្រឹមត្រូវទៅតាមលក្ខខណ្ឌដែលច្បាប់កំណត់។ មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តតាមចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលបានអនុម័តក្រោមកិច្ចព្រមព្រៀងទីក្រុងឡូកាណូ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៦៨ ហើយបានកែសម្រួលបោះពុម្ពជាបន្តបន្ទាប់ សម្រាប់បម្រើគោលបំណងពាក់ព័ន្ធនឹងការចុះបញ្ជី និងការបោះពុម្ពផ្សាយគំនូរឧស្សាហកម្ម ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវរកឯកសារ ដែលបានរក្សាទុកតាមចំណាត់ថ្នាក់។[18] នីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវភ្ជាប់មកជាមួយដូចជា គំនូរបង្ហាញ រូបថត ឬ រូបតំណាង ដែលតំណាងឲ្យវត្ថុបង្កើតជាគំនូរឧស្សាហកម្មនោះ និងចង្អុលបង្ហាញពីប្រភេទនៃផលិតផល ដែលគំនូរឧស្សាហកម្មនោះត្រូវយកមកប្រើ។ ហើយក្នុងករណីដែលគំនូរឧស្សាហកម្មនោះ មានទម្រង់បីវិមាត្រ សំណុំលិខិតស្នើសុំនោះ ត្រូវភ្ជាប់ដោយរូបសំណាកវត្ថុ ដែលតាងរូបរាងពិតរបស់គំនូរឧស្សាហកម្មនោះផងដែរ។[19]ការដាក់ពាក្យស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មនេះ អាចធ្វើឡើងដោយម្ចាស់គំនូរឧស្សាហកម្មផ្ទាល់ ឬប្រសិនបើអ្នកដាក់ពាក្យ

[16] កម្ពុជាបច្ចុប្បន្នពុំទាន់មានច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្មនៅឡើយទេ។

[17] មាត្រា៩៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[18] ប្រការ៤ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីនៃការចុះបញ្ជីគំនូរឧស្សាហកម្ម។

[19] មាត្រា៩៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

សុំ មិនមែនជាម្ចាស់ស្នាដៃនៃគំនូរឧស្សាហកម្មនោះទេ ពាក្យសុំចុះបញ្ជីនោះ ត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ឬលិខិតប្រគល់សិទ្ធិអ្នកតំណាងស្របច្បាប់។[20]

**ឃ.១ អ្នកតំណាង ឬភ្នាក់ងារទទួលសិទ្ធិចុះបញ្ជីគំនូរឧស្សាហកម្ម**

តាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងប្រកាសលេខ ៧០៧ ស្តីពីនីតិវិធីនៃការចុះបញ្ជីគំនូរឧស្សាហកម្ម ពុំបានកំណត់ឲ្យច្បាស់លាស់អំពីលក្ខខណ្ឌ ដែលអាចក្លាយជាភ្នាក់ងារតំណាងឲ្យម្ចាស់គំនូរឧស្សាហកម្មនោះទេ ហើយបច្ចុប្បន្ននេះ យើងក៏ពុំទាន់ឃើញមានបទបញ្ញត្តិពិសេសណាមួយ ដែលចេញដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីអាចក្លាយជាភ្នាក់ងារតំណាងស្របច្បាប់ឲ្យម្ចាស់គំនូរឧស្សាហកម្មដែរ។ ដូចនេះនៅក្នុងករណីម្ចាស់គំនូរឧស្សាហកម្ម ពុំអាចទៅចុះបញ្ជីដោយខ្លួនឯងផ្ទាល់ នោះម្ចាស់គំនូរឧស្សាហកម្មត្រូវប្រគល់សិទ្ធិសម្រាប់ចុះបញ្ជី ទៅឲ្យនរណាម្នាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលសិទ្ធិធ្វើជាអ្នកតំណាង ឬភ្នាក់ងារស្របច្បាប់ក្នុងការចុះបញ្ជីគំនូរឧស្សាហកម្ម។ ហើយប្រសិនបើម្ចាស់គំនូរឧស្សាហកម្មជាជនជាតិខ្មែរ ឬម្ចាស់គំនូរឧស្សាហកម្មមានទីលំនៅអចិន្ត្រៃយ៍ឬទីតាំងប្រកបអាជីវកម្មសំខាន់នៅព្រះរាជាណាចក្រកម្ពុជា វាពុំមែនជាបញ្ហានោះទេ ដែលម្ចាស់គំនូរឧស្សាហកម្មទៅចុះបញ្ជីដោយខ្លួនឯងនោះ។ ប៉ុន្តែប្រសិនបើមានករណីផ្សេងពីនេះ ម្ចាស់គំនូរឧស្សាហកម្មត្រូវតែរកអ្នកតំណាង ឬភ្នាក់ងារស្របច្បាប់ដើម្បីផ្តល់សិទ្ធិឲ្យពួកគេធ្វើការចុះបញ្ជីជំនួស ឬតំណាងឲ្យម្ចាស់គំនូរឧស្សាហកម្ម។ ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនោះ មានទីលំនៅអចិន្ត្រៃយ៍ ឬក៏ទីតាំងប្រកបអាជីវកម្មចំបងនៅក្រៅព្រះរាជាណាចក្រកម្ពុជា នោះអ្នកស្នើសុំត្រូវតែមានអ្នកតំណាង ឬក៏ភ្នាក់ងារគំនូរឧស្សាហកម្មដែលមានទីលំនៅ ឬប្រកបវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជា និងបានបំពេញទៅតាមលក្ខខណ្ឌតម្រូវទាំងឡាយដែលច្បាប់កំណត់។ សរុបមក ប្រសិនបើម្ចាស់គំនូរឧស្សាហកម្មជាជនបរទេស ដើម្បីចុះបញ្ជីគំនូរឧស្សាហកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានចាំបាច់តម្រូវឲ្យមានអ្នកតំណាង ដើម្បីចុះបញ្ជីគំនូរឧស្សាហកម្ម។

**ឃ. ២ សញ្ញាណនៃម្ចាស់គំនូរឧស្សាហកម្ម**

អ្នកដែលបង្កើតស្នាដៃគំនូរឧស្សាហកម្ម គឺជាម្ចាស់នៃគំនូរឧស្សាហកម្ម។ ហើយម្ចាស់នៃគំនូរឧស្សាហកម្ម មានសិទ្ធិក្នុងការដាក់ឈ្មោះរបស់ខ្លួន ឬមិនដាក់ឈ្មោះរបស់ខ្លួន នៅក្នុងវិញ្ញាបនបត្រចុះបញ្ជីគំនូរឧស្សាហកម្ម។ ប្រសិនបើមិនចង់ដាក់ទេ លើកតែងតែអ្នកបង្កើតស្នាដៃនោះ បានចុះហត្ថលេខាលើសេចក្តីប្រកាស ជាលាយលក្ខណ៍អក្សរពិសេសមួយ រួចផ្ញើជូនមន្ត្រី

[20] មាត្រា៩៦ និងមាត្រា១១៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

កាន់កាប់បញ្ជីដោយបញ្ជាក់ថា ខ្លួនពុំមានបំណងដាក់ឈ្មោះរបស់ខ្លួនឡើយ។ ម៉្យាងទៀត ពាក្យសុំចុះបញ្ជី អាចបញ្ចូលឈ្មោះអ្នកបង្កើតគំនូរឧស្សាហកម្មម្នាក់ ឬច្រើននាក់ ឬឈ្មោះនៃក្រុមអ្នកបង្កើតគំនូរឧស្សាហកម្ម ឬបញ្ជាក់ពីការបោះបង់សិទ្ធិក្នុងការដាក់ឈ្មោះរបស់អ្នកទាំងនេះ។

## ផ្នែកទី២ សញ្ញាណគតិយុត្តនៃគំនូរឧស្សាហកម្មជាអន្តរជាតិ

### កថាខណ្ឌទី១ សញ្ញាណទូទៅនៃគំនូរឧស្សាហកម្ម

#### ក. ប្រវត្តិ និងគោលបំណង

កិច្ចព្រមព្រៀងទីក្រុងឡាអេ បង្កើតឡើងដើម្បីគ្រប់គ្រងទៅលើការចុះបញ្ជីជាអន្តរជាតិ នៃគំនូរឧស្សាហកម្ម។ កិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតនៅឆ្នាំ១៩២៥ ហើយចូលជាធរមាននៅខែមិថុនា ឆ្នាំ១៩២៨ ដែលមានសមាជិកស្ថាបនិកចំនួន ៤ប្រទេស គឺ ប្រទេសអាល្លឺម៉ង់ អេស្ប៉ាញ បារាំង និងស្វីស។ តាមរយៈកិច្ចព្រមព្រៀងនេះ គេបានបង្កើតនូវប្រព័ន្ធអន្តរជាតិមួយ ហៅថា " **ប្រព័ន្ធឡាអេ** " ដែលអនុញ្ញាតអោយមានការការពារទៅលើគំនូរឧស្សាហកម្ម នៅក្នុងប្រទេសជាច្រើន ជាមួយនឹងទម្រង់នៃការដាក់ពាក្យស្នើសុំ។

ទន្ទឹមនឹងនេះផងដែរ កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើការកែសម្រួលចំនួនពីរលើក ដែលលើកទី១ ធ្វើនៅទីក្រុងឡុងដ៍ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៣៤ និងលើកទី២ ធ្វើនៅទីក្រុងឡាអេ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០ ដែលត្រូវបានគេស្គាល់ថា ច្បាប់ឆ្នាំ១៩៦០ ចូលជាធរមាននៅខែសីហា ឆ្នាំ១៩៨៤ និងមានសមាជិកចំនួន ២៤ប្រទេស។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងនេះ ត្រូវបានបំពេញដោយច្បាប់បន្ថែម ដែលចុះហត្ថលេខានៅទីក្រុងម៉ូណាកូ ក្នុងឆ្នាំ១៩៦១ និងដោយច្បាប់បំពេញបន្ថែម ដែលបានចុះហត្ថលេខានៅទីក្រុងស្តុកខុម ក្នុងឆ្នាំ១៩៦៧ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩។ បន្ថែមទៅលើច្បាប់ខាងលើ ច្បាប់មួយទៀត គឺត្រូវបានបង្កើតឡើងនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលត្រូវបានគេស្គាល់ថាច្បាប់ឆ្នាំ១៩៩៩។

ដូចនេះយើងឃើញថា កិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាអន្តរជាតិសំខាន់ៗចំនួន ៣ គឺ ច្បាប់ឆ្នាំ១៩៣៤ ច្បាប់ឆ្នាំ១៩៦០ និងច្បាប់ឆ្នាំ១៩៩៩ ដែលច្បាប់ទាំងបីនេះ គឺមានភាពឯករាជ្យពីគ្នា។ ក៏ប៉ុន្តែ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៩ ការដាក់ពាក្យសុំតាមរយៈច្បាប់ឆ្នាំ១៩៣៤ ត្រូវបាននិរាករណ៍ចោល ដែលមានន័យថា ពុំមានការចុះបញ្ជីថ្មីណាមួយ ដែលអាចដាក់បញ្ចូលទៅក្នុងការចុះបញ្ជីជាអន្តរជាតិ តាមរយៈច្បាប់នេះទៀតទេ។ ហើយការនិរាករណ៍ច្បាប់នេះចោល គឺដើម្បីធ្វើអោយមានភាពសាមញ្ញ និងងាយស្រួលទៅដល់កិច្ចការរដ្ឋបាលទាំងអស់ ដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធនៃការចុះបញ្ជីគំនូរឧស្សាហកម្ម។

ម្យ៉ាងវិញទៀត ដូចដែលយើងបានដឹងមកហើយថា ច្បាប់ឆ្នាំ១៩៩៩ និងច្បាប់ឆ្នាំ១៩៦០ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេ គឺមានភាពឯករាជ្យពីគ្នាទាំងស្រុង ហើយដែលបច្ចុប្បន្ននេះ សមាជិកនៃច្បាប់ឆ្នាំ១៩៩៩ គឺមានចំនួនច្រើនជាងច្បាប់ឆ្នាំ១៩៦០ ដោយសារតែច្បាប់ឆ្នាំ១៩៩៩ គឺបើកទូលាយចំពោះរដ្ឋ ដែលជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងអង្គការអន្តររដ្ឋាភិបាលជាក់លាក់ណាមួយក្នុងការចូលជាសមាជិក ខណៈពេលដែលច្បាប់ឆ្នាំ១៩៦០ គឺអនុញ្ញាតតែចំពោះរដ្ឋជាភាគីនៃសន្ធិសញ្ញាទីក្រុងប៉ារីស សម្រាប់ការការការពារកម្មសិទ្ធិឧស្សាហកម្មឆ្នាំ១៨៨៣ តែប៉ុណ្ណោះ។[21]

ទន្ទឹមនឹងនេះផងដែរ តាមរយៈកិច្ចព្រមព្រៀងទីក្រុងឡាអេ គេបានបង្កើតសហភាពមួយចាប់តាំងពីឆ្នាំ១៩៧០ ហើយបានរៀបចំអោយមាននូវសន្និបាតមួយផងដែរ។ សមាជិកណាមួយដែលជាប់ពាក់ព័ន្ធទៅនឹងច្បាប់បំពេញបន្ថែមនៃទីក្រុងស្តុកខុម គឺជាសមាជិកនៃសន្និបាត។ ហើយការងារសំខាន់ៗរបស់សន្និបាត គឺរៀបចំគម្រោងថវិកាសម្រាប់សហភាពរាល់ពីរឆ្នាំម្តង និងរៀបចំកម្មវិធីកុំព្យូទ័រ និងកម្រៃដែលពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធឡាអេជាដើម។

- **គោលបំណង**

កិច្ចព្រមព្រៀងទីក្រុងឡាអេ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើជាមធ្យោបាយមួយ សម្រាប់ការទទួលបាននូវសិទ្ធិក្នុងការការពារ និងគ្រប់គ្រងទៅលើគំនូរឧស្សាហកម្ម នៅក្នុងប្រទេសមួយចំនួន និងអង្គការអន្តររដ្ឋាភិបាលទាំងឡាយណា ដែលជាសមាជិកនៃសហភាពឡាអេ។ ហើយគោលបំណងដែលសំខាន់ជាងគេនោះ គឺការទទួលបានការការពារពីច្រើនប្រទេស ឬតំបន់ តាមរយៈការដាក់ពាក្យសុំការពារជាអន្តរជាតិតែមួយ បញ្ជូនទៅកាន់ការិយាល័យអន្តរជាតិ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីទទួលបាននូវការចុះបញ្ជីជាអន្តរជាតិ និងការការពារជាអន្តរជាតិនៅក្នុងរដ្ឋ និងអង្គការអន្តររដ្ឋាភិបាលទាំងឡាយណា ដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ។

លើសពីនេះទៅទៀត ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិមួយ អាចរួមបញ្ចូលនូវគំនូរឧស្សាហកម្មបានចំនួន១០០គំនូរឧស្សាហកម្មខុសៗគ្នា។ ម្យ៉ាងវិញទៀត គ្រប់គំនូរឧស្សាហកម្មទាំងអស់នោះ ត្រូវតែស្ថិតនៅក្នុងចំណាត់ថ្នាក់ជាមួយគ្នា ដែលបានកំណត់នៅក្នុងចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម តាមរយៈច្បាប់ឡូកាណូ ដែលត្រូវបានគេហៅថា ចំណាត់ថ្នាក់ឡូកាណូ (Locarno Classification)។

ដូចនេះ កិច្ចព្រមព្រៀងទីក្រុងឡាអេ ជួយអោយអ្នកប្រើប្រាស់ ចំណេញពេលវេលាចំណេញថវិកា មានភាពងាយស្រួល និងឆាប់រហ័ស ក្នុងការទទួលបានការការពារ នៅក្នុងប្រទេសជាច្រើន ពីព្រោះពាក្យសុំចុះបញ្ជីជាអន្តរជាតិតែមួយ អាចជំនួសអោយពាក្យសុំផ្សេងៗគ្នាទាំងឡាយដែលកំណត់ដោយរដ្ឋដែលជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងនេះ។

[21] មាត្រា៩ (២) នៃច្បាប់ទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

**- ផលប្រយោជន៍ពីការប្រើប្រាស់ប្រព័ន្ធឡាអេះ**

១- ប្រព័ន្ធឡាអេ សម្រាប់ការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម គឺកើតពីតម្រូវការ សម្រាប់ភាពងាយស្រួល និងសន្សំសំចៃ។ ហើយជួយសម្រួលអោយម្ចាស់គំនូរឧស្សាហកម្ម ដែលមកពីរដ្ឋហត្ថលេខីអាចទទួលបាននូវការការពារ សម្រាប់គំនូរឧស្សាហកម្មរបស់ពួកគេ ជាមួយនឹងកម្រិតអប្បរមានៃទម្រង់ និងការចំណាយ។ ជាពិសេសទៅទៀត ពួកគេពុំចាំបាច់ត្រូវធ្វើពាក្យសុំជាលក្ខណៈជាតិដាច់ដោយឡែក សម្រាប់រដ្ឋហត្ថលេខីនីមួយៗនោះទេ ហើយការដែលធ្វើបែបនេះ គឺអាចជៀសវាងនូវការលំបាក ដែលអាចកើតឡើងពីនីតិវិធីនៃការដាក់ពាក្យសុំ និងភាសាដែលខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។

២- ប្រព័ន្ធឡាអេ ជួយត្រួតពិនិត្យការផុតកំណត់នៃរយៈពេលចុះបញ្ជីសារឡើងវិញ និងជៀសវាងនូវការបង់កម្រៃទាំងឡាយ ដែលប្រើរូបយប័ណ្ណខុសគ្នា។

៣- ក្រោមកិច្ចព្រមព្រៀងទីក្រុងឡាអេ ការការពារគឺដូចគ្នា ដោយគ្រាន់តែប្រើប្រាស់នូវមធ្យោបាយតែមួយ គឺការចុះបញ្ជីជាអន្តរជាតិធ្វើឡើងក្នុងភាសាតែមួយ ការបង់កម្រៃតែម្តង ក្នុងរូបិយប័ណ្ណតែមួយ (Swiss francs) និងជាមួយការិយាល័យតែមួយ (ការិយាល័យអន្តរជាតិ)។

៤- ការចុះបញ្ជីជាអន្តរជាតិ គឺមានភាពងាយស្រួល និងជះឥទ្ធិពលទៅលើរដ្ឋហត្ថលេខីជាច្រើន។ ឧទាហរណ៍៖ ការផ្លាស់ប្តូរឈ្មោះ ឬផ្លាស់ប្តូរម្ចាស់គំនូរឧស្សាហកម្ម ឬអាសយដ្ឋាននៃអ្នកកាន់កាប់ ត្រូវបានគេដាក់បញ្ចូលទៅក្នុងការចុះឈ្មោះជាអន្តរជាតិ តាមរយៈការិយាល័យអន្តរជាតិសម្រាប់គ្រប់រដ្ឋហត្ថលេខីទាំងអស់ ឬមួយចំនួន។

**ខ. ការក្លាយជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ**

ច្បាប់ឆ្នាំ១៩៩៩ និងច្បាប់ឆ្នាំ១៩៦០ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេ មានភាពឯកច្ឆ័ន្ទ និងឯករាជ្យពីគ្នាទៅវិញទៅមកទាំងស្រុង។ ដូច្នេះ រដ្ឋហត្ថលេខីអាចសម្រេចចិត្ត ក្នុងការក្លាយជាភាគីនៃច្បាប់ណាមួយខាងលើ ឬក្លាយជាភាគីនៃច្បាប់ទាំងពីរនេះតែម្តង។

**រដ្ឋ៖**

ដើម្បីក្លាយជារដ្ឋហត្ថលេខីនៃច្បាប់ឆ្នាំ១៩៦០ រដ្ឋមួយត្រូវតែជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម។

ដើម្បីក្លាយជារដ្ឋហត្ថលេខីនៃច្បាប់ឆ្នាំ១៩៩៩ រដ្ឋមួយត្រូវតែជាសមាជិកនៃអនុសញ្ញា ដែលបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ ទោះបីមិនត្រូវបានគេតម្រូវថា រដ្ឋណាមួយនោះត្រូវតែជាភាគីនៃអនុសញ្ញាទីក្រុងប៉ារីសក៏ដោយ ក៏រដ្ឋទាំងឡាយដែលជាភាគីហត្ថលេខីនៃច្បាប់នេះ ត្រូវតែបំពេញលក្ខខណ្ឌនៃអនុសញ្ញាទីក្រុងប៉ារីស ដែលទាក់ទងនឹងគំនូរឧស្សាហកម្ម។[22]

[22] មាត្រា២ (២) នៃច្បាប់ហ្សឺណែវស្តីពី ការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ២ កក្កដា ១៩៩៩។

**អង្គការអន្តររដ្ឋាភិបាល៖**

អង្គការអន្តររដ្ឋាភិបាលមួយ មិនអាចក្លាយជាភាគីនៃច្បាប់ឆ្នាំ១៩៦០ បានឡើយ ពីព្រោះសមាជិកនៃសន្ធិសញ្ញានេះ គឺត្រូវបានអនុញ្ញាតចំពោះតែរដ្ឋប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត អង្គការអន្តររដ្ឋាភិបាល អាចក្លាយជាភាគីនៃច្បាប់ឆ្នាំ១៩៩៩ ត្រូវតែបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- យ៉ាងហោចណាស់ រដ្ឋសមាជិកមួយនៃអង្គការអន្តររដ្ឋាភិបាលនោះ ជាសមាជិកនៃWIPO រួចហើយ

- អង្គការត្រូវមានការិយាល័យមួយដែលការពារគំនូរឧស្សាហកម្ម ទើបអាចរក្សាអានុភាពក្នុងដែនដីនៃរដ្ឋជាសមាជិក នៃអង្គការអន្តររដ្ឋាភិបាលដែលបានដាក់ពាក្យសុំ។

**ការចូលជាធរមាននៃច្បាប់ឆ្នាំ១៩៩៩ និងច្បាប់ឆ្នាំ១៩៦០ នៅក្នុងភាគីហត្ថលេខី៖**

ទាក់ទងទៅនឹងច្បាប់ឆ្នាំ១៩៦០ ការយល់ព្រម ឬការផ្តល់សច្ចាប័ននៃភាគីហត្ថលេខី ចូលជាធរមាន ១ខែ បន្ទាប់ពីលិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រម ត្រូវបានជូនដំណឹងដោយអគ្គនាយករបស់ WIPO ទៅកាន់ភាគីហត្ថលេខីដែលពាក់ព័ន្ធ។

ចំណែកឯច្បាប់ឆ្នាំ១៩៩៩ ការយល់ព្រម ឬការផ្តល់សច្ចាប័ននៃភាគីហត្ថលេខី គឺចូលជាធរមាន ៣ខែ បន្ទាប់ពីកាលបរិច្ឆេទដែលលិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រម ត្រូវបានដាក់ទៅកាន់អគ្គនាយករបស់ WIPO ទោះជាយ៉ាងណាក៏ដោយ៖

-រដ្ឋដែលការពារគំនូរឧស្សាហកម្ម តាមរយៈការដាក់ពាក្យសុំនៅអង្គការអន្តររដ្ឋាភិបាល ការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រម មិនអាចមានអានុភាពមុនកាលបរិច្ឆេទនៃការតម្កល់លិខិតតុបករណ៍នៃអង្គការអន្តររដ្ឋាភិបាល ទៅកាន់រដ្ឋជាកម្មសិទ្ធិទាំងនោះ។

-ហើយចំពោះរដ្ឋទាំងឡាយណា ដែលបានធ្វើការប្រកាសថា ការិយាល័យដែលបង្កើតឡើងដោយអង្គការអន្តររដ្ឋាភិបាល មានប្រសិទ្ធិភាពក្នុងការធ្វើសកម្មភាព ដូចទៅនឹងការិយាល័យជាតិ។ តាមច្បាប់ឆ្នាំ១៩៩៩ ចូលជាធរមាន ៣ខែ និង/ឬច្បាប់ឆ្នាំ១៩៦០ ចូលជាធរមាន ១ខែ ចាប់ពីកាលបរិច្ឆេទដែលតម្កល់លិខិតតុបករណ៍ចុងក្រោយនៃរដ្ឋសមាជិក។

រដ្ឋដែលនឹងក្លាយជាភាគីហត្ថលេខី មិនត្រូវបានគេចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ឡើយ តែអាចជាលក្ខខណ្ឌក្នុងការផ្តល់សច្ចាប័ន ឬការយល់ព្រមចំពោះច្បាប់នោះ លុះត្រាតែភាគីហត្ថលេខីមួយ ឬច្រើនផ្សេងទៀត ត្រូវបានចងភ្ជាប់ដោយច្បាប់នោះដូចគ្នា។ នៅក្នុងករណីនេះ ការផ្តល់សច្ចាប័ន ឬការយល់ព្រម អាចមានអានុភាព ប្រសិនបើភាគីហត្ថលេខីមួយ ឬច្រើន បានតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រម។ លិខិតតុបករណ៍មានលក្ខខណ្ឌនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម ដូចនេះ លិខិតតុបករណ៍មួយ ត្រូវបានចាត់ទុកថា បានតម្កល់នៅថ្ងៃដែល

លក្ខខណ្ឌត្រូវបានបំពេញ ដូចជា ថ្ងៃដែលភាគីហត្ថលេខីពាក់ព័ន្ធ តម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រមជាដើម។

**ច្បាប់ដែលប្រើប្រាស់ដោយភាគីហត្ថលេខី៖**

ជាងនេះទៅទៀត ដើម្បីឱ្យដឹងថា តើភាគីហត្ថលេខីមួយចងភ្ជាប់ដោយច្បាប់មួយ ឬទាំងពីរនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ សំណួរត្រូវបានលើកឡើងទាក់ទងនឹងពាក្យសុំអន្តរជាតិមួយ ដែលបង្កើតដោយភាគីហត្ថលេខីនោះ។

ច្បាប់ដែលឆ្លើយតបទៅនឹងភាគីហត្ថលេខីមួយ ពឹងផ្អែកទៅលើច្បាប់ទាំងឡាយណា ដែលចងភ្ជាប់ដោយភាគីហត្ថលេខី (ច្បាប់ឆ្នាំ១៩៦០ និង/ឬ ច្បាប់ឆ្នាំ១៩៩៩) និងមួយទៀតទាក់ទងទៅនឹងពាក្យសុំ ដែលបង្កើតឡើងដោយភាគីហត្ថលេខីនោះ។

-នៅពេលដែលមានច្បាប់ជាធរមាន រវាងភាគីហត្ថលេខីដែលពាក់ព័ន្ធ នោះច្បាប់នោះហើយដែលគ្រប់គ្រងទៅលើភាគីហត្ថលេខី។ ឧទាហរណ៍ ប្រសិនបើអ្នកដាក់ពាក្យសុំមកពីភាគីហត្ថលេខីដែលបានចងភ្ជាប់ដោយច្បាប់ទាំងពីរ គឺច្បាប់ឆ្នាំ១៩៩៩ និងច្បាប់ឆ្នាំ១៩៦០ ការបង្កើតពាក្យសុំអន្តរជាតិ គឺត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាន គឺច្បាប់ឆ្នាំ១៩៦០។

-នៅពេលដែលភាគីហត្ថលេខីទាំងពីរ ត្រូវបានចងភ្ជាប់ដោយច្បាប់ជាធរមានច្រើនជាងមួយ គឺត្រូវប្រើប្រាស់ច្បាប់ទាំងឡាយណា ដែលឆ្លើយតបទៅនឹងភាគីហត្ថលេខីច្រើនជាងគេ ឧទាហរណ៍ ប្រសិនបើអ្នកដាក់ពាក្យសុំមកពីភាគីហត្ថលេខី ដែលបានភ្ជាប់ដោយច្បាប់ទាំងពីរ គឺច្បាប់ឆ្នាំ១៩៦០ និងច្បាប់ឆ្នាំ១៩៩៩ ការបង្កើតពាក្យសុំអន្តរជាតិនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ដែលអនុវត្តច្រើនជាងគេ គឺច្បាប់ឆ្នាំ១៩៩៩។

នៅក្នុងករណីពាក្យសុំអន្តរជាតិ ត្រូវបានដាក់នៅក្នុងប្រទេស ដែលជាភាគីហត្ថលេខីមួយ ហើយត្រូវបានចងភ្ជាប់ដោយច្បាប់ជាច្រើន (ច្បាប់ឆ្នាំ១៩៦០ និងច្បាប់១៩៩៩) នោះច្បាប់ដែលអនុវត្តគឺច្បាប់ឆ្នាំ១៩៩៩។ ឧទាហរណ៍ ប្រសិនបើអ្នកដាក់ពាក្យសុំ ដាក់ពាក្យសុំនៅក្នុងប្រទេសដែលជាភាគីហត្ថលេខីមួយ ហើយចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៦០ ក៏ប៉ុន្តែភាគីហត្ថលេខីនោះ ក៏ជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាល ដែលបានចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ផងដែរ នៅក្នុងករណីនេះ គេសន្មតថា វាត្រូវបានចងភ្ជាប់ដោយច្បាប់ទាំងពីរ គឺច្បាប់ឆ្នាំ១៩៦០ និងច្បាប់ឆ្នាំ១៩៩៩។

ច្បាប់ណាមួយដែលឆ្លើយតបទៅនឹងភាគីហត្ថលេខី គឺត្រូវបានគេធ្វើឡើងនៅកាលបរិច្ឆេទនៃការបញ្ជូនពាក្យសុំអន្តរជាតិដែលពាក់ព័ន្ធ។ លើសពីនេះទៅទៀត ភាគីហត្ថលេខីអាចយល់ព្រមតាមច្បាប់មួយទៀត នៃកិច្ចព្រមព្រៀងទីក្រុងឡាអេបាន ដោយការបញ្ជូនពាក្យសុំអន្តរជាតិ។ ការបញ្ជូនពាក្យសុំអន្តរជាតិ ដោយភាគីហត្ថលេខីនេះ គឺដើម្បីកំណត់ថា ការអនុវត្តការចុះបញ្ជីជាអន្តរជាតិនៃភាគីហត្ថលេខីនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ណាមួយពិតប្រាកដ។

**ខ.១ ការប្រកាសដោយរដ្ឋហត្ថលេខី**

ប្រព័ន្ធឡាអេ ផ្ដល់លទ្ធភាពសម្រាប់ភាគីហត្ថលេខី ក្នុងការធ្វើសេចក្ដីប្រកាសទាក់ទងទៅនឹងការរៀបចំប្រព័ន្ធចុះបញ្ជីជាអន្តរជាតិ។

ការប្រកាសនេះ ត្រូវបានធ្វើដោយភាគីហត្ថលេខីទាំងឡាយណា ដែលមានការិយាល័យជាការិយាល័យត្រួតពិនិត្យ ហើយក្នុងករណីនេះ ការិយាល័យដែលត្រួតពិនិត្យពាក្យសុំសម្រាប់ការការពារគំនូរឧស្សាហកម្ម ហើយការត្រួតពិនិត្យនេះ យ៉ាងហោចណាស់ដើម្បីឱ្យដឹងថា តើគំនូរគោរពតាមលក្ខខណ្ឌនៃភាពថ្មីរបស់វា ឬអត់។ ហើយវាក៏ត្រួតពិនិត្យភាពថ្មីផងដែរ ក្រោយពីទទួលបានការជំទាស់ពីភាគីទីបី ទាក់ទងនឹងគំនូរឧស្សាហកម្មនេះ។

ការប្រកាសនេះ អាចធ្វើឡើងបាននៅក្នុងដំណាក់កាល នៃការតម្កល់លិខិតតុបករណ៍ នៃការយល់ព្រម ឬផ្ដល់សច្ចាប័ន ឬក៏បន្ទាប់ពីការតម្កល់លិខិតតុបករណ៍ទាំងនេះ។ ហើយអានុភាពនៃការប្រកាសនេះ មានពីរករណី គឺក្នុងករណីទីមួយ ការប្រកាសមានអានុភាពចាប់ពីកាលបរិច្ឆេទដែលភាគីហត្ថលេខី ត្រូវបានចងភ្ជាប់ដោយច្បាប់។ ក្នុងករណីទីពីរ ការប្រកាសនេះមានអានុភាព ៣ខែ (ក្រោមច្បាប់ឆ្នាំ១៩៦០) បន្ទាប់ពីកាលបរិច្ឆេទនៃការទទួល ដោយអគ្គនាយករបស់ WIPO ឬកាលបរិច្ឆេទបន្ទាប់ដែលបានបង្ហាញក្នុងប្រកាស។ ជាងនេះទៅទៀត រាល់ការប្រកាសដែលបង្កើតឡើង ក្រោយពីការតម្កល់លិខិតតុបករណ៍នៃការយល់ព្រម ឬការផ្ដល់សច្ចាប័ន នឹងត្រូវបានដាក់បញ្ចូលក្នុងពាក្យសុំអន្តរជាតិ ដែលកាលបរិច្ឆេទនៃពាក្យសុំអន្តរជាតិនោះ ដូចគ្នាទៅនឹងកាលបរិច្ឆេទនៃការប្រកាស។

បន្ថែមលើនេះទៅទៀត ការិយាល័យអន្តរជាតិនឹងចុះផ្សាយនៅលើគេហទំព័ររបស់WIPO នូវរាល់ការប្រកាសដែលបង្កើតឡើងដោយភាគីហត្ថលេខី ក្រោមច្បាប់ឆ្នាំ១៩៩៩ ច្បាប់ឆ្នាំ១៩៦០ ឬក្រោមបទបញ្ជា។

**ខ.២ ការហាមឃាត់ចំពោះការជ្រើសតាំងខ្លួនឯង**

រាល់ភាគីហត្ថលេខីទាំងអស់ ដែលចងដោយច្បាប់ឆ្នាំ១៩៩៩ ដែលមានការិយាល័យជាការិយាល័យត្រួតពិនិត្យ នោះភាគីហត្ថលេខីអាចជូនដំណឹងទៅអគ្គនាយករបស់ WIPO ថា នៅពេលដែលវាជាភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ នោះការជ្រើសតាំងភាគីហត្ថលេខីនោះ នៅក្នុងការចុះបញ្ជីជាអន្តរជាតិ គឺគ្មានអានុភាពទេ។

**ខ.៣ ការរួមបញ្ចូលនៃគំនូរ**

ភាគីហត្ថលេខីមួយត្រូវបានចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ត្រូវជូនដំណឹងទៅអគ្គនាយករបស់WIPO។ នៅក្នុងសេចក្ដីប្រកាស ប្រសិនបើច្បាប់តម្រូវថា គំនូរស្ថិតនៅក្នុងប្រភេទនៃពាក្យសុំ

ដូចគ្នា គឺត្រូវគោរពទៅតាមការឯកភាពគ្នានៃគំនូរ ការឯកភាពគ្នានៃការការពារ ឬការឯកភាពគ្នានៃការប្រើប្រាស់ ឬជាបណ្តុំនៃវត្ថុ ឬក៏ជាគំនូរឯករាជ្យដាច់ពីគ្នា ដែលត្រូវអះអាងនៅក្នុងពាក្យសុំអន្តរជាតិមួយ។

**-រូបភាពច្បាស់លាស់នៃគំនូរដែលគេតម្រូវ**

រាល់ភាគីហត្ថលេខី ចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ តម្រូវឱ្យមានការបង្ហាញច្បាស់លាស់ និងជាក់លាក់អំពីគំនូរនៃផលិតផល ដែលត្រូវបង្កើតជាគំនូរឧស្សាហកម្ម ឬវត្ថុទាក់ទងទៅនឹងគំនូរឧស្សាហកម្មដែលត្រូវបានប្រើប្រាស់ ត្រូវជូនដំណឹងទៅអគ្គនាយករបស់ WIPO បញ្ជាក់អំពីគំនូរដែលត្រូវបានគេតម្រូវ និងស្ថានភាពនៅក្នុងគំនូរដែលគេតម្រូវ។

ទោះជាយ៉ាងណាក៏ដោយ ភាគីហត្ថលេខីត្រូវផ្តល់រូបភាពច្រើនជាងមួយ សម្រាប់គំនូរឧស្សាហកម្មជារូបភាពទម្រង់ពីរខ្នាត ឬទម្រង់បីខ្នាត។

**ខ.៤ ផលប៉ះពាល់ដែលកើតចេញពីការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ**

រាល់ភាគីហត្ថលេខី ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ត្រូវជូនដំណឹងទៅអគ្គនាយករបស់ WIPO នៅក្នុងសេចក្តីប្រកាសរបស់ខ្លួនថា ការថតចម្លងនៅក្នុងការចុះឈ្មោះជាអន្តរជាតិ នៃការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ នៃការចុះបញ្ជីជាអន្តរជាតិ នឹងមិនត្រូវប៉ះពាល់ដល់រដ្ឋហត្ថលេខី រហូតដល់ការិយាល័យជាតិនៃរដ្ឋហត្ថលេខីនោះ បានទទួលឯកសារ ដូចដែលបានបញ្ជាក់នៅក្នុងការប្រកាស។

**ខ.៥ សុពលភាពនៃការអនុញ្ញាត**

រាល់ភាគីហត្ថលេខីទាំងឡាយណា ដែលបានក្លាយទៅជាភាគីនៃច្បាប់ឆ្នាំ១៩៩៩ ត្រូវជូនដំណឹងទៅអគ្គនាយករបស់ WIPO ថា រយៈពេល ១ខែ ដែលបញ្ជូនពាក្យសុំអន្តរជាតិទៅការិយាល័យអន្តរជាតិ នឹងត្រូវបានជំនួសដោយរយៈពេល ៦ខែ វិញ។

**គ. ការហាមឃាត់ចំពោះការបញ្ជូនតាមរយៈការិយាល័យជាតិ**

រាល់ភាគីហត្ថលេខី ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ពាក្យសុំអន្តរជាតិមិនអាចបញ្ជូនតាមរយៈការិយាល័យជាតិរបស់ខ្លួនបានឡើយ។

**ឃ. ការិយាល័យជាក់លាក់មួយសម្រាប់រដ្ឋច្រើន**

ប្រសិនបើរដ្ឋច្រើនមានបញ្ហាទាក់ទងការរួមបញ្ចូលគ្នានៃច្បាប់ជាតិ ទៅលើគំនូរឧស្សាហកម្មនោះគេអាចជូនដំណឹងទៅអគ្គនាយករបស់WIPO ថា៖

-ការិយាល័យមួយត្រូវបានបង្កើតឡើងសម្រាប់ការិយាល័យជាតិនីមួយៗ

-ដែនដីដែលមានការរួមបញ្ចូលគ្នានៃច្បាប់ជាតិនោះ គឺត្រូវបានចាត់ទុកថា ជាភាគីហត្ថលេខីតែមួយ សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ។

**កថាខណ្ឌទី២ ការប្រព្រឹត្តទៅនៃពាក្យសុំអន្តរជាតិ**

**ក. ការកំណត់នៃច្បាប់ដែលគ្រប់គ្រងពាក្យសុំអន្តរជាតិទាំងស្រុង**

ពាក្យសុំអន្តរជាតិ ដែលបង្កើតដោយភាគីហត្ថលេខីមួយ អាចត្រូវបានគ្រប់គ្រងដោយច្បាប់តែមួយ។ ក៏ប៉ុន្តែក្នុងករណីនេះ គេក៏អាចប្រើប្រាស់ច្បាប់ច្រើនដែលពាក់ព័ន្ធនៅក្នុងពាក្យសុំអន្តរជាតិមួយផងដែរ។ ហើយវាពឹងផ្អែកទៅលើថា តើភាគីហត្ថលេខីបានបង្កើតក្រោមច្បាប់ឆ្នាំ១៩៩៩ និង/ឬច្បាប់ឆ្នាំ១៩៦០។

ទន្ទឹមនឹងនេះផងដែរ វាពិតជាចាំបាច់ខ្លាំងណាស់ សម្រាប់អ្នកដាក់ពាក្យសុំ ត្រូវដឹងថា ច្បាប់ណាមួយគ្រប់គ្រងពាក្យសុំអន្តរជាតិ នៅក្នុងរដ្ឋភាគីហត្ថលេខីណាមួយនោះ ពីព្រោះងាយស្រួលក្នុងការដាក់ពាក្យសុំអន្តរជាតិ ក៏ដូចជាលទ្ធភាពក្នុងការស្នើសុំពន្យារពេលនៃការចុះផ្សាយ និងកម្រៃដែលអាចបង់ផងដែរ។

សរុបមក ពាក្យសុំអន្តរជាតិមានបីប្រភេទ ដែលអាចយកមកប្រើប្រាស់ ដូចជា៖

- ពាក្យសុំអន្តរជាតិ ដែលបង្កើតឡើងក្រោមច្បាប់ឆ្នាំ១៩៩៩
- ពាក្យសុំអន្តរជាតិ ដែលបង្កើតឡើងក្រោមច្បាប់ឆ្នាំ១៩៦០
- ពាក្យសុំអន្តរជាតិ ដែលបានរួមបញ្ចូលដោយច្បាប់ទាំងពីរ គឺច្បាប់ឆ្នាំ១៩៩៩ និងច្បាប់ឆ្នាំ១៩៦០។

ករណីនេះ អាចត្រូវបានបង្ហាញជាមួយនឹងឧទាហរណ៍ដូចខាងក្រោម៖

អ្នកដាក់ពាក្យសុំដែលមកពីភាគីហត្ថលេខីមួយ ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ និងច្បាប់ឆ្នាំ១៩៦០ ត្រូវបានសន្មតជាដំបូងគេថា ពាក្យសុំអន្តរជាតិរបស់គាត់ គឺត្រូវបានចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ទាំងអស់ មានន័យថា គឺត្រូវធ្វើឡើងក្រោមច្បាប់ឆ្នាំ១៩៩៩ តែមួយគត់។

ក៏ប៉ុន្តែ ប្រសិនបើអ្នកដាក់ពាក្យសុំ ដែលមកពីភាគីហត្ថលេខីមួយ ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៦០ ទោះបីជាពាក្យសុំ ត្រូវបានគ្រប់គ្រងដោយច្បាប់ឆ្នាំ១៩៦០ និងច្បាប់ឆ្នាំ១៩៩៩ ក៏ដោយក៏ច្បាប់ដែលត្រូវយកមកអនុវត្ត គឺច្បាប់ឆ្នាំ១៩៦០។

**ក.១ មាតិកាចាំបាច់នៃពាក្យសុំអន្តរជាតិ**

រាល់ភាគីហត្ថលេខីទាំងអស់ ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ មានការិយាល័យជាការិយាល័យត្រួតពិនិត្យ នោះភាគីហត្ថលេខីអាចជូនដំណឹងទៅអគ្គនាយករបស់ WIPO ថា ពាក្យសុំអន្តរជាតិត្រូវតែមាននូវ ការបង្ហាញនូវអត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំ សេចក្តីអធិប្បាយខ្លីមួយ និង

សេចក្តីអះអាង ដើម្បីបំពេញគ្រប់លក្ខខណ្ឌនៃពាក្យសុំ ហើយកាលបរិច្ឆេទបញ្ជូន ត្រូវស្ថិតនៅក្រោមច្បាប់នៃភាគីហត្ថលេខីនោះ។

**ក.២ ការតម្រូវពិសេសទាក់ទងនៅនឹងអ្នកដាក់ពាក្យសុំ និងអ្នកបង្កើត**

រដ្ឋហត្ថលេខីដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ តម្រូវថា ដើម្បីការពារគំនូរឧស្សាហកម្មពាក្យសុំអន្តរជាតិ ត្រូវបញ្ជូនឈ្មោះអ្នកបង្កើតគំនូរឧស្សាហកម្មនោះ។ រដ្ឋហត្ថលេខីអាចជូនដំណឹងទៅអគ្គនាយករបស់ WIPO នៅក្នុងសេចក្តីប្រកាសរបស់ខ្លួន អំពីអ្នកបង្កើតគំនូរឧស្សាហកម្មនោះ។ ហើយនៅក្នុងសេចក្តីប្រកាសនោះ ក៏ត្រូវបញ្ជាក់អំពីទម្រង់ និងមាតិកាដែលចាំបាច់នៃឯកសារ ឬស្ថានភាពដែលតម្រូវផងដែរ។

**ក.៣ បុគ្គលដែលអាចដាក់ពាក្យសុំ**

ដើម្បីទទួលបាននូវការការពារគំនូរឧស្សាហកម្មជាអន្តរជាតិ ការដាក់ពាក្យសុំចុះបញ្ជី គឺពុំបើកទូលាយ ឬអនុញ្ញាតចំពោះបុគ្គលគ្រប់រូបនោះទេ។ ដើម្បីអាចទទួលបាននូវសិទ្ធិក្នុងការដាក់ពាក្យសុំនេះ អ្នកដាក់ពាក្យសុំត្រូវតែគោរពទៅតាមលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌខាងក្រោម ៖

- ជាពលរដ្ឋនៃរដ្ឋហត្ថលេខី ឬរដ្ឋដែលជាសមាជិកនៃអង្គការអន្តររដ្ឋាភិបាល ដែលជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ
- មានទីលំនៅក្នុងទឹកដីនៃរដ្ឋដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ
- មានស្ថាប័នឧស្សាហកម្មពិតប្រាកដ ហើយកំពុងដំណើរការនៅក្នុងទឹកដីនៃរដ្ឋ ដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ។[23]

ម្យ៉ាងវិញទៀត ការការពារគឺអាចត្រូវបានផ្តល់អោយ ចំពោះអ្នកដាក់ពាក្យសុំទាំងឡាយណា ដែលច្បាប់នៃការការពារគំនូរឧស្សាហកម្មរបស់រដ្ឋខ្លួន ដូចគ្នាទៅនឹងច្បាប់របស់រដ្ឋហត្ថលេខីដទៃទៀត ដែលខ្លួនមានបំណងចង់អោយផ្តល់នូវការការពារ ទៅលើគំនូរឧស្សាហកម្មណាមួយនោះ។

ឧទាហរណ៍ទី១ ៖ សញ្ជាតិ ទីលំនៅ ស្ថាប័ន ឬគ្រឹះស្ថាន ដែលសុទ្ធសឹងជាលក្ខខណ្ឌចាំបាច់ដែលកំណត់ក្នុងច្បាប់ ដើម្បីទទួលបានការការពារ។

ឧទាហរណ៍ទី២ ៖ ប្រសិនអ្នកដាក់ពាក្យសុំ ជាប្រជាពលរដ្ឋនៃរដ្ឋហត្ថលេខីដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ នោះអ្នកដាក់ពាក្យសុំ អាចដាក់ពាក្យសុំតែនៅរដ្ឋហត្ថលេខីទាំងឡាយណាដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ដូចគ្នាតែប៉ុណ្ណោះ ហើយពុំអាចសុំអោយមានការការពារនៅរដ្ឋហត្ថលេខីទាំងឡាយណា ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៦០ នោះទេ។

---
[23] មាត្រា៣ នៃច្បាប់ទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០ និងច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម។

ដូចបានរៀបរាប់រួចមកហើយថា កិច្ចព្រមព្រៀងទីក្រុងឡាអេ បានបង្កើតប្រព័ន្ធអន្តរជាតិមួយដែលហៅថា ប្រព័ន្ធឡាអេ។ ប្រព័ន្ធនេះ មិនត្រូវបានប្រើប្រាស់ ដើម្បីការពារគំនូរឧស្សាហកម្មរបស់បុគ្គលណា ដែលមិនគោរពទៅតាមលក្ខខណ្ឌដែលកំណត់ថា ពលរដ្ឋរបស់រដ្ឋហត្ថលេខី និងបុគ្គលទាំងឡាយ ដែលពុំមែនជាពលរដ្ឋនៃរដ្ឋហត្ថលេខីណាមួយ ដែលមានលំនៅដ្ឋាន ឬមានគ្រឹះស្ថានពាណិជ្ជកម្ម ឬឧស្សាហកម្មពិត និងកំពុងដំណើរការនៅក្នុងដែនដីនៃរដ្ឋហត្ថលេខី អាចតម្កល់គំនូរនៅការិយាល័យអន្តរជាតិបាន។[24] ដូចនេះ ដើម្បីទទួលបានការការពារគំនូរឧស្សាហកម្មនៅក្នុងប្រទេសណាមួយនោះ អ្នកដាក់ពាក្យសុំគ្មានជម្រើសនោះទេ គឺមានតែវិធីមួយគត់ គឺដាក់ពាក្យសុំទៅកាន់រដ្ឋដែលខ្លួនចង់អោយមានការការពារនោះផ្ទាល់តែម្តង។

**ក.៤ អានុភាពនៃការចុះបញ្ជីជាអន្តរជាតិ**

ជាគោលការណ៍ ម្ចាស់នៃគំនូរឧស្សាហកម្មដែលបានចុះបញ្ជីហើយ មានសិទ្ធិក្នុងការការពារមិនអោយតតិយជនធ្វើការបង្កើត លក់ ឬនាំចូលនូវការចតចម្លងនៃគំនូរឧស្សាហកម្ម ក្នុងគោលបំណងធ្វើពាណិជ្ជកម្មឡើយ។[25]

ជាមួយគ្នានេះដែរ ការតម្កល់ដែលបានចុះបញ្ជី នៅការិយាល័យអន្តរជាតិ ត្រូវមានអានុភាពដូចៗគ្នានៅក្នុងរដ្ឋហត្ថលេខីនីមួយៗ ដែលបានជ្រើសរើសដោយអ្នកដាក់ពាក្យសុំ ក្នុងពាក្យសុំរបស់ខ្លួន ប្រសិនបើគ្រប់ទម្រង់ដែលបានទាមទារដោយច្បាប់ជាតិ ដើម្បីផ្តល់កិច្ចការពារបានអនុវត្តតាមដោយអ្នកដាក់ពាក្យសុំ ហើយប្រសិនបើគ្រប់លិខិតរដ្ឋបាលទាំងអស់ ដែលបានទាមទារក្នុងរឿងនេះ ត្រូវបានបំពេញដោយការិយាល័យនៃរដ្ឋនេះ។

ជាងនេះទៅទៀត ប្រសិនបើអង្គការអន្តររដ្ឋាភិបាលណាមួយ ជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ត្រូវបានគេស្នើសុំនៅក្នុងពាក្យសុំអន្តរជាតិមួយ នោះការការពារគឺគ្របដណ្តប់ទៅលើដែនដីទាំងអស់នៃរដ្ឋជាសមាជិកអង្គការអន្តររដ្ឋាភិបាលនោះតែម្តង។

យ៉ាងណាមិញ ការតម្កល់ជាអន្តរជាតិ មិនត្រូវមានអានុភាក្នុងរដ្ឋដើមឡើយ ប្រសិនបើច្បាប់នៃរដ្ឋនោះចែងដូច្នេះ។[26]

**ខ. រយៈពេលនៃការការពារ**

រាល់ភាគីហត្ថលេខីដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ឬច្បាប់ឆ្នាំ១៩៦០ អាចជូនដំណឹងទៅអគ្គនាយករបស់WIPO នៅក្នុងសេចក្តីប្រកាស អំពីរយៈពេលនៃការការពារអតិបរមា ដែលផ្តល់ឱ្យដោយច្បាប់ជាតិរបស់ខ្លួន។

---

[24] មាត្រា៣ នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[25] មាត្រា៧ ចំណុចក (១) នៃច្បាប់ទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[26] មាត្រា៧ ចំណុចក (២) នៃច្បាប់ទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

**-ការបន្ថែមរយៈពេលសម្រាប់ជូនដំណឹងការបដិសេធ និងកាលបរិច្ឆេទដែលគំនូរឧស្សាហកម្ម ត្រូវបានការពារ**

រាល់ភាគីហត្ថលេខីទាំងអស់ ដែលចងដោយច្បាប់ឆ្នាំ១៩៩៩ ហើយមានការិយាល័យជា ការិយាល័យត្រួតពិនិត្យ ត្រូវជូនដំណឹងទៅអគ្គនាយករបស់WIPO ថា រយៈពេលបដិសេធមិនផ្តល់ ការការពារ ៦ខែ ត្រូវជំនួសដោយ ១២ខែ វិញ។

**គ. ការពន្យារការចុះផ្សាយសម្រាប់រយៈពេលដែលតិចជាងរយៈពេលកំណត់**

នៅពេលច្បាប់នៃភាគីហត្ថលេខីដែលត្រូវបានចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ផ្តល់ការពន្យារ ពេលចុះផ្សាយ សម្រាប់រយៈពេលមួយដែលតិចជាងរយៈពេលកំណត់ (៣០ខែ) នោះភាគីហត្ថលេខី ត្រូវជូនដំណឹងទៅអគ្គនាយករបស់ WIPO នៅក្នុងសេចក្តីប្រកាស អំពីរយៈពេលអនុញ្ញាតនៃការ ពន្យារ។

**- ការហាមឃាត់ចំពោះការពន្យារការចុះផ្សាយ**

នៅពេលដែលច្បាប់នៃភាគីហត្ថលេខី ដែលត្រូវបានចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ មិនផ្តល់ ការពន្យារពេលសម្រាប់ការចុះផ្សាយ ភាគីហត្ថលេខីត្រូវជូនដំណឹងទៅអគ្គនាយករបស់ WIPO នៅ ក្នុងសេចក្តីប្រកាសអំពីការពិតនោះផងដែរ។

**ឃ. កម្រៃស្តង់ដានៃការបង្កើត**

កម្រៃស្តង់ដាមានចំនួនបីកម្រិត ដែលឆ្លុះបញ្ចាំងពីកម្រិតការត្រួតពិនិត្យ ដែលធ្វើឡើងដោយ ការិយាល័យនៃភាគីហត្ថលេខី។ លើសពីនេះទៅទៀត ពាក្យសុំដែលស្ថិតនៅក្នុងកម្រិតទី២ និងទី៣ នឹងត្រូវបានពឹងផ្អែកទៅលើការបញ្ជាក់ នៅក្នុងសេចក្តីប្រកាសរបស់ភាគីហត្ថលេខី។ ក្នុងករណី ដែលអវត្តមាននៃសេចក្តីប្រកាស កម្រិតទី១ នឹងត្រូវបានចាត់ទុកថាយកមកប្រើប្រាស់។ ហើយការ តម្រូវដែលបានធ្វើឡើងនៅក្នុងសេចក្តីប្រកាស នឹងត្រូវប្រាកដថា អ្នកប្រើប្រាស់បានដឹងនូវកម្រិត ច្បាស់លាស់នៃកម្រៃស្តង់ដា ដែលកំណត់នៅភាគីហត្ថលេខីនោះ។ ហើយវាគួរតែត្រូវបានគេកត់ សម្គាល់ថា ភាគីហត្ថលេខីអាចជ្រើសរើសកម្រៃស្តង់ដា ជំនួសអោយកម្រៃផ្ទាល់ខ្លួន ឬក៏អាចធ្វើការ ជ្រើសរើសកម្រិតទាបជាងនៃកម្រៃស្តង់ដា ទោះបីទទួលបានច្រើនជាងនេះក៏ដោយ។

រាល់ភាគីហត្ថលេខី ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ឬច្បាប់ឆ្នាំ១៩៦០ ហើយមាន ការិយាល័យជាការិយាល័យធ្វើការត្រួតពិនិត្យទូទៅ មិនត្រួតពិនិត្យតែលើភាពថ្មី។ ឧទាហរណ៍ បញ្ហាទាក់ទងទៅនឹងអត្តន័យនៃគំនូរឧស្សាហកម្ម បទដ្ឋានសាធារណៈ និងសីលធម៌ជាដើម នោះ ភាគីហត្ថលេខីអាចជូនដំណឹងទៅអគ្គនាយករបស់ WIPO ថា កម្រៃជាមូលដ្ឋាននៅក្នុងករណីនេះ គឺ ស្ថិតនៅក្នុងកម្រិតទី២ ជំនួសឱ្យការបង់កម្រៃដែលស្ថិតនៅក្នុងកម្រិតទី១។

រាល់ភាគីហត្ថលេខី ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩៩ ឬច្បាប់ឆ្នាំ១៩៦០ ហើយមានការិយាល័យជាការិយាល័យត្រួតពិនិត្យទៅលើចំនុចដែលសំខាន់ ដូចជា ការត្រួតពិនិត្យទៅលើភាពថ្មី។ ឧទាហរណ៍ ការត្រួតពិនិត្យភាពថ្មីត្រឹមតែនៅក្នុងតំបន់ប៉ុណ្ណោះ ដែលមិនពិនិត្យមើលថា តើថ្មីទូទាំងសកលលោកនោះទេ ស្របពេលដែលស្តង់ដាសុពលភាពនៃសិទ្ធិគំនូរ គឺថ្មីទូទាំងសកលលោក ឬការត្រួតពិនិត្យភាពថ្មី ដោយយោងទៅតាមការជំទាស់ពីភាគីទីបី នោះភាគីហត្ថលេខីអាចជូនដំណឹងទៅអគ្គនាយក WIPO ថា ស្តង់ដានៃការបង់កម្រៃ គឺស្ថិតនៅក្នុងកម្រិតទីពីរ ឬទីបី ជំនួសឱ្យកម្រិតទីមួយ។

**- កម្រៃឯកជន ៖ ពាក្យសុំអន្តរជាតិ និងការចុះបញ្ជីសារឡើងវិញ**

រាល់ភាគីហត្ថលេខីទាំងអស់ ដែលចងដោយច្បាប់ឆ្នាំ១៩៩៩ ដែលមានការិយាល័យជាការិយាល័យត្រួតពិនិត្យ និងរាល់ភាគីហត្ថលេខីដែលជាអង្គការអន្តរដ្ឋាភិបាល ភាគីហត្ថលេខីនោះអាចជូនដំណឹងទៅអគ្គនាយករបស់ WIPO ថា នៅក្នុងពាក្យសុំអន្តរជាតិ និងការចុះបញ្ជីសារឡើងវិញ កម្រៃដែលត្រូវបង់ មិនមែនកម្រៃដែលគេបង្ហាញជាលក្ខណៈស្តង់ដានោះទេ តែជាកម្រៃឯកជនដែលកំណត់ដោយភាគីហត្ថលេខីនៅក្នុងសេចក្តីប្រកាស ឬក៏អាចត្រូវបានផ្លាស់ប្តូរនៅក្នុងសេចក្តីប្រកាសក្រោយៗទៀត។ តែកម្រៃនោះមិនអាចច្រើនជាងកម្រៃ ដែលភាគីហត្ថលេខីនោះមានសិទ្ធិទទួលនោះទេ។

សេចក្តីប្រកាសអាចបញ្ជាក់ថា កម្រៃឯកជនដែលត្រូវបង់ គឺបែងចែកជាពីរផ្នែក គឺផ្នែកទី១ ត្រូវបង់នៅពេលដែលធ្វើការបញ្ជូនពាក្យសុំអន្តរជាតិ និងផ្នែកទី២ ត្រូវបង់នៅកាលបរិច្ឆេទបន្ទាប់ដែលត្រូវបានគេកំណត់ ដោយយោងទៅតាមច្បាប់របស់ភាគីហត្ថលេខីដែលពាក់ព័ន្ធ។

**- កម្រៃឯកជន ៖ សម្រាប់តែពាក្យសុំអន្តរជាតិ**

រាល់ភាគីហត្ថលេខីទាំងអស់ ដែលចងដោយច្បាប់ឆ្នាំ១៩៩៩ ដែលមានការិយាល័យជាការិយាល័យត្រួតពិនិត្យ នោះភាគីហត្ថលេខី អាចធ្វើការជូនដំណឹងទៅអគ្គនាយករបស់ WIPO ថា ពាក្យសុំអន្តរជាតិដែលស្ថិតនៅក្រោមច្បាប់ឆ្នាំ១៩៦០ គឺជាកម្រៃស្តង់ដា ត្រូវបានជំនួសដោយកម្រៃឯកជន ដែលចំនួនរបស់វាត្រូវបានបង្ហាញនៅក្នុងសេចក្តីប្រកាស និងអាចត្រូវបានផ្លាស់ប្តូរនៅក្នុងសេចក្តីប្រកាសក្រោយៗទៀត។ ហើយកម្រៃដែលត្រូវបង់នោះ គឺចែកចេញជាពីរផ្នែក ដូចដែលបានរៀបរាប់ខាងលើ។ តែកម្រៃនោះមិនអាចច្រើនជាងកម្រៃដែលភាគីហត្ថលេខីនោះ មានសិទ្ធិទទួលនោះទេ។

# ជំពូកទី២ យន្តការនៃការការពារគំនូរឧស្សាហកម្មជាតិ

## ផ្នែកទី១ នីតិវិធីនៃការសុំចុះបញ្ជីគំនូរឧស្សាហកម្មជាតិ

នៅក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម រួមទាំងប្រកាសស្តីអំពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម សុទ្ធតែបានចែងតម្រូវឲ្យបំពេញតាមនីតិវិធីនៃការដាក់ពាក្យសុំ និងត្រូវតែមានឯកសារចាំបាច់មួយចំនួន ទើបអាចទទួលបាននូវកិច្ចការពារដល់អ្នកបង្កើតស្នាដៃគំនូរឧស្សាហកម្ម ព្រោះគំនូរឧស្សាហកម្ម មិនអាចទទួលបាននូវកិច្ចការពារដោយស្វ័យប្រវត្តិនោះទេ។

### កថាខណ្ឌទី១ ការរៀបចំពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម

#### ក. សមត្ថកិច្ចទទួលបន្ទុកការដាក់ពាក្យស្នើសុំ

អាជ្ញាធរដែលមានសមត្ថកិច្ចទទួលបន្ទុកលើវិស័យគំនូរឧស្សាហកម្ម គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ [27] ហើយសមត្ថកិច្ចក្នុងការអនុវត្ត គឺជាបន្ទុករបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដែលជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម[28] មានភារៈកិច្ចពិនិត្យរាល់លិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដែលបានដាក់ជូនមកនាយកដ្ឋាននេះ ដើម្បីជួយការពារកម្មសិទ្ធិបញ្ញា របស់អ្នកបង្កើតស្នាដៃគំនូរឧស្សាហកម្មឲ្យស្របតាមច្បាប់។[29]

#### ក.១ ការបង្កើត និងតួនាទីនៃនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានតួនាទី និងភារកិច្ចដូចតទៅ៖

- ទទួលពិនិត្យសំណុំលិខិតស្នើសុំ
- អនុវត្តនីតិវិធីក្នុងការផ្តល់នូវប្រកាសនីយបត្រតក្កកម្ម ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការចុះបញ្ជីគំនូរឧស្សាហកម្ម
- អនុវត្តនីតិវិធីក្នុងការគ្រប់គ្រងលើប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដែលបានផ្តល់ឲ្យ និងគំនូរឧស្សាហកម្មដែលបានចុះបញ្ជី នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំសេចក្តីព្រាងច្បាប់ នីតិវិធី និងបទបញ្ញាពាក់ព័ន្ធនឹងការចុះបញ្ជី ការគ្រប់គ្រងគំនូរបង្ហាញនៃសៀគ្វីបង្រួម និងប្រភេទថ្មីនៃពូជរុក្ខជាតិ

[27] មាត្រា៩៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[28] ប្រការ៣ នៃប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។

[29] ប្រការ២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

- ចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការតាមនីតិវិធីអំពីប្រកាសនីយបត្រតក្កកម្ម

- អនុវត្តគោលនយោបាយ និងផែនការនានា ក្នុងការពង្រឹងការការពារសិទ្ធិលើកម្មសិទ្ធិឧស្សាហកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា

- សហការរៀបចំលើគោលនយោបាយ អំពីការច្នៃប្រឌិត និងការបង្កើតថ្មី ក្នុងក្របខណ្ឌនៃការអភិវឌ្ឍបច្ចេកវិទ្យា

- អនុវត្តយន្តការជំរុញការច្នៃប្រឌិត និងបង្កើតថ្មី

- ផ្សព្វផ្សាយ និងប្រើប្រាស់ពត៌មានស្តីពីកម្មសិទ្ធិឧស្សាហកម្ម ធ្វើជាឧបករណ៍សម្រាប់ជំរុញការច្នៃប្រឌិត ការបង្កើតតក្កកម្ម ការស្រាវជ្រាវ ក្នុងគោលបំណងអភិវឌ្ឍន៍វិទ្យាសាស្ត្របច្ចេកវិទ្យា

- អនុវត្តនីតិវិធីក្នុងការចុះបញ្ជីសម្រាប់ភ្នាក់ងារ ដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំ ក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម

- សម្រុះសម្រួលវិវាទពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម

- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការ ជាមួយអង្គការជាតិ និងអន្តរជាតិ លើការងារកម្មសិទ្ធិឧស្សាហកម្ម។[30]

**ក.២ រចនាសម្ព័ន្ធនៃនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យប្រកាសនីយបត្រតក្កកម្ម
- ការិយាល័យគំនូរបង្ហាញនៃសៀគ្វីបង្រួម និងកិច្ចសន្យាអាជ្ញាប័ណ្ណ
- ការិយាល័យគំនូរឧស្សាហកម្ម
- ការិយាល័យប្រភេទថ្មីនៃពូជរុក្ខជាតិ និងជម្រុញការច្នៃប្រឌិតតក្កកម្ម
- ការិយាល័យសហប្រតិបត្តិការ និងផ្សព្វផ្សាយ។[31]

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ហើយក្នុងនោះដែរ ក៏មានការិយាល័យគំនូរឧស្សាហកម្ម ដែលជាសេនាធិការឲ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារគំនូរឧស្សាហកម្ម និងស្ថិតនៅក្រោមនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។ ការិយាល័យគំនូរឧស្សាហកម្មមានភារកិច្ចដូចជា៖

[30] ប្រការ១ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។
[31] ប្រការ៣ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។

- រៀបចំនីតិវិធី បទបញ្ញាពាក់ព័ន្ធនឹងការចុះបញ្ជីគំនូរឧស្សាហកម្ម

- ទទួលស្រាវជ្រាវ ពិនិត្យ និងវាយតម្លៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សហកម្ម

- អនុវត្តនីតិវិធីសម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្ម

- អនុវត្តនីតិវិធីលើសំណុំលិខិតស្នើសុំអន្តរជាតិ សម្រាប់គំនូរឧស្សាហកម្មតាមប្រព័ន្ធអន្តរជាតិ និងតាមប្រព័ន្ធថ្នាក់តំបន់

- គ្រប់គ្រងគំនូរឧស្សាហកម្មដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- សិក្សាស្រាវជ្រាវ ដើម្បីរៀបចំគោលនយោបាយ និងផែនការក្នុងការពង្រឹងកិច្ចការពារសិទ្ធិលើគំនូរឧស្សាហកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- សម្រុះសម្រួលវិវាទពាក់ព័ន្ធនឹងគំនូរឧស្សាហកម្ម។[32]

**ខ. ការរៀបចំសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម**

**- ការរៀបចំសំណុំឯកសារ**

សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានពាក្យសុំ គំនូសបង្ហាញ រូបថត គំនូសតាងសមស្របផ្សេងៗទៀត ដែលជារូបតំណាងនៃវត្ថុ ដែលបង្កើតឡើងពីគំនូរឧស្សាហកម្ម និងការចង្អុលបង្ហាញអំពីប្រភេទនៃផលិតផល ដែលគំនូរឧស្សាហកម្មត្រូវយកមកប្រើប្រាស់ ហើយដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី(ដែលជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម) និងត្រូវបង់កម្រៃទៅតាមការកំណត់។[33]

ពាក់ព័ន្ធទៅនឹងគំនូសតាង ឬរូបសំណាកតាងឲ្យរូបពិត ត្រូវតែបំពេញទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- សំណុំលិខិតស្នើសុំត្រូវតែភ្ជាប់មកជាមួយនូវ៖
  - ✓ ក្រាហ្វិចតាងចំនួន ០៤ ច្បាប់ ឬគំនូសបង្ហាញ ឬគំនូសចម្លងតាមចំនួន ០៤ ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្មគឺជាទម្រង់ពីរខ្នាត ឬ
  - ✓ ក្រាហ្វិចតាងចំនួន ០៤ ច្បាប់ ឬគំនូសបង្ហាញ ឬគំនូសចម្លងតាមនៃផ្នែកខុសគ្នានីមួយៗ របស់គំនូរឧស្សាហកម្មចំនួន ០៤ ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្មនោះជាទម្រង់បីខ្នាត
  - ✓ និងគំនូរនោះត្រូវតែបោះពុម្ពនៅលើសន្លឹកក្រដាសដែលមិនត្រូវលើសពីទំហំ ១៧.០ ស.ម × ២៦.២ ស.ម ឡើយ

[32] ប្រការ២ និងប្រការ៤ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។

[33] ប្រការ៥ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

- ➢ រូបសំណាកតាំងអោយរូបពិតរបស់គំនូរឧស្សាហកម្មមិនត្រូវមានខ្នាតធំលើសពីទំហំ ២០ ស.ម × ២០ ស.ម ឡើយ។ ក្រាហ្វិចតាងគំនូសបង្ហាញ ឬគំនូសចម្លងតាមនៃគំនូសឧស្សាហកម្មទាំងនោះ ត្រូវគូសនៅលើក្រដាសរឹងដែលមានទំហំA4 ចំនួន០៤ សន្លឹក។ គំនូសបង្ហាញ និងគំនូសចម្លងតាម ត្រូវគូសដោយទឹកខ្មៅ ពណ៌ខ្មៅ។[34]
- ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមពាក្យសុំ **គំរូលេខ ១គឧ**។
- ត្រូវបញ្ជាក់អំពីឈ្មោះ អាសយដ្ឋាន សញ្ជាតិ ទីលំនៅរបស់អ្នកដាក់ពាក្យស្នើសុំម្នាក់ៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំម្នាក់ៗនោះ។ ការបញ្ជាក់អំពីឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋានត្រូវបញ្ជាក់ដូចខាងក្រោម៖
  - ✓ ត្រង់ចំណុចឈ្មោះរបស់រូបវន្តបុគ្គល ត្រូវបញ្ជាក់ដោយនាមត្រកូល នាមខ្លួន សញ្ជាតិ និងអាសយដ្ឋានរបស់បុគ្គលនោះ រីឯឈ្មោះរបស់នីតិបុគ្គលត្រូវបញ្ជាក់ដោយឈ្មោះជាផ្លូវការរបស់នីតិបុគ្គលនោះ
  - ✓ ត្រង់ចំណុចសញ្ជាតិត្រូវបញ្ជាក់ឈ្មោះប្រទេសដែលបុគ្គលនោះជាជនជាតិ។ ចំណែកឯនីតិបុគ្គលវិញ ត្រូវបញ្ជាក់ពីឈ្មោះប្រទេស ដែលនីតិបុគ្គលនោះត្រូវបានបង្កើតឡើង ក្រោមច្បាប់នៃប្រទេសនោះ
  - ✓ ត្រង់ចំណុចអាសយដ្ឋាន របស់អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់តាមវិធីណាមួយ ដើម្បីជាតម្រូវការធម្មតា សម្រាប់ការបញ្ជូនឯកសារតាមប្រៃសនីយ៍ឲ្យបានឆាប់រហ័ស ទៅដល់អាសយដ្ឋានដែលបានបញ្ជាក់នោះ ហើយក្នុងករណីណាមួយក៏ដោយ ក៏ត្រូវបញ្ជាក់ផងដែរ នូវអង្គភាពរដ្ឋបាលដែលពាក់ព័ន្ធ រួមទាំងលេខផ្ទះប្រសិនបើមាន លេខទូរស័ព្ទ អាសយដ្ឋានអ៊ីម៉ែល និងលេខទូរសារផងដែរ
  - ✓ ត្រង់ចំណុចទីលំនៅត្រូវបញ្ជាក់ឈ្មោះប្រទេសដែលបុគ្គលនោះមានទីលំនៅជាប់លាប់
  - ✓ គ្រប់អ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្មទាំងអស់ត្រូវផ្តល់ឲ្យមន្ត្រីកាន់កាប់បញ្ជី នូវអាសយដ្ឋានសម្រាប់ទំនាក់ទំនង ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងនៃសំណុំលិខិតស្នើសុំរបស់គាត់។[35]

ប្រសិនបើក្នុងករណីដែលមានការផ្លាស់ប្តូរឈ្មោះ សញ្ជាតិ និងអាសយដ្ឋាន ការ

[34] ប្រការ៦ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

[35] ប្រការ៨ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

ផ្លាស់ប្តូរនេះ ត្រូវអនុវត្តទៅតាមពាក្យសុំ **គំរូលេខ ៤គខ** ដោយមានលក្ខខណ្ឌដូចខាងក្រោម៖

- ✓ សំណើសុំដោយម្ចាស់ ឬអ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដើម្បីផ្លាស់ប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទងដូចដែលបានកត់ត្រាចំពោះគំនូរឧស្សាហកម្ម ឬក្នុងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មរបស់ខ្លួននោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ
- ✓ មុននឹងអនុវត្តទៅតាមសំណើក្នុងការប្តូរឈ្មោះ ឬសញ្ជាតិ មន្ត្រីកាន់កាប់បញ្ជីអាចតម្រូវឲ្យអ្នកដាក់ពាក្យសុំផ្តល់នូវភស្តុតាងសមស្របពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរនេះ
- ✓ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណើនោះសមស្របហើយ មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តការផ្លាស់ប្តូរនោះលើគំនូរឧស្សាហកម្ម ឬក៏លើសំណុំលិខិតស្នើសុំការចុះបញ្ជីគំនូរឧស្សាហកម្ម ហើយក្នុងករណីដែលឈ្មោះ សញ្ជាតិ ឬអាសយដ្ឋាន ត្រូវកត់ត្រាចូលក្នុងបញ្ជីរួចហើយ បញ្ជីនោះក៏ត្រូវកត់ត្រានៃការប្តូរនេះ ឲ្យបានត្រឹមត្រូវទៀតផង។ [36]

- ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំជាអ្នកបង្កើតស្នាដៃ ពាក្យស្នើសុំនោះត្រូវតែភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអានុភាពនោះ។ ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំពុំមែនជាម្ចាស់ស្នាដៃទេនោះ ពាក្យស្នើសុំនោះត្រូវតែមានបញ្ជាក់អំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកបង្កើតស្នាដៃ ពោលគឺអ្នកគូរគំនូរឧស្សាហកម្មម្នាក់ៗ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារ ដែលបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យស្នើសុំ ចំពោះការចុះបញ្ជីគំនូរឧស្សាហកម្មនោះផង។
- ប្រសិនបើអ្នកដាក់ពាក្យស្នើសុំ ត្រូវតំណាងដោយភ្នាក់ងារ ពាក្យស្នើនោះត្រូវតែបញ្ជាក់ផងដែរអំពីឈ្មោះនិងអាសយដ្ឋានរបស់ភ្នាក់ងារនោះ។ ការចាត់តាំងភ្នាក់ងារតំណាង ត្រូវធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិ ដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំ ឬដោយអ្នកដាក់ពាក្យស្នើសុំម្នាក់ៗ ប្រសិនបើមានអ្នកដាក់ពាក្យសុំលើសពីមួយនាក់។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាងនោះ ត្រូវចាត់ទុកថាជាអាសយដ្ឋានទាក់ទង ដើម្បីបញ្ជូនដំណឹងទៅបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ដែលបានចាត់តាំងភ្នាក់ងារនោះ សម្រាប់គោលបំណងទាំងឡាយ ដែលពាក់ព័ន្ធនឹង

[36] ប្រការ៩ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

ច្បាប់ ប្រកាសនានារបស់ក្រសួង និងបទបញ្ញត្តិពាក់ព័ន្ធដទៃទៀត។ ជាមួយគ្នានេះដែរ លិខិតដែលប្រគល់សិទ្ធិឲ្យទៅភ្នាក់ងារតំណាង ត្រូវភ្ជាប់មកជាមួយផងដែរនូវសំណុំលិខិតស្នើសុំ ឬដែលអាចប្រគល់អោយក្នុងរយៈពេល ០២ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំនោះ។ លក្ខខណ្ឌមួយចំនួនទៀត ដែលពាក់ព័ន្ធទៅនឹងភ្នាក់ងារតំណាងនេះ ក៏បានលើកឡើងនៅក្នុងចំណុច "ក" ស្តីពីអ្នកតំណាង ឬភ្នាក់ងារទទួលសិទ្ធិចុះបញ្ជីគំនូរឧស្សាហកម្ម រួចមកហើយផងដែរ។[37]

- ការស្នើសុំដោយអ្នកដាក់ពាក្យសុំ សម្រាប់ពន្យារពេល នៃការបោះពុម្ពផ្សាយគំនូរឧស្សាហកម្ម ឬគំនូរដែលមាននៅក្នុងសំណុំលិខិតស្នើសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់ពីរយៈពេលនៃការពន្យារនោះ តាមទម្រង់នៃពាក្យសុំ **គំរូលេខ ៧ គឌ**។ នៅក្នុងករណីនៃការសុំពន្យារពេលចុះផ្សាយនេះ មន្ត្រីកាន់កាប់បញ្ជីមិនត្រូវបើកបង្ហាញជាសាធារណៈនូវគំនូរឧស្សាហកម្ម ឬឯកសារណាមួយ ដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំនោះទេ។ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះផ្សាយ ដោយបញ្ជាក់អំពី ការសុំពន្យារការចុះផ្សាយគំនូរឧស្សាហកម្មនេះ និងពត៌មានដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់គំនូរឧស្សាហកម្ម ព្រមទាំងត្រូវបញ្ជាក់ពីកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ រយៈពេលនៃការពន្យារ និងចំណុចសំខាន់ៗផ្សេងទៀតដែលបានកំណត់។[38] ការពន្យារពេលនៃការចុះផ្សាយគំនូរឧស្សាហកម្ម ដែលបានលើកឡើងខាងលើនេះ មិនត្រូវឲ្យលើសពីរយៈពេល ១២ខែ បានឡើយ។[39] នៅពេលផុតកំណត់នៃការពន្យារពេលចុះផ្សាយ មន្ត្រីកាន់កាប់បញ្ជី ត្រូវចុះផ្សាយគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចនោះ។ នៅក្នុងអំឡុងពេលនៃការពន្យារពេលលើការចុះផ្សាយនេះ ការប្តឹងអំពីការរំលោភលើគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីរួចហើយ អាចធ្វើទៅបានលុះត្រាតែអាចកំណត់បានថា បុគ្គលដែលត្រូវចោទប្រកាន់ការរំលោភនោះ បានដឹងពត៌មានដែលមាននៅក្នុងបញ្ជី និងមាននៅក្នុងឯកសារពាក់ព័ន្ធនឹងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះ។

**- ភាសានៃឯកសារ និងការបកប្រែ**

រាល់សំណុំលិខិតស្នើសុំ ឬឯកសារដែលដាក់ឲ្យចុះបញ្ជីគំនូរឧស្សាហកម្ម នៅនាយកដ្ឋាន

[37] ប្រការ១៨ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

[38] ប្រការ១០៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[39] ប្រការ៩៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

ទទួលបន្ទុកការចុះបញ្ជី ឬមន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើជាភាសាខ្មែរ។ ក្នុងករណីដែលលិខិតស្នើសុំដាក់ជូនមន្ត្រីកាន់កាប់បញ្ជីនោះ ជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ហើយដាក់សម្រាប់គោលបំណងនៃការស្រាវជ្រាវ និងពិនិត្យ ត្រូវបកប្រែជាភាសាអង់គ្លេស។ ក្នុងករណីដែលសំណុំលិខិតស្នើសុំ សរសេរជាភាសាបរទេសក្រៅពីភាសាខ្មែរ ហើយដាក់សម្រាប់គោលបំណងនៃការវិនិច្ឆ័យការការពារ និងការអនុវត្តច្បាប់ ត្រូវសរសេរជាភាសាខ្មែរ និងត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ០៦ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី។[40]

**- ការចុះហត្ថលេខា**

ឯកសារដែលរៀបចំសម្រាប់ចុះហត្ថលេខាជូសមុខអោយ ឬក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ក្រុមហ៊ុន និងដៃគូទាំងអស់ជាឈ្មោះពេញ ហើយត្រូវបានចុះហត្ថលេខាដោយអ្នកទាំងអស់នោះ ឬដោយដៃគូណាមួយ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការចុះហត្ថលេខា ដោយបញ្ជាក់ថា ដៃគូនោះ ចុះហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬក៏ចុះហត្ថលេខាដោយបុគ្គលណាម្នាក់ផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីបានទទួលស្គាល់ថា បុគ្គលនោះ ត្រូវបានអនុញ្ញាតឲ្យចុះហត្ថលេខាលើឯកសារនោះបាន។ ឯកសារដែលបានរៀបចំដើម្បីចុះហត្ថលេខាជូសមុខឲ្យ ឬក្នុងនាម**អង្គភាពសាជីវកម្ម** ត្រូវចុះហត្ថលេខាដោយនាយក ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ណាមួយផ្សេងទៀត របស់អង្គភាពសាជីវកម្មនោះ ឬដោយបុគ្គលណាមួយផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាត ឲ្យចុះហត្ថលេខាលើឯកសារ និងប្រថាប់ត្រារបស់អង្គភាពសាជីវកម្មនោះផង។ ឯកសារដែលរៀបចំឡើងដើម្បីចុះហត្ថលេខាជូសមុខឲ្យ ឬក្នុងនាម**សមាគម**នៃបុគ្គលច្រើននាក់ អាចត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ដើម្បីចុះហត្ថលេខា។ ក្នុងករណដែលយល់ថាចំបាច់ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើសុំឲ្យផ្តល់ភស្តុតាងនៃការចុះហត្ថលេខា។[41]

**គ. ការចុះលេខ ការគូសសញ្ញា និងការត្រួតពិនិត្យលើទម្រង់ពាក្យសុំ**

នៅពេលដែលមន្ត្រីកាន់កាប់បញ្ជី ទទួលបានពាក្យសុំចុះបញ្ជីពីបុគ្គលដែលស្នើសុំ មន្ត្រីកាន់កាប់បញ្ជីនឹងចុះកាលបរិច្ឆេទជាក់ស្តែងនៃការទទួលពាក្យសុំ។ ការចុះលេខសំណុំលិខិតស្នើសុំត្រូវផ្តុំដោយអក្សរ "កជ" បន្ទាត់ទ្រេត "/" អក្សរ "គឧ" បន្ទាត់ទ្រេត "/" លេខពីរខ្ទង់ចុងក្រោយនៃឆ្នាំដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល។ មន្ត្រីកាន់កាប់បញ្ជីនឹងចុះកាលបរិច្ឆេទសុំចុះបញ្ជីជាក់ស្តែង

[40] ប្រការ៧ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

[41] ប្រការ១០ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

នៅពេលដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា រាល់ឯកសារកែតម្រូវណាមួយ ឬឯកសារដែលបានដាក់ក្រោយផ្សេងទៀត ចាំបាច់សម្រាប់ការដាក់ពាក្យស្នើសុំ។

បន្ទាប់ពីការចុះហត្ថលេខាខាងលើ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យថា សំណុំលិខិតស្នើសុំនោះបានបំពេញត្រឹមត្រូវតាមការតម្រូវ នៃការរៀបចំសំណុំឯកសារចុះបញ្ជីហើយ ឬនៅ។ រាល់ខ្លឹមសារ ឬលក្ខខណ្ឌដែលមិនបានបំពេញនោះ មន្ត្រីកាន់កាប់បញ្ជីអាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឲ្យធ្វើការកែតម្រូវដែលមានរយៈពេល ០២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ជាមួយនឹងការបង់កម្រៃតាមការកំណត់។ ប្រសិនអ្នកដាក់ពាក្យស្នើសុំនោះ មិនបានអនុវត្តត្រឹមត្រូវតាមការអញ្ជើញឲ្យធ្វើការកែតម្រូវនូវកំហុស ដែលមាននៅក្នុងសំណុំលិខិតស្នើសុំនោះ ឬអ្នកដាក់ពាក្យស្នើសុំបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី នូវការកែតម្រូវរួចហើយក៏ដោយ តែបើសិនមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌខាងលើ មិនត្រូវបានបំពេញត្រឹមត្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធលើសំណុំលិខិតស្នើសុំ ហើយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ និងបញ្ជាក់ពីមូលហេតុ។ ការបដិសេធលើសំណុំលិខិតស្នើសុំនេះ មិនមានឥទ្ធិពលដល់កាលបរិច្ឆេទសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំឡើយ គឺនៅតែរក្សាសុពលភាពដដែល។ [42] មន្ត្រីកាន់កាប់បញ្ជីត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅកាន់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី អំពីការសម្រេចយល់ព្រមចុះបញ្ជី ឬបដិសេធ តែបើសម្រេចថា យល់ព្រមចុះបញ្ជីសំណុំលិខិតស្នើសុំ នោះមន្ត្រីកាន់កាប់បញ្ជី ត្រូវឲ្យអ្នកដែលដាក់ពាក្យសុំ បង់កម្រៃការចុះបញ្ជីក្នុងរយៈពេល ០១ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង។[43] អ្នកដាក់ពាក្យស្នើសុំ អាចដកហូតយកសំណុំលិខិតស្នើសុំទៅវិញបាន តាម **គំរូលេខ ៣គឧ** ឬទទួលយកការកែតម្រូវលើសំណុំលិខិតស្នើសុំតាម **គំរូលេខ ៥គឧ** បានដោយៈ

- ធ្វើសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលបានដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ហើយដែលបានចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំម្នាក់ៗ។
- កម្រៃពាក់ព័ន្ធនឹងការដាក់ពាក្យនៃសំណុំលិខិតស្នើសុំ មិនត្រូវបានប្រគល់ជូនវិញនោះទេ បើសំណុំលិខិតស្នើសុំនោះត្រូវបានដកហូតយកទៅវិញ។
- ការកែតម្រូវណាមួយ នៃសំណុំលិខិតស្នើសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។
- សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដែលបានដកហូតយកទៅវិញ ឬបានបោះបង់ចោល ឬក៏ត្រូវបានបដិសេធទទួលការចុះបញ្ជី ត្រូវអនុវត្តទៅតាមបទបញ្ញត្តិនៃមាត្រា៥ (គ)

[42] មាត្រា១០១(២) និងមាត្រា៣៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩៥ និងមាត្រា៩៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[43] ប្រការ១៤ នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

(៤)[44] ស្តីពីសិទ្ធិអាទិភាពនៃអនុសញ្ញាទីក្រុងប៉ារីស តាមការសមស្រប។[45]

**ឃ. កាលបរិច្ឆេទអាទិភាព**

អ្នកដាក់ពាក្យស្នើសុំ ត្រូវធ្វើសេចក្តីអះអាងបញ្ជាក់អំពីកាលបរិច្ឆេទអាទិភាពនោះ ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម មានកាលបរិច្ឆេទអាទិភាព។ ការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបញ្ជាក់អំពី៖

- កាលបរិច្ឆេទនៃការចុះបញ្ជីរបស់សំណុំលិខិតស្នើសុំដំបូង

- លេខនៃសំណុំលិខិតស្នើសុំដំបូង។ បើក្នុងករណីដែលដាក់សេចក្តីប្រកាសអាទិភាពនោះ ពុំមានលេខនៃសំណុំលិខិតស្នើសុំនោះទេ លេខនេះត្រូវផ្តល់ឲ្យមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ០៣ ខែ ក្រោយកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ

- និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលត្រូវបានដាក់ចំពោះសំណុំលិខិតស្នើសុំលើកដំបូង។ សំណុំលិខិតស្នើសុំលើកដំបូង មិនទាន់បានកំណត់នូវនិមិត្តសញ្ញាក្នុងការដាក់នូវសេចក្តីប្រកាសអាទិភាពនៅឡើយទេ។ អ្នកដាក់ពាក្យស្នើសុំ ត្រូវតែថ្លែងបញ្ជាក់អំពីហេតុការណ៍នេះ នៅក្នុងសេចក្តីប្រកាសនោះ ហើយត្រូវផ្តល់និមិត្តសញ្ញាចំណាត់ថ្នាក់អន្តរជាតិនោះទៅមន្ត្រីកាន់កាប់បញ្ជីឲ្យបានយ៉ាងឆាប់រហ័ស ខណៈពេលដែលត្រូវបានកំណត់

- ឈ្មោះប្រទេសដែលបានទទួលការចុះបញ្ជីនៃសំណុំលិខិតស្នើសុំដំបូង ឬឈ្មោះប្រទេសមួយ ឬច្រើនដែលបានទទួលការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំនោះ ក្នុងករណីដែលសំណុំលិខិតស្នើសុំដំបូងនោះ ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬសំណុំលិខិតស្នើសុំថ្នាក់អន្តរជាតិ

- ឈ្មោះការិយាល័យដែលបានទទួលការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំលើកដំបូង ករណីដែលសំណុំលិខិតស្នើសុំលើកដំបូងនោះ ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬសំណុំលិខិតស្នើសុំថ្នាក់អន្តរជាតិ

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី អាចកែតម្រូវលើអត្ថបទនៃសេចក្តីប្រកាសអាទិភាព ដែលភ្ជាប់ជាមួយសំណុំពាក្យសុំចុះបញ្ជី។[46]

ចំណែកការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ឯកសារចម្លង ដោយបញ្ជាក់ឲ្យត្រឹមត្រូវតាមច្បាប់ដើម នៃសំណុំលិខិតស្នើសុំលើកដំបូង ក្នុងរយៈ

---

[44] Article 4 [...]. (D) (4): No other formalities may be required for the declaration of priority at the time of filing the application. Each country of the Union shall determine the consequences of failure to comply with the formalities prescribed by this Article, but such consequences shall in no case go beyond the loss of the right of priority. (5) [...]

[45] ប្រការ១២ (៤) នៃប្រកាសលេខ៧០៧ ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

[46] មាត្រា២៧ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

ពេល ០៣ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំ ដោយមន្ត្រីកាន់កាប់បញ្ជី។ ក្នុងករណីបានប្រគល់ឯកសារចម្លងរួចហើយ សម្រាប់ការដាក់សំណុំលិខិតផ្សេងទៀតនោះ អ្នកដាក់ពាក្យសុំអាចឆ្លើយតបដោយធ្វើសេចក្តីយោង ទៅលើការដាក់លិខិតស្នើសុំផ្សេងទៀតនោះ។ តែបើសំណុំលិខិតស្នើសុំសរសេរជាភាសាផ្សេងក្រៅពីភាសាខ្មែរ អ្នកដាក់ពាក្យសុំត្រូវផ្តល់សំណុំលិខិតស្នើសុំបកប្រែ ក្នុងរយៈពេល ០៦ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំ របស់មន្ត្រីកាន់កាប់បញ្ជី។ ទោះបីគ្មានការស្នើសុំឲ្យផ្តល់នូវលិខិតខាងលើក៏ដោយ ក៏ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីដែរ។[47]

**កថាខណ្ឌទី២ ដំណើរប្រព្រឹត្តទៅនៃគំនូរឧស្សាហកម្ម**

**ក. ដំណើរការចុះបញ្ជីគំនូរឧស្សាហកម្ម**

**ក.១ នីតិវិធីរបស់មន្ត្រីកាន់កាប់បញ្ជី**

នៅពេលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណុំលិខិតស្នើសុំ បានបំពេញត្រឹមត្រូវគ្រប់លក្ខខណ្ឌហើយ នោះមន្ត្រីកាន់កាប់បញ្ជី ត្រូវចុះបញ្ជីគំនូរឧស្សាហកម្ម ចុះផ្សាយសេចក្តីបញ្ជាក់អំពីការចុះបញ្ជី និងដំណើរការចេញវិញ្ញាបនបត្រចុះបញ្ជីឲ្យអ្នកដាក់ពាក្យសុំ។ មន្ត្រីកាន់កាប់បញ្ជីមាននីតិវិធី ក្នុងការអនុវត្តចុះបញ្ជីគំនូរឧស្សាហកម្មដូចខាងក្រោមៈ

- មន្ត្រីកាន់កាប់បញ្ជីត្រូវចុះលេខ សម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្មនីមួយៗ តាមលំដាប់លំដោយនៃការចុះបញ្ជី

- ការចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវរួមបញ្ចូលការបង្ហាញអំពីគំនូរឧស្សាហកម្ម និងត្រូវបញ្ជាក់អំពីៈ

  - លេខនៃគំនូរឧស្សាហកម្ម
  - ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់ ដែលបានចុះបញ្ជីរួចហើយ
  - ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារតំណាង ប្រសិនបើមាន
  - ឈ្មោះ និងអាសយដ្ឋានរបស់អ្នកបង្កើត លើកលែងតែករណីដែលអ្នកបង្កើតស្នើសុំ មិនឲ្យដាក់ឈ្មោះរបស់គេនៅក្នុងការចុះបញ្ជី
  - ប្រសិនបើកាលបរិច្ឆេទអាទិភាពត្រូវបានអះអាង និងសេចក្តីអះអាងត្រូវបានទទួលយក
  - កាលបរិច្ឆេទអាទិភាព និងប្រទេសមួយ ឬប្រទេសច្រើន ដែលបានទទួលការសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំដំបូង និង
  - ប្រភេទនៃផលិតផលដែលគំនូរឧស្សាហកម្មត្រូវយកទៅប្រើប្រាស់។[48]

[47] មាត្រា២៨ និងមាត្រា២៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[48] ប្រការ១៥ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។

**ក.២ ការចុះបញ្ជីសារជាថ្មី**

ក្រោយពីទទួលបានការការពារ គំនូរឧស្សាហកម្មនោះ មានសុពលភាពរយៈពេល ៥ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី។ ហើយការចុះបញ្ជីនេះ អាចធ្វើសារឡើងវិញបានពីរដង (២ដង) ជាប់ៗគ្នា ហើយដែលម្តងៗមានរយៈពេល ៥ឆ្នាំ ដូចគ្នា[49] សរុបរយៈពេលផ្តល់កិច្ចការពារទាំងអស់ គឺ ១៥ឆ្នាំ។ ម្ចាស់គំនូរឧស្សាហកម្ម ត្រូវបង់កម្រៃបន្តសុពលភាពតាមការកំណត់ ដូចមានចែងក្នុងតារាងនៃការបង់កម្រៃ ចំពោះការចុះបញ្ជីគំនូរឧស្សាហកម្មរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ការចុះបញ្ជីសារជាថ្មីនៃគំនូរឧស្សាហកម្មត្រូវអនុវត្តដូចខាងក្រោម៖

- ការចុះបញ្ជីសារឡើងវិញ អាចត្រូវធ្វើឡើងដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយភ្នាក់ងារតំណាងរបស់គាត់ ក្នុងរយៈពេល ០៦ ខែ មុនការផុតកំណត់នៃការចុះបញ្ជី

- ការចុះបញ្ជីសារឡើងវិញ ត្រូវធ្វើឡើងដោយមានការបង់កម្រៃ ក្នុងការចុះបញ្ជីសារឡើងវិញ ក្នុងរយៈពេល ០៦ខែ មុនការផុតកំណត់នៃការចុះបញ្ជី ឬក្នុងរយៈពេលអនុគ្រោះចំនួន ០៦ ខែ ដោយមានការបង់កម្រៃបន្ថែមលើការយឺតយ៉ាវ

- ការចុះបញ្ជីសារឡើងវិញនៃគំនូរឧស្សាហកម្មត្រូវកត់ត្រានៅក្នុងបញ្ជី និងត្រូវបោះពុម្ពផ្សាយ

- មន្ត្រីកាន់កាប់បញ្ជីត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីសារឡើងវិញ ជូនដល់ម្ចាស់ដែលបានចុះបញ្ជី ក្នុងនោះត្រូវមាន៖

- លេខចុះបញ្ជីនៃគំនូរឧស្សាហកម្ម
- កាលបរិច្ឆេទនៃការចុះបញ្ជីសារឡើងវិញ និងកាលបរិច្ឆេទនៃការផុតកំណត់
- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់ដែលបានចុះបញ្ជី និង
- ការបញ្ជាក់អំពីប្រភេទនៃផលិតផលដែលគំនូរឧស្សាហកម្មត្រូវបានចុះបញ្ជីរួចហើយ

**បញ្ជាក់៖** បុគ្គលទាំងឡាយដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចស្នើទៅតុលាការដែលមានសមត្ថកិច្ច សុំមោឃភាពនូវការចុះបញ្ជីគំនូរឧស្សាហកម្មបាន ប្រសិនបើបុគ្គលដែលបានស្នើសុំនោះ បានបង្ហាញនូវភស្តុតាងទៅតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់ ហើយការអស់សុពលភាពនៃគំនូរឧស្សាហកម្មនោះ គឺគិតចាប់ពីថ្ងៃចុះបញ្ជី និងរាល់ការសម្រេចនានា របស់តុលាការមានសមត្ថកិច្ចត្រូវជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជី ដើម្បីឲ្យមន្ត្រីកាន់កាប់បញ្ជី អាចចុះកំណត់ត្រា និងធ្វើការផ្សព្វផ្សាយពីការសម្រេចនោះ ឲ្យឆាប់តាមដែលអាចធ្វើទៅបាន។[50]

---

[49] មាត្រា១០៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[50] មាត្រា១១០ ដល់មាត្រា១១៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរ

### ខ. ការចុះផ្សាយគំនូរឧស្សាហកម្មក្នុងព្រឹត្តិបត្រ

ក្នុងករណីបើពិនិត្យឃើញថា គំនូរឧស្សាហកម្មមួយបានបំពេញត្រឹមត្រូវ ទៅតាមលក្ខខណ្ឌទាំងឡាយដែលច្បាប់កំណត់ នោះមន្ត្រីកាន់កាប់បញ្ជី ត្រូវចុះបញ្ជីគំនូរឧស្សាហកម្មឲ្យ និងចុះផ្សាយសេចក្តីបញ្ជាក់អំពីការចុះបញ្ជី និងដំណើរការចេញវិញ្ញាបនបត្រចុះបញ្ជីឲ្យអ្នកដាក់ពាក្យសុំនោះ។[51] ហើយត្រូវចុះផ្សាយក្នុងករណីបើមិនបានកែតម្រូវ ឬមិនបានបំពេញគ្រប់លក្ខខណ្ឌក្នុងការចុះបញ្ជី។ ការចុះផ្សាយអាចធ្វើតាមសំណើ របស់ម្ចាស់គំនូរឧស្សាហកម្ម ដែលចុះផ្សាយទាក់ទងតែនឹងគំនូរឧស្សាហកម្មមួយផ្នែក នៃពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម។

មន្ត្រីកាន់កាប់បញ្ជី មិនត្រូវបើកបង្ហាញជាសាធារណៈ នូវគំនូរ ឬឯកសារណាមួយ ដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំ ប្រសិនបើមានពាក្យសុំពន្យារចុះបញ្ជីគំនូរឧស្សាហកម្ម។ ប៉ុន្តែមន្ត្រីកាន់កាប់បញ្ជី ត្រូវចុះផ្សាយបញ្ជាក់អំពី ការសុំពន្យារពេលចុះផ្សាយគំនូរឧស្សាហកម្ម និងពត៌មានបញ្ជាក់ពីអត្តសញ្ញាណ របស់ម្ចាស់គំនូរឧស្សាហកម្ម កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ រយៈពេលនៃការសុំពន្យារ និងចំណុចសំខាន់ៗផ្សេងទៀតដែលបានកំណត់។ ការសុំពន្យារចុះផ្សាយគំនូរឧស្សាហកម្ម មិនត្រូវលើសពី ១២ខែ គិតពីកាលបរិច្ឆេទសុំចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាព។[52] មន្ត្រីកាន់កាប់បញ្ជី ត្រូវតែចុះផ្សាយគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីរួចហើយ នៅពេលផុតកំណត់ការពន្យារចុះផ្សាយ។ គ្រប់ការធ្វើអាជីវកម្មទាំងឡាយ ត្រូវតែមានការអនុញ្ញាតពីម្ចាស់ដើមនៃគំនូរឧស្សាហកម្មនោះ។ ម្ចាស់គំនូរឧស្សាហកម្មអាចដាក់ពាក្យប្តឹងទៅតុលាការ ចំពោះជនទាំងឡាយណា ដែលបានរំលោភលើគំនូរឧស្សាហកម្ម នៅក្នុងអំឡុងពេលពន្យារចុះផ្សាយ។ លុះត្រាតែអាចកំណត់បានថា ជនដែលត្រូវចោទប្រកាន់ថា បានរំលោភលើគំនូរឧស្សាហកម្មនោះពុំបានដឹងពីពត៌មានដែលមាននៅក្នុងបញ្ជី និងឯកសារពាក់ព័ន្ធ ទៅនឹងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះ។

## ផ្នែកទី២ អត្ថប្រយោជន៍ និងសិទ្ធិដែលទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ

### កថាខណ្ឌទី១ អត្ថប្រយោជន៍ និងសិទ្ធិដែលទទួលបានពីចុះបញ្ជីគំនូរឧស្សាហកម្ម

#### ក. អត្ថប្រយោជន៍ និងសិទ្ធិដែលទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម

ការចុះបញ្ជីគំនូរឧស្សាហកម្ម បានផ្តល់ផលប្រយោជន៍ជាច្រើន ដល់ម្ចាស់គំនូរឧស្សាហកម្ម និងផ្តល់នូវការការពារចំពោះគំនូរឧស្សាហកម្ម ដែលកិច្ចការពារនេះ បានជួយជម្រុញអោយមានការ

[51] មាត្រា១០៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[52] មាត្រា៩៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

បង្កើតថ្មី នៅក្នុងផ្នែកឧស្សាហកម្ម ផ្នែកផលិតកម្ម និងរួមចំណែកក្នុងការពង្រីកនូវសកម្មភាពពាណិជ្ជកម្ម និងបង្កើនសក្កានុពលនីហរណកម្មនៃផលិតផលជាតិ។ ហើយកិច្ចការពារនេះ ក៏បានជួយនៅក្នុងផ្នែកពាណិជ្ជកម្មដែរ ដោយជួយបង្កើនអោយមាននូវ ការប្រកួតប្រជែងគ្នានៅលើវិស័យពាណិជ្ជកម្ម និងនាំមកនូវផលប្រយោជន៍បន្ថែមទៀតដូចជា៖

- ការចុះបញ្ជីគំនូរឧស្សាហកម្ម ម្ចាស់សិទ្ធិអាចការពារគំនូររបស់ខ្លួនពីការលួចចម្លង និងការក្លែងបន្លំពីសំណាក់ដៃគូប្រកួតប្រជែងរបស់ខ្លួន មានន័យថា ជួយពង្រឹងនូវការប្រកួតប្រជែង អោយកាន់តែមានភាពល្អប្រសើរឡើង។

- ការចុះបញ្ជីគំនូរឧស្សាហកម្ម ដែលមានតម្លៃនាំឲ្យម្ចាស់សិទ្ធិ ទទួលបានមកវិញនូវការវិនិយោគប្រកបដោយភាពយុត្តិធម៌ នៅក្នុងការបង្កើត និងការលក់ផលិតផលរបស់ខ្លួន បានសេចក្តីថា ជួយបង្កើនប្រាក់ចំណេញដល់ម្ចាស់សិទ្ធិ។

- គំនូរឧស្សាហកម្ម គឺជាទ្រព្យពាណិជ្ជកម្ម (Business assets) ដែលអាចបង្កើននូវតម្លៃពាណិជ្ជកម្មទៅឲ្យក្រុមហ៊ុន ក៏ដូចជាផលិតផលរបស់ក្រុមហ៊ុននោះ។ គំនូរមួយកាន់តែល្បី នាំឲ្យក្រុមហ៊ុននោះ ក៏កាន់តែមានកេរ្តិ៍ឈ្មោះ។

- ការចុះបញ្ជីគំនូរឧស្សាហកម្ម ជំរុញឲ្យមានការប្រកួតប្រជែងដោយភាពយុត្តិធម៌ និងការធ្វើពាណិជ្ជកម្មដោយភាពស្មោះត្រង់ ដែលជួយបង្កើននូវការផលិតផលិតផល ដែលមានការរចនាម៉ូតផ្សេងៗពីគ្នា។

ចំណែកសិទ្ធិដែលម្ចាស់គំនូរឧស្សាហកម្ម ទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម គឺសិទ្ធិផ្តាច់មុខលើគំនូររបស់ខ្លួន តាមការការពារដោយវិញ្ញាបនបត្រចុះបញ្ជីគំនូរឧស្សាហកម្ម។ បុគ្គលដទៃដែលមិនមែនជាម្ចាស់លើគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីហើយ ពេលធ្វើអាជីវកម្មត្រូវតែមានការយល់ព្រមពីម្ចាស់ដើម។[53] ការធ្វើអាជីវកម្មនៃគំនូរឧស្សាហកម្ម ដែលបានទទួលនូវកិច្ចការពារដោយវិញ្ញាបនបត្រចុះបញ្ជីគំនូរឧស្សាហកម្ម អាចស្តែងចេញជារូបភាពនៃសកម្មភាពដូចជា៖

- **ការផលិត** មានន័យថា ម្ចាស់កម្មសិទ្ធិលើគំនូរឧស្សាហកម្ម អាចផលិតចេញនូវផលិតផលផ្សេងៗ ពីគំនូររបស់គាត់ ដើម្បីយកមកធ្វើអាជីវកម្មលើទីផ្សារ។ ឧទាហរណ៍ គំនូររចនាម៉ូតអំពីតុ នាំឲ្យការផលិតក៏បានម៉ូតតុដូចអ្វីដែលគេរចនាទុកជាគំនូរនោះ។

- **ការលក់** បានសេចក្តីថា ម្ចាស់សិទ្ធិគាត់មានសិទ្ធិនៅក្នុងការលក់នូវគំនូររបស់ខ្លួន ទៅឲ្យបុគ្គលណាមួយបានតាមឆន្ទៈរបស់ខ្លួន។

---

[53] មាត្រា១០៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

- **ការនាំចូលវត្ថុទាំងឡាយ ដែលបង្កើតឡើងដោយគំនូរឧស្សាហកម្ម** នៅពេលខ្លះ ម្ចាស់កម្មសិទ្ធិនៃគំនូរ បានលក់នូវគំនូររបស់ខ្លួនទៅឲ្យបុគ្គលណាម្នាក់នោះ ដោយបុគ្គលនោះ អាចជាបុគ្គលនៅក្នុងស្រុក ឬក្រៅស្រុក បន្ទាប់មកម្ចាស់ស្នាដៃនោះ ក៏ធ្វើការនាំចូលនូវផលិតផលសម្រេចដើម្បីធ្វើអាជីវកម្មនៅលើទីផ្សារវិញ។

ជារួម ម្ចាស់គំនូរឧស្សាហកម្ម អាចទទួលបាននូវសិទ្ធិ ពីការចុះបញ្ជីគំនូរឧស្សាហកម្មដូចខាងក្រោមៈ

- សិទ្ធិផ្តាច់មុខចំពោះគំនូរឧស្សាហកម្មរបស់ខ្លួន ដែលបានចុះបញ្ជីរួចហើយ មានន័យថា រាល់ការធ្វើអាជីវកម្មដោយបុគ្គលដទៃទៀត ក្រៅពីម្ចាស់គំនូរឧស្សាហកម្ម ត្រូវតែមានការយល់ព្រមពីម្ចាស់ដើម។ ការធ្វើអាជីវកម្មនេះ សំដៅលើការផលិត ការលក់ ឬការនាំចូលវត្ថុទាំងឡាយ ដែលបានបង្កើតឡើងដោយគំនូរឧស្សាហកម្ម។
- សិទ្ធិប្តឹងទៅតុលាការ គឺម្ចាស់គំនូរឧស្សាហកម្ម មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាមួយ ដែលបានរំលោភលើគំនូរឧស្សាហកម្មរបស់ខ្លួនដោយគ្មានការយល់ព្រមពីម្ចាស់គំនូរនោះ។[54] ក្រៅពីនេះ ម្ចាស់គំនូរឧស្សាហកម្មក៏មានសិទ្ធិនៅក្នុងការផ្ទេរគំនូររបស់ខ្លួន ទៅឲ្យបុគ្គលណាម្នាក់តាមឆន្ទៈខ្លួន ឬផ្តល់ជាអាជ្ញាប័ណ្ណលើគំនូរនោះ។

**ខ. ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាប័ណ្ណ**

ការប្តូរម្ចាស់កម្មសិទ្ធិ ជាការប្តូរម្ចាស់កម្មសិទ្ធិនៃគំនូរឧស្សាហកម្ម តាមរយៈកិច្ចសន្យាលក់ ឬផ្ទេរជាដើម។ ចំពោះការប្តូរម្ចាស់កម្មសិទ្ធិ នៃការចុះបញ្ជីគំនូរឧស្សាហកម្មស្របតាមច្បាប់ ឬប្តូរម្ចាស់កម្មសិទ្ធិនៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមគំរូពាក្យសុំដែលកំណត់ រួចដាក់ជូនមន្ត្រីកាន់កាប់បញ្ជី និងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវកត់ត្រាចូលបញ្ជី និងចុះផ្សាយជាសាធារណៈ ដោយមន្ត្រីកាន់កាប់បញ្ជីនោះ លើកលែងតែសំណុំលិខិតស្នើសុំដែលមិនត្រូវធ្វើការចុះផ្សាយ។ ការកត់ត្រាចូលក្នុងបញ្ជី ត្រូវបានធ្វើរួចជាស្ថាពរ ទើបការប្តូរម្ចាស់កម្មសិទ្ធិគំនូរឧស្សាហកម្ម អាចមានអានុភាពចំពោះភាគីទី ៣ ។ ហើយសំណើសុំធ្វើការកត់ត្រាប្តូរម្ចាស់កម្មសិទ្ធិនៃគំនូរឧស្សាហកម្មនេះត្រូវបង្ហាញនូវៈ

- លទ្ធផលចំពោះការប្តូរម្ចាស់កម្មសិទ្ធិដែលបានស្នើសុំឡើង
- លេខនៃការចុះបញ្ជីទាក់ទងនឹងការផ្លាស់ប្តូរ
- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់កម្មសិទ្ធិ

[54] ដកស្រង់ពីសៀវភៅនីតិកម្មសិទ្ធិបញ្ញារបស់សាស្ត្រាចារ្យ ខាំ សុមករា ទំព័រ១០៩។

- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់កម្មសិទ្ធិថ្មី

- កាលបរិច្ឆេទផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ

- ឈ្មោះប្រទេសដែលម្ចាស់កម្មសិទ្ធិថ្មីមានលំនៅដ្ឋានតាំងនៅ បើមិនដូច្នេះទេ ឈ្មោះនៃប្រទេសដែលម្ចាស់កម្មសិទ្ធិមានកន្លែងឧស្សាហកម្មពិតប្រាកដ ឬស្ថាប័នពាណិជ្ជកម្មតាំងនៅ

- បើម្ចាស់សិទ្ធិមានអ្នកតំណាង ត្រូវប្រាប់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង

- ម្ចាស់កម្មសិទ្ធិថ្មីត្រូវមានអាសយដ្ឋានមួយដែលងាយស្រួលទំនាក់ទំនង

- ការកំណត់ពីការផ្លាស់ប្តូរ។[55]

បន្ថែមពីនេះទៅទៀត សំណើសុំធ្វើការកត់ត្រាប្តូរម្ចាស់កម្មសិទ្ធិនេះ ត្រូវមាននូវឯកសារដូចខាងក្រោម៖

- កិច្ចសន្យាថតចម្លងមួយច្បាប់ដែលអនុលោមតាមកិច្ចសន្យាដើម

- សេចក្តីដកស្រង់ចេញពីកិច្ចសន្យា ដែលបង្ហាញអំពីការប្តូរម្ចាស់កម្មសិទ្ធិ ហើយសេចក្តីដកស្រង់នោះ ត្រូវតែពិតដូចកិច្ចសន្យា

- វិញ្ញាបនបត្រផ្ទេរមួយច្បាប់ដែលចុះហត្ថលេខាដោយម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិថ្មី

- ឯកសារផ្ទេរសិទ្ធិដែលចុះហត្ថលេខាដោយម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិថ្មី។[56]

មន្ត្រីកាន់កាប់បញ្ជី ត្រូវកត់ត្រាចូលបញ្ជី និងចុះផ្សាយជាសាធារណៈ ហើយការបោះពុម្ពផ្សាយស្តីពីការប្តូរម្ចាស់កម្មសិទ្ធិនេះត្រូវបញ្ជាក់អំពី៖

- ចំណាងជើងនៃគំនូរឧស្សាហកម្មដែលបានការពារ

- កាលបរិច្ឆេទសុំចុះបញ្ជី កាលបរិច្ឆេទអាទិភាពប្រសិនបើមាន និងកាលបរិច្ឆេទនៃការចុះបញ្ជី

- ម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិថ្មី

- និងលក្ខណៈនៃការប្តូរម្ចាស់កម្មសិទ្ធិ។

ចំណែកឯកិច្ចសន្យាអាជ្ញាប័ណ្ណ គឺសំដៅទៅលើកិច្ចសន្យាមួយ ដែលម្ចាស់សិទ្ធិនៃគំនូរឧស្សាហកម្មបានចុះបញ្ជីរួចហើយ ហើយផ្តល់គំនូរនោះទៅឲ្យជនណាម្នាក់ នូវសិទ្ធិធ្វើអាជីវកម្មលើគំនូរឧស្សាហកម្មនោះ។ មានន័យថា បុគ្គលណាម្នាក់ដែលទទួលបានអាជ្ញាប័ណ្ណគំនូរឧស្សាហកម្មពីម្ចាស់សិទ្ធិនៃគំនូរឧស្សាហកម្មនោះ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់គំនូរនោះ ទៅតាមអ្វីដែលបានព្រមព្រៀង ហើយត្រូវចុះហត្ថលេខាដោយភាគីទាំងសងខាង ដើម្បីបញ្ជាក់ពីពេលវេលាកំណត់នៃ

---

[55] ដកស្រង់ពីឯកសារ Standing committee on the law of trademarks, industrial designs and Geographies Indication (twenty-fifth session ) របស់ WIPO ទំព័រ៣០។

[56] ដកស្រង់ពីឯកសារ Standing committee on the law of trademarks, industrial designs and Geographies Indication (twenty-fifth session ) របស់ WIPO ទំព័រ៣០។

ការផ្តល់អាជ្ញាប័ណ្ណ និងព្រំដែននៃការប្រើប្រាស់គំនូរ ទៅតាមការព្រមព្រៀងគ្នា ថែមទាំងត្រូវរួមបញ្ចូលនូវការកំណត់ព្រំដែន ចំពោះប្រទេសដែលអ្នកទទួលអាជ្ញាប័ណ្ណ អាចប្រើប្រាស់គំនូរនោះ និងប្រភេទនៃផលិតផល។ ហើយការកត់ត្រាពីការផ្តល់អាជ្ញាប័ណ្ណ ត្រូវបំពេញនូវចំណុចមួយចំនួន ឬទាំងអស់ដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់សិទ្ធិ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងម្ចាស់សិទ្ធិ ប្រសិនបើម្ចាស់សិទ្ធិមានអ្នកតំណាង
- អាសយដ្ឋានពិតប្រាកដរបស់ម្ចាស់សិទ្ធិ ដើម្បីងាយស្រួលទំនាក់ទំនង
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណ
- បើអ្នកទទួលអាជ្ញាប័ណ្ណមានអ្នកតំណាង ត្រូវបញ្ជាក់ពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងនោះ
- អាសយដ្ឋានពិតប្រាកដរបស់អ្នកទទួលអាជ្ញាប័ណ្ណដើម្បីងាយទំនាក់ទំនង
- ឈ្មោះនៃប្រទេសដែលអ្នកទទួលអាជ្ញាប័ណ្ណមានលំនៅដ្ឋានតាំងនៅ និង/ឬ ឈ្មោះនៃប្រទេសដែលអ្នកទទួលអាជ្ញាប័ណ្ណមានកន្លែងឧស្សាហកម្មពិតប្រាកដ ឬស្ថាប័នពាណិជ្ជកម្មតាំងនៅ
- លេខនៃការចុះបញ្ជីគំនូរឧស្សាហកម្មដែលជាកម្មវត្ថុនៃការផ្តល់អាជ្ញាប័ណ្ណ
- រយៈពេលនៃការផ្តល់អាជ្ញាប័ណ្ណ
- បង្ហាញពីប្រភេទអាជ្ញាប័ណ្ណ ជាអាជ្ញាប័ណ្ណផ្តាច់មុខ អាជ្ញាប័ណ្ណមិនផ្តាច់មុខ ឬអាជ្ញាប័ណ្ណដោយឡែក
- បង្ហាញពីចំនួនគំនូរឧស្សាហកម្ម ដែលបានអនុញ្ញាតផ្តល់អាជ្ញាប័ណ្ណ ក្នុងចំណោមគំនូរទាំងឡាយ ដែលគេបានចុះបញ្ជី។

បន្ថែមពីនេះទៀត ការផ្តល់អាជ្ញាប័ណ្ណត្រូវភ្ជាប់នូវឯកសារដូចជា៖

- លិខិតស្រង់នៃកិច្ចសន្យាអាជ្ញាប័ណ្ណ ដែលបង្ហាញប្រាប់ពីភាគីនៃកិច្ចសន្យា ហើយនឹងសិទ្ធិដែលបានផ្តល់ឲ្យដោយច្បាប់មានសមត្ថកិច្ច ឬ
- របាយការណ៍ស្តីពីការផ្តល់អាជ្ញាប័ណ្ណមិនផ្លូវការ ដែលចុះហត្ថលេខាដោយម្ចាស់កម្មសិទ្ធិ និងអ្នកទទួលអាជ្ញាប័ណ្ណនោះ។

រាល់កិច្ចសន្យាអាជ្ញាប័ណ្ណនៃគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីហើយ ត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវរក្សាការសម្ងាត់ ដែលមាននៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ ប៉ុន្តែត្រូវកត់ត្រាចូលបញ្ជី និងត្រូវចុះផ្សាយជាសាធារណៈ នូវចំណុចគោលមួយចំនួន[57]។ ការកត់ត្រា

[57] មាត្រា១១៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

ពីការផ្តល់អាជ្ញាប័ណ្ណ ដែលបានផ្តល់ឲ្យម្ចាស់សិទ្ធិ ក៏អាចធ្វើការបកប្រែ ឬលុបចោលវិញបានផងដែរ តែការសុំកែប្រែត្រូវតម្រូវឲ្យមាននូវឯកសារដូចជា៖

- ឯកសារបង្ហាញភស្តុតាងពីសំណើស្នើសុំ ក្នុងការកែប្រែការកត់ត្រាផ្តល់អាជ្ញាប័ណ្ណ ឬ

- របាយការណ៍មិនផ្លូវការ នៃការកែប្រែការផ្តល់អាជ្ញាប័ណ្ណ ដែលបានចុះហត្ថលេខាដោយម្ចាស់កម្មសិទ្ធិ និងអ្នកទទួលអាជ្ញាប័ណ្ណ។

រីឯការសុំលុបចោលនូវការផ្តល់អាជ្ញាប័ណ្ណវិញ ក៏តម្រូវឲ្យមានឯកសារដូចជា៖

- ឯកសារបង្ហាញភស្តុតាងពីសំណើសុំក្នុងការលុបចោលការកត់ត្រាផ្តល់អាជ្ញាប័ណ្ណ ឬ

- របាយការណ៍មិនផ្លូវការ នៃការសុំលុបចោលការផ្តល់អាជ្ញាប័ណ្ណ ដែលបានចុះហត្ថលេខាដោយម្ចាស់កម្មសិទ្ធិ និងអ្នកទទួលអាជ្ញាប័ណ្ណ។

ចំពោះការផ្តល់អាជ្ញាប័ណ្ណ ឲ្យប្រើប្រាស់គំនូរឧស្សាហកម្មទៅកាន់ប្រទេសដទៃៗ វៀរលែងតែម្ចាស់សិទ្ធិនោះ បានទទួលនូវកិច្ចការពារគំនូរនោះ នៅក្នុងប្រទេសដែលជាប់ទាក់ទងនោះ ឬក៏យ៉ាងហោចណាស់ ក៏បានដាក់ពាក្យសុំនូវកិច្ចការពារគំនូរឧស្សាហកម្ម នៅក្នុងប្រទេសទាំងនោះដែរ។ ហើយចំពោះសហគមន៍អឺរ៉ុបវិញ ការផ្តល់អាជ្ញាប័ណ្ណគំនូរឧស្សាហកម្មទៅឲ្យបុគ្គលណាមួយ ត្រូវបែងចែកដូចជា៖

- អាជ្ញាប័ណ្ណសម្រាប់គំនូរឧស្សាហកម្មសហគមន៍ដែលត្រូវចុះបញ្ជី ត្រូវបានកត់ត្រាចូលទុកក្នុងបញ្ជីថា ជាអាជ្ញាប័ណ្ណផ្តាច់មុខ ប្រសិនបើម្ចាស់គំនូរឧស្សាហកម្ម ឬអ្នកកាន់កាប់អាជ្ញាប័ណ្ណនេះស្នើសុំយ៉ាងដូច្នេះ

- អាជ្ញាប័ណ្ណសម្រាប់គំនូរឧស្សាហកម្មសហគមន៍ដែលត្រូវចុះបញ្ជី ត្រូវកត់ត្រាក្នុងបញ្ជីថាជាអាជ្ញាប័ណ្ណរង ប្រសិនបើម្ចាស់អាជ្ញាប័ណ្ណ ដែលអាជ្ញាប័ណ្ណរបស់ខ្លួន ត្រូវបានកត់ត្រាចូលក្នុងបញ្ជីបានសម្រេចយ៉ាងដូច្នេះ

- អាជ្ញាប័ណ្ណសម្រាប់គំនូរឧស្សាហកម្មសហគមន៍ដែលត្រូវចុះបញ្ជី ត្រូវបានកត់ត្រាចូលក្នុងបញ្ជីថា ជាអាជ្ញាប័ណ្ណដែលកំណត់ឲ្យប្រើប្រាស់ក្នុងដែនដីមួយ ប្រសិនណាបើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់តែក្នុងផ្នែកណាមួយនៅក្នុងសហគមន៍

- អាជ្ញាប័ណ្ណសម្រាប់គំនូរឧស្សាហកម្មសហគមន៍ដែលត្រូវចុះបញ្ជី ត្រូវបានកត់ត្រាចូលក្នុងបញ្ជីថា ជាអាជ្ញាប័ណ្ណបណ្តោះអាសន្ន ប្រសិនបើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ ក្នុងរយៈពេលមួយជាកំណត់។[58]

[58] មាត្រា២៥ នៃបទបញ្ជារបស់គណៈកម្មការសហគមន៍អឺរ៉ុបលេខ ២២៤៥/២០០២ ស្តីពីការអនុវត្តបទបញ្ជាក្រុមប្រឹក្សាសហគមន៍អឺរ៉ុប (ស,អ) ស្តីពីគំនូរឧស្សាហកម្ម។

## កថាខណ្ឌទី២ ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ

### ក. ការរំលោភសិទ្ធិនៃគំនូរឧស្សាហកម្ម

#### ក.១ និយមន័យនៃការរំលោភ

និយមន័យនៃការរំលោភសិទ្ធិនៃគំនូរឧស្សាហកម្ម គឺជាការអនុវត្តសកម្មភាពរំលោភសិទ្ធិទាំងឡាយ ដោយគ្មានការព្រមព្រៀងពីម្ចាស់ ដែលបានទទួលសិទ្ធិការពារ។[59] ហើយកើតឡើងបានដោយសារ មានសិទ្ធិផ្តាច់មុខដល់ម្ចាស់សិទ្ធិ ក្នុងការផលិត ការលក់ ឬការនាំចូលវត្ថុទាំងឡាយដែលបានបង្កើតឡើងដោយគំនូរនោះ និងដោយការចុះបញ្ជីគំនូរឧស្សាហកម្ម ទើបរាល់សកម្មភាពអាជីវកម្មដោយបុគ្គលដទៃទៀត ដែលប្រើប្រាស់នូវគំនូរមួយមានលក្ខណៈដូចគ្នា ទៅនឹងគំនូរដែលបានធ្វើការចុះបញ្ជី ចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់សិទ្ធិនៃគំនូរឧស្សាហកម្ម។ សិទ្ធិផ្តាច់មុខដែលម្ចាស់សិទ្ធិមាន ជាសិទ្ធិឯកជនរបស់បុគ្គល ដូច្នេះ ការអនុវត្តសិទ្ធិនេះ ជាតួនាទីនៃម្ចាស់សិទ្ធិ ហើយមានតែម្ចាស់សិទ្ធិទេ ដែលមានទំនួលខុសត្រូវនៅក្នុងការដាក់ពាក្យបណ្តឹង ដើម្បីទប់ស្កាត់ការរំលោភបំពានពីភាគីដទៃ ឬអាចនិយាយបានថា គាត់គឺជាអ្នកផ្តើមសកម្មភាពដំបូងគេក្នុងកិច្ចការពារគំនូរឧស្សាហកម្មដែលបានចុះបញ្ជី។ មានតែម្ចាស់សិទ្ធិ ឬអ្នកស្នងជំនួស ឬអ្នកដែលមានសិទ្ធិលើគំនូរឧស្សាហកម្មស្របច្បាប់ប៉ុណ្ណោះ ទើបមានសិទ្ធិប្តឹង ដើម្បីបញ្ឈប់សកម្មភាពរំលោភសិទ្ធិនៃគំនូរឧស្សាហកម្ម និងទាមទារសំណងចំពោះការរំលោភនោះ។ ហើយជំនួយដ៏ល្អរបស់ម្ចាស់សិទ្ធិនៃគំនូរឧស្សាហកម្ម គឺមេធាវីដែលមានជំនាញផ្នែកកម្មសិទ្ធិបញ្ញា។ មានតែមេធាវីទេ ដែលជាអ្នកមានសមត្ថភាព ក្នុងការផ្តល់ពត៌មានទៅឲ្យម្ចាស់សិទ្ធិ ពីរបៀបដាក់ពាក្យបណ្តឹង និងផ្តល់ដំបូន្មានពីរបៀបដោះស្រាយជំលោះ។ ហើយបើម្ចាស់សិទ្ធិ ឬអ្នកស្នងជំនួស ឬអ្នកដែលមានសិទ្ធិស្របច្បាប់ទាំងនោះ មិនប្តឹងទៅលើសកម្មភាពរំលោភនោះទេ អ្នកដទៃទៀតមិនអាចចេញមុខប្តឹងជំនួសអ្នកទាំងនោះឡើយ។

#### ក.២ ទោសប្បញ្ញត្តិ

បុគ្គលណាមួយដែលបានផ្តល់ពត៌មានមិនពិត នៅក្នុងឯកសារដែលបានដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីមួយលានរៀល (១.០០០.០០០ រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ខែ ទៅ ០៦ខែ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើ ក្នុងករណីមិនរាងចាលក្នុងរយៈពេល ៥ឆ្នាំ គិតចាប់ពីពេលផ្តន្ទាទោសលើកមុន ត្រូវផ្តន្ទាទោសទ្វេដង ដែលចាត់ទុកថាជាទណ្ឌកម្ម ចំពោះការផ្តល់ពត៌មានមិនពិត។[60]

---

[59] មាត្រា១២៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[60] មាត្រា១៣២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

រីឯបុគ្គលណាមួយដែលបានរំលោភដោយចេតនា ត្រូវផ្តន្ទាទោសដោយពិន័យជាប្រាក់ ពីប្រាំលានរៀល (៥.០០០.០០០ រៀល) ដល់ម្ភៃលានរៀល (២០.០០០.០០០ រៀល) ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ឆ្នាំ ទៅ ០៥ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើ ក្នុងករណីមិនរាងចាលក្នុងរយៈពេល ០៥ឆ្នាំ គិតចាប់ពីពេលផ្តន្ទាទោសលើកមុន ត្រូវផ្តន្ទាទោសទ្វេដង ដែលចាត់ទុកថាជាទណ្ឌកម្មចំពោះការរំលោភបំពាន។[61]

នៅក្នុងករណីត្រូវផ្តន្ទាទោស តុលាការមានសមត្ថកិច្ច អាចបញ្ជាឲ្យធ្វើការរឹបអូសទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលនូវទំនិញដែលរំលោភ និងសម្ភារៈ ឧបករណ៍ដែលយកមកប្រើប្រាស់ ក្នុងការប្រព្រឹត្តអំពើរំលោភលើម្ចាស់សិទ្ធិគំនូរឧស្សាហកម្ម។[62]

## ខ. យន្តការដោះស្រាយវិវាទ

### ខ.១ យន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ

ការិយាល័យគំនូរឧស្សាហកម្ម មានភារៈកិច្ចក្នុងការសម្រុះសម្រួល រាល់វិវាទពាក់ព័ន្ធគំនូរឧស្សាហកម្ម។[63]

ស្របតាមអង្គការកម្មសិទ្ធិបញ្ញាពិភពលោក មានទីតាំងស្ថិតនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ហើយត្រូវបានគេបង្កើតឡើងនៅឆ្នាំ១៩៩៤ ក្នុងគោលបំណងដើម្បីជំរុញការដោះស្រាយវិវាទទាក់ទងនឹងបញ្ហាកម្មសិទ្ធិបញ្ញា តាមនីតិវិធីក្រៅប្រព័ន្ធតុលាការ និងដោយសារប្រទេសកម្ពុជា ក៏ជាសមាជិកមួយរបស់អង្គការនេះ ដូចនេះ ទើបយើងអាចមាននូវវិធាន ក្នុងការដោះស្រាយវិវាទដែលបានផ្តល់អោយ ដោយមជ្ឈមណ្ឌលសន្ទានកម្ម និងមជ្ឈត្តកម្ម ដែលជាវិធានមួយរបស់អង្គការនេះ សម្រាប់ផ្តល់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ពាក់ព័ន្ធទៅនឹងបញ្ហាកម្មសិទ្ធិបញ្ញា ដល់បណ្តាលប្រទេសជាសមាជិក។

### ខ.២ យន្តការដោះស្រាយវិវាទតាមផ្លូវតុលាការ

ក្រៅពីមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគីវិវាទអាចមានជម្រើសមួយទៀត ក្នុងការដោះស្រាយវិវាទខ្លួន ដោយជ្រើសរើសតាមយន្តការដោះស្រាយវិវាទ តាមប្រព័ន្ធតុលាការវិញ ឬអាចប្រើប្រាស់នូវយន្តការទាំងពីរនេះតែម្តង។

អាជ្ញាធរខាងយុត្តាធិការ ត្រូវមានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យមានជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព នូវវិធានការបណ្តោះអាសន្ន ដែលជាដីការបស់តុលាការ ដើម្បីបញ្ជា ឬបង្ការ ឬ

[61] មាត្រា១៣៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[62] មាត្រា១៣៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[63] មាត្រា៤ (៤) នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។

រារាំងសកម្មភាពណាមួយ និងដើម្បីការពារការរំលោភបំពានកម្មសិទ្ធិបញ្ញា មិនឲ្យកើតមានឡើង។ ជាពិសេសការជ្រៀតចូលនូវទំនិញ ក្នុងចរន្តពាណិជ្ជកម្ម ដែលស្ថិតក្រោមដែនយុត្តាធិការខ្លួន និងរក្សាភស្តុតាងដែលពាក់ព័ន្ធនឹងការរំលោភបំពាន ដែលទទួលការចោទប្រកាន់នោះ។ ដើម្បីអោយតុលាការចេញនូវវិធាននេះបាន អ្នកប្តឹងត្រូវតែបង្ហាញថា គ្មានសំណងគ្រប់គ្រាន់ និងត្រឹមត្រូវតាមផ្លូវច្បាប់ទេ ហើយប្រសិនបើមិនមានវិធាននេះ នឹងកើតមានឡើងនូវការខូចខាតធ្ងន់ធ្ងរ ឬមិនអាចជួសជុល[64] ថែមទាំងត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- នៅពេលដែលមានការពន្យារពេលណាមួយ ដែលទំនងដូចជា បង្កនូវការខូចខាតមិនអាចជួសជុលបាន ចំពោះអ្នកកាន់កាប់សិទ្ធិ ឬនៅពេលមានការបង្ហាញថា គ្រោះថ្នាក់នៃការបំផ្លាញភស្តុតាងអាចកើតមាន

- អ្នកដាក់ពាក្យបណ្តឹង បានបង្ហាញភស្តុតាងគ្រប់គ្រាន់ថា ខ្លួនជាអ្នកកាន់កាប់សិទ្ធិ និងបង្ហាញថាសិទ្ធិរបស់ខ្លួន កំពុងត្រូវបានគេរំលោភបំពាន ឬការរំលោភបំពាននោះជិតនឹងកើតឡើង ហើយអាជ្ញាធរខាងយុត្តាធិការ អាចបញ្ជាឲ្យអ្នកដាក់ពាក្យប្តឹងនោះ ផ្តល់ការធានាដែលមានតម្លៃសមមូលគ្រប់គ្រាន់ ដើម្បីការពារចុងចោទ និងបង្ការការប្តឹងបំពាន។ អ្នកដាក់ពាក្យបណ្តឹងអាចត្រូវតម្រូវឲ្យផ្តល់ពតិមានចាំបាច់ផ្សេងទៀត សម្រាប់បង្ហាញអត្តសញ្ញាណរបស់ទំនិញដែលពាក់ព័ន្ធ។[65]

- តុលាការមានសមត្ថកិច្ច គឺអាចបំពេញនូវសេចក្តីសម្រេចបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការរំលោភ ឬការរំលោភដែលប្រុងនឹងកើតឡើង សម្រេចអោយសងជាការខូចខាត និងផ្តល់ដំណោះស្រាយផ្សេងៗ ដែលមានចែងក្នុងច្បាប់ផ្សេងទៀតជាធរមាន តាមរយៈបណ្តឹងរបស់ម្ចាស់ទទួលបានសិទ្ធិការពារ ឬរបស់អ្នកទទួលអាជ្ញាប័ណ្ណ ក្រោយពីបានស្នើសុំទៅអោយម្ចាស់ប្តឹង ទៅតុលាការមានសមត្ថកិច្ច តែម្ចាស់នោះបានបដិសេធ ឬខកខានមិនបានធ្វើតាមសំណើនោះទេ។[66]

នៅពេលដែលទទួលបាននូវ វិធានបណ្តោះអាសន្ននេះ នឹងទទួលបានការជូនដំណឹងដោយគ្មានបង្អែរបង្អង់ ក្រោយពេលអនុវត្តវិធានចុងក្រោយបង្អស់។ ការពិនិត្យឡើងវិញ រួមទាំងសិទ្ធិក្នុងការស្តាប់សវនាការ ត្រូវធ្វើឡើងតាមសំណើរបស់ចុងចម្លើយ ដើម្បីពិនិត្យសម្រេចក្នុងអំឡុងពេលសមស្របមួយ បន្ទាប់ពីជូនដំណឹងអំពីវិធានការនេះថា វិធាននេះត្រូវតែកែតម្រូវ លុបចោល ឬបន្តការអនុវត្ត។ នៅពេលដែលវិធាននេះ ត្រូវបានដកហូតឲ្យឈប់អនុវត្ត ឬអស់សុពលភាពនោះដោយសារសកម្មភាពណាមួយ ឬដោយសារការលុបចោលដោយអ្នកដាក់ពាក្យបណ្តឹង ឬនៅពេល

---

[64] Bryan A. Garner,Black's Law Dictionary (9th ed.), p 855.

[65] មាត្រា៥០ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធបញ្ញា (កិច្ចព្រមព្រៀងTRIPS១៩៩៤)។

[66] មាត្រា១២៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

ដែលវិធានការនេះ ត្រូវបានគេរកឃើញជាបន្តបន្ទាប់ថា គ្មានការរំលោភបំពាន ឬការគំរាមកំហែងទេ អាជ្ញាធរយុត្តាធិការ ត្រូវមានសិទ្ធិអំណាចបញ្ជាឲ្យអ្នកដាក់ពាក្យ ប្តឹងតាមសំណើរបស់ចុងចោទឲ្យផ្តល់ដល់ចុងចោទនូវប្រាក់សំណងសមរម្យ ចំពោះការខូចខាតទាំងឡាយ ដែលបង្កដោយវិធានការទាំងនេះ។

រីឯបណ្តឹងដល់អង្គសេចក្តី គឺសំដៅរាល់បណ្តឹងទាំងឡាយណា ដែលធ្វើឡើងដោយម្ចាស់សិទ្ធិ ទៅកាន់តុលាការមានសមត្ថកិច្ចចំពោះបុគ្គលណាមួយ ដែលរំលោភលើគំនូរឧស្សាហកម្មរបស់ខ្លួន តាមរយៈការធ្វើអាជីវកម្ម ដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិ ឬតាមរយៈការអនុវត្តសកម្មភាពទាំងឡាយ ដែលអាចនឹងបណ្តាលឲ្យមានការរំលោភកើតឡើង។ ហើយការសម្រេចដល់អង្គសេចក្តីតម្រូវឲ្យតុលាការមានសមត្ថកិច្ច អាចផ្តន្ទាទោសពិន័យជាប្រាក់ និង/ឬ ដាក់ពន្ធនាគារចំពោះបុគ្គលណាដែលបានរំលោភបំពាន។ កម្រិតទោសពិន័យជាប្រាក់ និង/ឬ ដាក់ពន្ធនាគារ គឺមានចែងក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។ តុលាការក៏អាចបញ្ជាឲ្យរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ ឬបំផ្លាញចោលនូវទំនិញដែលរំលោភ និងឧបករណ៍សំភារៈ ដែលប្រើប្រាស់ក្នុងសកម្មភាពរំលោភបំពាន។

# ជំពូកទី៣ យន្តការនៃការការពារគំនូរឧស្សាហកម្មជាអន្តរជាតិ ក្រោមកិច្ចព្រមព្រៀងទីក្រុងឡាអេ (០៦. ១១. ១៩២៥)

## ផ្នែកទី១ នីតិវិធីនៃការសុំចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិ

### កថាខណ្ឌទី១ ខ្លឹមសារនៃសំណុំលិខិតស្នើសុំ និងទម្រង់នៃពាក្យសុំ

#### ក. ខ្លឹមសារនៃសំណុំលិខិតស្នើសុំ

នៅក្នុងច្បាប់ឆ្នាំ១៩៦០ បានកំណត់ថា ការតម្កល់ជាអន្តរជាតិ រួមមាននូវពាក្យសុំចុះបញ្ជីជាអន្តរជាតិមួយ និងរូបថត ឬគំនូសតាងមួយ ឬច្រើនជាតំណាងនៃគំនូរឧស្សាហកម្ម ហើយត្រូវរួមបញ្ចូលទាំងការបង់កម្រៃ ដែលបានកំណត់ដោយបទបញ្ញាផងដែរ។ ដោយឡែក នៅក្នុងច្បាប់ឆ្នាំ ១៩៩៩ វិញ បានកំណត់ថា សំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវមានដូចជា ពាក្យសុំចុះបញ្ជីអន្តរជាតិ ទិន្នន័យដែលបានកំណត់អំពីអ្នកដាក់ពាក្យសុំ ចំនួនកំណត់ច្បាប់ចម្លងនៃគំនូរឧស្សាហកម្ម ការចង្អុលបង្ហាញពីផលិតផល ឬផលិតផលទាំងឡាយណា ដែលបង្កើតជាគំនូរឧស្សាហកម្ម ការចង្អុលបង្ហាញពីភាគីហត្ថលេខី ជ្រើសរើសកម្រៃកំណត់ និងចំនុចពិសេសផ្សេងៗទៀត។[67]

នៅក្នុងករណីនេះ ត្រូវលើកយកតែខ្លឹមសារនៃសំណុំលិខិតស្នើសុំ តាមច្បាប់ឆ្នាំ១៩៦០ មកបកស្រាយប៉ុណ្ណោះ។

#### ខ. ពាក្យសុំ

នៅក្នុងពាក្យសុំចុះបញ្ជីជាអន្តរជាតិមួយ ត្រូវគោរពនូវចំនុចសំខាន់ៗដែលមានដូចជា៖

-បញ្ជីនៃរដ្ឋហត្ថលេខីដែលអ្នកដាក់ពាក្យសុំស្នើសុំឱ្យការតម្កល់ជាអន្តរជាតិត្រូវមានអានុភាពក្នុងរដ្ឋនោះ

-ការជ្រើសរើសវត្ថុមួយ ឬច្រើន ដែលគេមានបំណងនឹងបញ្ចូលគំនូរទៅក្នុងវត្ថុនោះ

-ការបញ្ជាក់កាលបរិច្ឆេទ រដ្ឋ និងចំនួននៃការតម្កល់ដែលបង្កើតសិទ្ធិអាទិភាព ប្រសិនបើអ្នកដាក់ពាក្យសុំមានបំណងទាមទារអាទិភាព

-ចំនុចពិសេសផ្សេងទៀតដូចមានចែងនៅក្នុងបទបញ្ញា។

ក្រៅពីខ្លឹមសារដូចដែលបានលើកឡើងខាងលើនេះ នៅក្នុងពាក្យសុំអន្តរជាតិ ក៏អាចមាននូវខ្លឹមសារមួយចំនួនទៀតដែលរួមមាន៖

-សេចក្ដីអធិប្បាយខ្លីមួយ អំពីលក្ខណៈរូបរាងនៃគំនូរ

---

[67] មាត្រា៥ (១) នៃច្បាប់ហ្សឺណែវស្ដីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

-សេចក្តីប្រកាសអំពីអ្នកបង្កើតស្នាដៃពិតនៃគំនូរ

-ពាក្យសុំពន្យារការចុះផ្សាយជាដើម។[68]

ពាក្យសុំចុះបញ្ជីជាអន្តរជាតិនេះ អាចសរសេរបានជាបីភាសា គឺភាសាអង់គ្លេស បារាំង និង អេស្ប៉ាញ ហើយការសរសេរជាភាសាណាមួយនោះ គឺអាស្រ័យទៅតាមចំណង់ចំណូលចិត្តរបស់អ្នកដាក់ពាក្យសុំ។

លើសពីនេះទៅទៀត ការទំនាក់ទំនង និងការបញ្ជូនពាក្យសុំ អាចប្រើប្រាស់ភាសាទាំងបីខាងលើនេះបានអាស្រ័យដោយៈ

-នៅពេលធ្វើការទំនាក់ទំនង និងបញ្ជូនពាក្យសុំទៅការិយាល័យអន្តរជាតិ អ្នកដាក់ពាក្យសុំ អ្នកកាន់កាប់ ឬ ការិយាល័យជាតិនៃរដ្ឋហត្ថលេខី ត្រូវតែសរសេរជាភាសាអង់គ្លេស បារាំង និង អេស្ប៉ាញ។

-ហើយនៅពេលដែលការិយាល័យអន្តរជាតិ ធ្វើការទំនាក់ទំនងជាមួយនឹងការិយាល័យជាតិនៃរដ្ឋហត្ថលេខីនីមួយៗ គឺអាចសរសេរជាភាសាអង់គ្លេស បារាំង និងអេស្ប៉ាញបាន លុះត្រាតែរដ្ឋហត្ថលេខីទាំងនោះ បានជូនដំណឹងទៅការិយាល័យអន្តរជាតិថាអាចធ្វើដូច្នេះបាន។

-នៅពេលដែលការិយាល័យអន្តរជាតិ ធ្វើការទំនាក់ទំនងជាមួយអ្នកដាក់ពាក្យសុំ គឺអាចប្រើប្រាស់ភាសាទាំងបីខាងលើនេះបាន លុះត្រាតែអ្នកដាក់ពាក្យសុំ បានជូនដំណឹងជាមុនទៅការិយាល័យអន្តរជាតិ ថាអាចធ្វើបែបនេះបាន។

**- អ្នកដាក់ពាក្យសុំ**

- **ឈ្មោះ ៖** ប្រសិនបើអ្នកដាក់ពាក្យសុំជារូបវន្តបុគ្គល នោះត្រកូល និងឈ្មោះ ត្រូវតែបង្ហាញ ហើយការបង្ហាញនេះ ទៀតសោត គឺធ្វើទៅតាមទំលាប់នៃការប្រើប្រាស់។ ហើយប្រសិនបើអ្នកដាក់ពាក្យសុំជានីតិបុគ្គលស្របច្បាប់ នោះឈ្មោះជាផ្លូវការរបស់នីតិបុគ្គលនោះ ត្រូវតែបង្ហាញ។

លើសពីនេះទៅទៀត ឈ្មោះរបស់អ្នកដាក់ពាក្យសុំ ត្រូវតែសរសេរជាភាសាឡាតាំង ដោយយោងទៅតាមនិមិត្តសញ្ញាសម្លេងនៃភាសា (អង់គ្លេស បារាំង អេស្ប៉ាញ) ដែលត្រូវប្រើប្រាស់នៅក្នុងពាក្យសុំនោះ។ ដូចគ្នានេះដែរ ប្រសិនឈ្មោះរបស់នីតិបុគ្គលណាមួយ ដែលពុំមែនជាអក្សរឡាតាំង នោះត្រូវសរសេរជាអក្សរឡាតាំង ដោយការបកប្រែទៅក្នុងភាសានៃពាក្យសុំ។

- **អាសយដ្ឋាន៖** ត្រូវសរសេរបង្ហាញ

[68] មាត្រា៥ នៃច្បាប់ទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

- **លេខទូរស័ព្ទ ទូរសារ និងគេហទំព័រ៖** ពុំមែនជាកាតព្វកិច្ចទេ តែគួរតែបង្ហាញ
- **អាសយដ្ឋានសារអេឡិចត្រូនិច** (Email address)៖ ពុំមែនជាកាតព្វកិច្ចទេ តែគួរតែបង្ហាញ។

**- អ្នកដាក់ពាក្យសុំច្រើន**

ក្នុងករណីដែលមានអ្នកដាក់ពាក្យសុំច្រើន នៅក្នុងពាក្យសុំអន្តរជាតិមួយ នោះអ្នកដាក់ពាក្យសុំម្នាក់ៗ ត្រូវតែបង្ហាញនូវរាល់ទិន្នន័យដែលពាក់ព័ន្ធ ដែលតម្រូវនៅក្នុងចំនុច "អ្នកដាក់ពាក្យសុំ" ។ អ្នកដាក់ពាក្យសុំដំបូងគេ ត្រូវចូលក្នុងទិន្នន័យរបស់ខ្លួន ហើយបន្ទាប់មកចុចលើអក្សរ " រក្សាទុក" ។ ហើយទិន្នន័យនឹងបង្ហាញ នៅចំនុចក្រោមគេបង្អស់នៅក្នុងផ្នែក " អ្នកដាក់ពាក្យសុំបានចុះឈ្មោះ " Registered applicant (s) ។ ហើយអ្នកដាក់ពាក្យសុំបន្តបន្ទាប់ គឺធ្វើដូចគ្នានឹងអ្នកដំបូងដែរ បើការបញ្ជូនធ្វើតាមប្រព័ន្ធអ៊ី-ហ្វាលលីង។

**- សិទ្ធិអាទិភាព**

សិទ្ធិអាទិភាព ជាកាលបរិច្ឆេទនៃការតម្កល់លើកដំបូង ប្រសិនបើការតម្កល់គំនូរជាអន្តរជាតិ បានធ្វើឡើងក្នុងរយៈពេល ០៦ខែ បន្ទាប់ពីការតម្កល់លើកដំបូង នៃគំនូរដូចគ្នានៅក្នុងរដ្ឋមួយ ដែលជាសមាជិកនៃសហភាពអន្តរជាតិ ទទួលបន្ទុកកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ហើយប្រសិនបើអាទិភាពត្រូវបានទាមទារ ចំពោះការតម្កល់ជាអន្តរជាតិ។[69]

ដើម្បីអះអាងសិទ្ធិអាទិភាព អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ពតិមានដែលគេតម្រូវ។ ហើយនៅពេលដែលសិទ្ធិអាទិភាពត្រូវបានអះអាង អ្នកដាក់ពាក្យសុំត្រូវតែបង្ហាញឈ្មោះនៃការិយាល័យដែលការបញ្ជូនដំបូងត្រូវបានធ្វើឡើង និងចំនួននៃការបញ្ជូនផងដែរប្រសិនជាអាច ព្រមទាំងកាលបរិច្ឆេទនៃការបញ្ជូនផងដែរ។

ប្រសិនបើការបញ្ជូនមុន មិនទាក់ទងទៅនឹងគំនូរឧស្សាហកម្មដែលបានបញ្ចូលនៅក្នុងពាក្យសុំនោះទេ អ្នកដាក់ពាក្យសុំអាចបង្ហាញគំនូរឧស្សាហកម្មសម្រាប់ការអះអាងសិទ្ធិអាទិភាព និងគំនូរឧស្សាហកម្ម ដែលសិទ្ធិអាទិភាពមិនត្រូវបានអះអាង។ ប្រសិនបើការបង្ហាញមិនត្រូវបានធ្វើឡើងនោះទេ នោះការិយាល័យអន្តរជាតិនឹងសន្មតថា ការអះអាងសិទ្ធិអាទិភាពដែលទាក់ទងទៅនឹងរាល់គំនូរឧស្សាហកម្មទាំងនោះ ត្រូវបានបញ្ចូលទៅក្នុងពាក្យសុំអន្តរជាតិ។

នៅពេលដែលអ្នកដាក់ពាក្យសុំ អះអាងសិទ្ធិអាទិភាពនៃការបញ្ជូនមុន អ្នកដាក់ពាក្យសុំមិនត្រូវបញ្ជូនទៅការិយាល័យអន្តរជាតិ នូវការចម្លងនៃឯកសារនៃការបញ្ជូនមុន ដែលសិទ្ធិអាទិភាពពឹងផ្អែកនោះទេ។ ម្យ៉ាងវិញទៀត ការិយាល័យជាតិនៃភាគីហត្ថលេខី អាចស្នើសុំការចម្លងឯកសារសិទ្ធិអាទិភាពនៅពេលក្រោយៗបាន ឧទាហរណ៍ នៅក្នុងបរិបទនៃការបដិសេធ ដែលការិយាល័យ

[69] មាត្រា៩ នៃច្បាប់ទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

ទទួលនូវឯកសារអាទិភាព ដែលចាំបាច់ដើម្បីបង្កើតភាពថ្មី ពីព្រោះការបង្ហាញនូវរយៈពេល គឺត្រូវគ្របដណ្តប់ដោយការអះអាងអាទិភាព។

ការិយាល័យអន្តរជាតិ នឹងលើកចោលនូវការអះអាងសិទ្ធិអាទិភាព ដែលហួសរយៈពេល០៦ខែ មុនកាលបរិច្ឆេទបញ្ជូនពាក្យសុំអន្តរជាតិ និងធ្វើការជូនដំណឹងទៅអ្នកដាក់ពាក្យសុំផងដែរ។

**- ការចុះហត្ថលេខា**

ពាក្យសុំអន្តរជាតិត្រូវតែចុះហត្ថលេខា និងចុះកាលបរិច្ឆេទដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកតំណាងរបស់គាត់។ ការចុះហត្ថលេខាត្រូវមាននូវការបង្ហាញ នៃឈ្មោះរបស់អ្នកដាក់ពាក្យសុំ ឬឈ្មោះរបស់អ្នកតំណាង (អាស្រ័យទៅលើអ្នកណាចុះហត្ថលេខាលើពាក្យសុំ)។ ហើយកាលបរិច្ឆេទគឺជាកាលបរិច្ឆេទដែលពាក្យសុំមានសុពលភាព និងត្រូវបានបញ្ជូនទៅកាន់ការិយាល័យអន្តរជាតិ។

**គ. រូបថត ឬគំនូសតាង**

នៅក្នុងពាក្យសុំចុះបញ្ជីជាអន្តរជាតិ ត្រូវតែមានភ្ជាប់មកជាមួយនូវរូបថត ឬគំនូសតាង និងសេចក្តីអធិប្បាយ ដែលទាក់ទងទៅនឹងគំនូរឧស្សាហកម្ម ដែលចង់ទទួលបាននូវការការពារ។ ជាទូទៅ នៅក្នុងពាក្យសុំនោះ ត្រូវមានរូបថត ១ប្លង់ ប្រសិនបើគំនូរឧស្សាហកម្មនោះ ជាគំនូរទម្រង់ពីរខ្នាត ក៏ប៉ុន្តែប្រសិនបើវាជាទម្រង់បីខ្នាតវិញ ត្រូវតែមានរូបថតគំនូរឧស្សាហកម្មនោះ យ៉ាងហោចណាស់ ៦ប្លង់ ដែរ។

រូបថត និងគំនូសតាងទាំងឡាយនៃគំនូរឧស្សាហកម្ម ត្រូវតែដាក់នៅលើក្រដាស A4 ដែលក្រដាសនោះទៀតសោត ត្រូវមានពណ៌សល្អក់។

**ឃ. កម្រៃកំណត់**

ពាក្យសុំចុះបញ្ជីជាអន្តរជាតិមួយ គឺត្រូវបានគេកំណត់អោយបង់កម្រៃជា ៣ ប្រភេទគឺៈ

- កម្រៃជាមូលដ្ឋាន
- កម្រៃចុះផ្សាយ
- កម្រៃសម្រាប់រដ្ឋហត្ថលេខីដែលផ្តល់ការការពារ (កម្រៃស្តង់ដារ ឬកម្រៃផ្ទាល់ខ្លួន)

ចំពោះកម្រៃសម្រាប់រដ្ឋហត្ថលេខី ដែលផ្តល់ការការពារ វាអាចរួមបញ្ចូលទាំងកម្រៃសម្រាប់ការត្រួតពិនិត្យភាពថ្មីផងដែរ ប្រសិនបើរដ្ឋនោះទាមទារអោយបង់កម្រៃទាំងនេះ អាចត្រូវកំណត់ដោយច្បាប់នៃរដ្ឋនោះ ក៏ប៉ុន្តែចំនួននេះមិនអាចខ្ពស់ជាងចំនួនសមមូល ដែលការិយាល័យអន្តរជាតិនៃរដ្ឋហត្ថលេខី មានសិទ្ធិទទួលបានពីអ្នកដាក់ពាក្យសុំឱ្យការពារ ក្នុងរយៈពេលសមមូលតាមចំនួនតែមួយនៃគំនូរឧស្សាហកម្មឡើយ។ ហើយកម្រៃនេះត្រូវបញ្ជូនដោយការិយាល័យអន្តរជាតិ ទៅកាន់ភាគីហត្ថលេខីចំពោះកម្រៃដែលបានបង់។[70]

[70] មាត្រា៨ (១) និង៨ (២) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

ចំនួននៃកម្រៃដែលត្រូវបង់ គឺមានកំណត់នៅក្នុងតារាងកម្រៃ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ព្រមទាំងមានម៉ាស៊ីនគិតលេខដោយស្វ័យប្រវត្តិ ក្នុងការបង់កម្រៃនេះផងដែរ ដែលអាចរកបាននៅលើគេហទំព័ររបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

នៅពេលដែលកម្រៃត្រូវបានបង់ទៅការិយាល័យអន្តរជាតិ អ្នកដាក់ពាក្យសុំត្រូវតែបង្ហាញនូវគោលបំណងនៃការបង់កម្រៃនេះ រួមជាមួយព័ត៌មានដែលពាក់ព័ន្ធទៅនឹងពាក្យសុំ ហើយពត៌មាននោះត្រូវតែបញ្ចូលនៅដំណាក់កាលនៃពាក្យសុំអន្តរជាតិ ដែលមានឈ្មោះអ្នកដាក់ពាក្យសុំ និងគំនូរឧស្សាហកម្មដែលទាក់ទងទៅនឹងការបង់កម្រៃនោះ។

កម្រៃនេះ អ្នកដាក់ពាក្យសុំអាចបង់ ទៅកាន់ការិយាល័យអន្តរជាតិដោយផ្ទាល់តែម្តង។ ម្យ៉ាងវិញទៀត កម្រៃនេះអាចត្រូវបានបង់តាមរយៈការិយាល័យជាតិនៃរដ្ឋហត្ថលេខី ដោយអ្នកដាក់ពាក្យសុំ ប្រសិនបើពាក្យសុំនោះ ត្រូវបានបញ្ជូនដោយការិយាល័យជាតិនៃរដ្ឋហត្ថលេខី ហើយក្នុងករណីដែលការិយាល័យជាតិនោះ ទទួលយល់ព្រមក្នុងការប្រមូលកម្រៃនេះ និងបញ្ជូនកម្រៃនេះបន្តទៅការិយាល័យអន្តរជាតិ។ ក្នុងករណីនេះផងដែរ ការិយាល័យនៃរដ្ឋហត្ថលេខីនោះអាចទាមទារឱ្យអ្នកដាក់ពាក្យសុំ បង់កម្រៃបញ្ជូនមកឱ្យខ្លួន ចំពោះពាក្យសុំអន្តរជាតិណាមួយ ដែលបានដាក់តាមរយៈការិយាល័យជាតិខ្លួន ដើម្បីជាប្រយោជន៍ផ្ទាល់របស់ការិយាល័យជាតិនោះ។[71]

ជាងនេះទៅទៀត រាល់ការបង់កម្រៃទៅការិយាល័យអន្តរជាតិ គឺត្រូវតែបង់ជារូបិយប័ណ្ណស្វីស។ ការិយាល័យណាមួយដែលទទួលក្នុងការប្រមូល និងបញ្ជូនកម្រៃពីអ្នកដាក់ពាក្យសុំ ទៅការិយាល័យអន្តរជាតិ អាចប្រមូលជារូបិយប័ណ្ណប្រភេទណាពីអ្នកដាក់ពាក្យសុំក៏បានដែរ តែក្នុងការបញ្ជូនកម្រៃនោះទៅការិយាល័យអន្តរជាតិ ត្រូវតែបញ្ជូនជារូបិយប័ណ្ណស្វីសជាដាច់ខាត។

ទាក់ទងទៅនឹងបែបបទនៃការបង់កម្រៃ គឺអាចត្រូវបង់ទៅការិយាល័យអន្តរជាតិដោយៈ

១-ដោយការដកកម្រៃពីគណនីរបស់អ្នកដាក់ពាក្យសុំនោះ ចូលទៅក្នុងគណនីធនាគាររបស់ការិយាល័យអន្តរជាតិ ដែលអាចធ្វើតាមរយៈការបង់កម្រៃតាមប្រព័ន្ធអេឡិចត្រូនិច តាមប្រព័ន្ធមួយដែលមានឈ្មោះថា "អ៊ី-ផេមិន" (E-payment)។ ការធ្វើតាមវិធីនេះ គឺត្រូវតែមានកម្រៃគ្រប់គ្រាន់នៅក្នុងគណនីរបស់អ្នកដាក់ពាក្យសុំ ហើយប្រសិនបើកម្រៃនោះ មិនគ្រប់គ្រាន់សម្រាប់ការបង់លើកក្រោយទេ នោះការិយាល័យអន្តរជាតិ នឹងជូនដំណឹងទៅម្ចាស់គណនីនោះ អោយបានដឹងជាមុន។

២-ដោយការបង់ចូល ទៅក្នុងគណនីជាក់លាក់ណាមួយ នៃធនាគារស្វីស (Swiss postal account)

៣-ការបង់កម្រៃដោយប្រើប្រាស់កាតឥណទានជាដើម។

[71] មាត្រា៩ (២) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

ចំពោះអ្នកដាក់ពាក្យសុំ ឬការិយាល័យជាតិណាមួយ ដែលមានទំនាក់ទំនងជាញឹកញាប់ជាមួយនឹងការិយាល័យអន្តរជាតិ គួរណាតែបង្កើតអោយមាននូវគណនីផ្ទាល់ខ្លួនមួយ ជាមួយនឹងការិយាល័យអន្តរជាតិ ពីព្រោះថាការធ្វើបែបនេះ វាសម្រួលអោយមានភាពសាមញ្ញ និងងាយស្រួលក្នុងការបង់កម្រៃ ព្រមទាំងកាត់បន្ថយនូវហានិភ័យនៃការបង់កម្រៃយឺត ឬការបង់កម្រៃមិនត្រឹមត្រូវជាដើម។

ទាក់ទងទៅនឹងកាលបរិច្ឆេទនៃការបង់កម្រៃ គឺកម្រៃត្រូវបានចាត់ទុកថា បានបង់នៅកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិ បានទទួលកម្រៃគ្រប់ចំនួនដែលត្រូវបង់។

ក្នុងករណីកម្រៃត្រូវបានបង់ តាមរយៈការិយាល័យជាតិនៃរដ្ឋហត្ថលេខី នោះកាលបរិច្ឆេទសុពលភាព គឺចាប់ពីពេលដែលការិយាល័យជាតិទទួលបានកម្រៃនោះ ទោះវាពុំទាន់បានទៅដល់ការិយាល័យអន្តរជាតិក៏ដោយ។

**កថាខណ្ឌទី២ ទម្រង់នៃពាក្យសុំ**

ពាក្យសុំដើម្បីចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិ អាចសរសេរនៅលើក្រដាសតាមទម្រង់ពាក្យសុំជាផ្លូវការ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ឬអាចបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិចតាមរយៈប្រព័ន្ធមួយ ដែលមានឈ្មោះថា " អ៊ី-ហ្វាលលីង " (E-filing) ដែលយើងអាចរកបាននៅលើគេហទំព័រ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

**ក. ទម្រង់ជាផ្លូវការ**

ទម្រង់ជាផ្លូវការ ត្រូវបានបង្កើតឡើងដោយការិយាល័យអន្តរជាតិ។ ដូចបានរៀបរាប់ខាងលើ ទម្រង់ជាផ្លូវការ រាប់បញ្ចូលទាំងទម្រង់ជាក្រដាស និងតាមរយៈប្រព័ន្ធអេឡិចត្រូនិច (អ៊ី-ហ្វាលលីង)។

ជាងនេះទៅទៀត ដោយផ្លាស់ប្តូរពីការប្រើប្រាស់ទម្រង់ពាក្យសុំ ដែលបង្កើតឡើងដោយការិយាល័យអន្តរជាតិនៃរដ្ឋហត្ថលេខី អ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ឬម្ចាស់សិទ្ធិគំនូរឧស្សាហកម្ម អាចបង្កើតទម្រង់ដោយខ្លួនឯងបាន។ ការបង្កើតទម្រង់ផ្ទាល់ខ្លួននេះ អាចនឹងត្រូវបានទទួលយកដោយការិយាល័យអន្តរជាតិ លុះត្រាតែទម្រង់នោះ មានចំនុចដែលគេតម្រូវដូចគ្នា ទៅនឹងទម្រង់ដែលបង្កើតឡើងដោយការិយាល័យអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ទម្រង់ផ្ទាល់ខ្លួនបែបនេះ គឺមិនត្រូវបានតម្រូវអោយមានការដកឃ្លា ឬក៏ទំហំប៉ុនគ្នា ទៅនឹងការបង្កើតឡើងដោយការិយាល័យអន្តរជាតិនោះទេ។

ហើយចំនុចសំខាន់ៗនៃទម្រង់ផ្លូវការនោះមានដូចជាៈ

-ទម្រង់នេះត្រូវតែសរសេរនៅលើក្រដាសA4 ហើយសរសេរតែមួយចំហៀងប៉ុណ្ណោះ

-ទម្រង់នេះត្រូវតែមានចំនួន និងចំណងជើង ទៅតាមលំដាប់លំដោយដូចគ្នា ទៅនឹងទម្រង់ដែលបង្កើតដោយការិយាល័យអន្តរជាតិ

-ប្រសិនបើចំនុចណាមួយ នៅក្នុងទម្រង់ផ្លូវការរបស់ការិយាល័យអន្តរជាតិ មិនត្រូវបានយកមកប្រើប្រាស់ ឬមិនឆ្លើយតប នោះវាពុំត្រូវបានលុបចោលនោះទេ តែត្រូវបង្ហាញថា ចំនុចណាមួយមិនត្រូវបានប្រើប្រាស់ ឬមិនឆ្លើយតប។

ទន្ទឹមនឹងនេះផងដែរ ផលប្រយោជន៍នៃការបង្កើតទម្រង់ដោយខ្លួនឯងបែបនេះ គឺវាមាននៅសល់ចន្លោះទំនេរច្រើន ដើម្បីបន្ថែមចំនុចដែលគេតម្រូវ។ ឧទាហរណ៍ នៅពេលដែលពាក្យសុំចុះបញ្ជីជាអន្តរជាតិមួយ មានឈ្មោះអ្នកដាក់ពាក្យសុំច្រើន ឬក៏មានគំនូរឧស្សាហកម្មច្រើន នោះការប្រើប្រាស់ទម្រង់បែបនេះ គឺអាចជៀសវាងការបន្តសន្លឹកទៅខាងក្រោយ។

ម្យ៉ាងវិញទៀត នៅពេលដែលចន្លោះទំនេរសម្រាប់បំពេញចំនុចណាមួយមិនគ្រប់គ្រាន់ នោះគេអាចបន្តសន្លឹកទៀតបាន ហើយនៅលើសន្លឹកបន្តនោះ ចាំបាច់ត្រូវតែបង្ហាញអំពីលេខនៃចំនុចដែលត្រូវបន្តជាដើម ហើយពត៌មានដែលត្រូវបង្ហាញនៅលើសន្លឹកបន្ត ត្រូវតែដូចគ្នាទៅនឹងពត៌មានដែលត្រូវបង្ហាញ នៅក្នុងសន្លឹកដើមនៃទម្រង់នោះផងដែរ។ លើសពីនេះ ចំនួនសន្លឹកបន្តដែលប្រើប្រាស់ គួរតែត្រូវបង្ហាញនៅក្នុងប្រអប់ដែលបានផ្តល់អោយ នៅចំនុចចាប់ផ្តើមនៃទម្រង់នេះ។

លើសពីនេះទៅទៀត រាល់ការបង្ហាញកាលបរិច្ឆេទនៃទម្រង់ជាផ្លូវការ ត្រូវតែសរសេរថ្ងៃ និងខែជាលេខពីរខ្ទង់ អមដោយឆ្នាំដែលនឹងត្រូវសរសេរជាលេខបួនខ្ទង់ ហើយលេខទាំងអស់ត្រូវតែសរសេរជាលេខអារ៉ាប់ និងត្រូវខណ្ឌចែកពីគ្នាដោយសញ្ញាស្លាស(/)។

**ខ. ទម្រង់មិនផ្លូវការ**

បន្ថែមទៅលើទម្រង់ជាផ្លូវការ ទម្រង់មិនផ្លូវការមួយចំនួនត្រូវបានទទួលយក។ ឧទាហរណ៍សម្រាប់ការចុះបញ្ជីសារឡើងវិញជាដើម។ ការប្រើប្រាស់ទម្រង់មិនផ្លូវការនេះ ពុំមែនជាកាតព្វកិច្ចទេ តែទោះជាយ៉ាងណា ទម្រង់នេះត្រូវបានបង្កើតឡើងដោយការិយាល័យអន្តរជាតិ ដើម្បីបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់។

## ផ្នែកទី២៖ នីតិវិធីមុន និងបន្ទាប់ទទួលបានការការពារ

### កថាខណ្ឌទី១ នីតិវិធីមុនទទួលបានការការពារ

**ក. ការបញ្ជូនពាក្យសុំ**

ការបញ្ជូនពាក្យសុំអាចធ្វើដោយផ្ទាល់ ឬមិនផ្ទាល់ទៅការិយាល័យអន្តរជាតិ។

**ក.១ ការបញ្ជូនដោយផ្ទាល់ទៅការិយាល័យអន្តរជាតិ**

ក្នុងករណីនេះ អ្នកដាក់ពាក្យសុំ ត្រូវបានណែនាំអោយត្រួតពិនិត្យអោយច្បាស់លាស់ថា ច្បាប់នៃរដ្ឋហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ មិនតម្រូវអោយមាននីតិវិធីត្រួតពិនិត្យ ដែលត្រូវធ្វើឡើងដោយការិយាល័យជាតិនៃរដ្ឋហត្ថលេខីមុននោះទេ។

**ក.២ ការបញ្ជូនដោយមិនផ្ទាល់ទៅការិយាល័យអន្តរជាតិ**

ការបញ្ជូនពាក្យសុំ គឺអាចបញ្ជូនបានតាមរយៈការិយាល័យជាតិនៃរដ្ឋហត្ថលេខី នៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ក្នុងករណីភាគីហត្ថលេខីណាមួយ មិនបានជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាសថា សំណុំលិខិតស្នើសុំអន្តរជាតិ មិនអាចដាក់តាមរយៈការិយាល័យរបស់ខ្លួន ឬក៏បញ្ជូនទៅការិយាល័យអន្តរជាតិ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកដោយផ្ទាល់តែម្តង។[72]

ស្ថិតនៅក្រោមច្បាប់ឆ្នាំ១៩៦០ ប្រសិនបើរដ្ឋហត្ថលេខី តម្រូវអោយបញ្ជូនឯកសារមកការិយាល័យខ្លួនជាមុន នោះរដ្ឋនោះនឹងត្រូវបានគេចាត់ទុកថាជារដ្ឋដើម ហើយពាក្យសុំចុះបញ្ជីជាអន្តរជាតិ ត្រូវតែបញ្ជូនទៅការិយាល័យនោះ។ នៅក្នុងករណីបែបនេះ គឺគេទទួលតែពាក្យសុំដែលសរសេរនៅលើក្រដាសតែប៉ុណ្ណោះ។

ជាងនេះទៅទៀត ប្រសិនបើមានការអនុញ្ញាតឲ្យបញ្ជូនមិនផ្ទាល់ នោះអ្នកដាក់ពាក្យសុំនឹងត្រូវបានគេជូនដំណឹងថា អ្នកដាក់ពាក្យសុំត្រូវតែបង់កម្រៃ នូវរាល់ពាក្យសុំដែលបញ្ជូនទៅឲ្យការិយាល័យអន្តរជាតិជាតិ។

ការបញ្ជូនពាក្យសុំដោយមិនផ្ទាល់ អាចប៉ះពាល់ទៅដល់កាលបរិច្ឆេទ នៃការបញ្ជូនពាក្យសុំអន្តរជាតិ។

**ខ. ការទំនាក់ទំនងជាមួយនឹងការិយាល័យអន្តរជាតិ**

ការទំនាក់ទំនងខាងក្រោមនេះ ជានីតិវិធីអន្តរជាតិដែលមានដូចជា៖

១-ការទំនាក់ទំនងរវាងការិយាល័យអន្តរជាតិ និងការិយាល័យជាតិនៃរដ្ឋហត្ថលេខី

២-ការទំនាក់ទំនងរវាងការិយាល័យអន្តរជាតិ ជាមួយនឹងអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ ឬអ្នកតំណាង

៣-ការទំនាក់ទំនងរវាងអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ ជាមួយការិយាល័យនៃរដ្ឋហត្ថលេខី។ តែការទំនាក់ទំនងនេះ គឺស្ថិតនៅក្រៅប្រព័ន្ធឡាអេ ពីព្រោះការទំនាក់ទំនងបែបនេះ អាស្រ័យទៅលើច្បាប់ និងការអនុវត្តរបស់រដ្ឋហត្ថលេខីដែលពាក់ព័ន្ធតែប៉ុណ្ណោះ។

[72] មាត្រា៤ (១) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០ និងច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម។

ការទំនាក់ទំនងដែលធ្វើដោយអ្នកដាក់ពាក្យសុំ ឬអ្នកកាន់កាប់ ឬការិយាល័យជាតិនៃរដ្ឋហត្ថលេខី ទៅកាន់ការិយាល័យអន្តរជាតិ គឺត្រូវតែវាយដោយកុំព្យូទ័រ ឬក៏ព្រីនចេញ។ ហើយចំពោះការទំនាក់ទំនងដែលសរសេរដោយដៃ គឺពុំត្រូវបានទទួលយកនោះទេ។ លើសពីនេះទៅទៀត ការទំនាក់ទំនងទាំងនេះ ត្រូវតែចុះហត្ថលេខា ដែលហត្ថលេខាទាំងនោះ គឺអាចចុះដោយដៃ ព្រីន ឬក៏ជំនួសដោយការបិតតែម ឬបោះត្រាជាដើម។ ការចុះហត្ថលេខា ត្រូវតែធ្វើតាមការកំណត់របស់ការិយាល័យអន្តរជាតិ ហើយចំពោះករណីមួយចំនួនទៀត ការចុះហត្ថលេខាអាចធ្វើឡើងក្រោមការព្រមព្រៀងរវាងការិយាល័យអន្តរជាតិ និងរដ្ឋហត្ថលេខីដែលពាក់ព័ន្ធ។

ទន្ទឹមនឹងនេះផងដែរ ការទំនាក់ទំនងនេះ គឺអាចបញ្ជូនដោយផ្ទាល់ទៅការិយាល័យអន្តរជាតិ តាមរយៈប្រៃសនីយ៍ ឬក៏អាចធ្វើតាមប្រព័ន្ធអេឡិចត្រូនិច ដែលអាចរកបាននៅលើគេហទំព័ររបស់អង្គការកម្មសិទ្ធិពិភពលោក។

**ខ.១ ទំនាក់ទំនងបញ្ជូនតាមរយៈប្រៃសនីយ៍**

ការទំនាក់ទំនងមួយចំនួន អាចត្រូវបានបញ្ជូនទៅកាន់ការិយាល័យអន្តរជាតិ តាមរយៈប្រៃសនីយ៍ ឬសេវាកម្មបញ្ជូនដទៃទៀត។

ប្រសិនបើមានឯកសារច្រើន ត្រូវបានបញ្ជូនតាមប្រៃសនីយ៍ ទៅការិយាល័យអន្តរជាតិនៅក្នុងស្រោមសំបុត្រតែមួយ ឯកសារនោះត្រូវតែអមដោយបញ្ជីមួយ ដែលកំណត់អត្តសញ្ញាណនៃឯកសារនីមួយៗ ដើម្បីជៀសវាងការភ័ន្តច្រលំ។ បន្ទាប់មកការិយាល័យអន្តរជាតិ ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ដើម្បីជាការបញ្ជាក់អំពីឯកសារនីមួយៗ ទៅតាមបញ្ជីដែលបានផ្ញើជូន។

**ខ.២ ទំនាក់ទំនងតាមរយៈទូរសារ**

ឯកសារមួយចំនួន អាចត្រូវបានបញ្ជូនទៅកាន់ការិយាល័យអន្តរជាតិ បានតាមរយៈទូរសារ ហើយមានអានុភាព ចាប់ពីពេលដែលការិយាល័យអន្តរជាតិបានទទួល។ ក៏ប៉ុន្តែនៅក្នុងករណីដែលមានរូបថត ឬគំនូសតាងនៃគំនូរឧស្សាហកម្មណាមួយ ដែលត្រូវចុះផ្សាយជាពណ៌ នោះគេពុំអាចបញ្ជូនតាមរយៈមធ្យោបាយនេះបានទេ ដោយសារតែការបញ្ជូនតាមរយៈទូរសារ គឺពុំត្រូវបានអនុញ្ញាត សម្រាប់កំណត់សម្គាល់ណាមួយជាពណ៌នោះទេ។

ដូចនេះ គំនូរឧស្សាហកម្មណាមួយ ដែលត្រូវចុះផ្សាយជាពណ៌ ហើយបានបញ្ជូនតាមរយៈទូរសារ គឺពុំមានអានុភាព ចាប់ពីកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិ ទទួលពាក្យសុំនោះ។ ផ្ទុយទៅវិញ ប្រសិនបើគំនូរឧស្សាហកម្មនោះ មានពណ៌ស ឬខ្មៅ នោះពាក្យសុំនឹងមានអានុភាពចាប់ពីពេលដែលការិយាល័យទទួលបាន ប្រសិនបើពាក្យសុំចុះបញ្ជីជាអន្តរជាតិដើម និងគំនូរដើមត្រូវបានទទួលដោយការិយាល័យអន្តរជាតិ មុនផុតកំណត់ ២០ថ្ងៃ ចាប់ពីថ្ងៃធ្វើការបញ្ជូនតាមរយៈទូរសារ។

បន្ទាប់ពីឯកសារត្រូវបានបញ្ជូនទៅដល់ ការិយាល័យអន្តរជាតិត្រូវជូនដំណឹង អំពីការបានទទួល ទៅអ្នកដាក់ពាក្យសុំភ្លាមៗ ហើយការជូនដំណឹងនេះ ត្រូវបានធ្វើតាមរយៈទូរសារត្រឡប់ទៅវិញផងដែរ។ លើសពីនេះទៅទៀត ការិយាល័យអន្តរជាតិ ក៏ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំផងដែរ ក្នុងករណីឯកសារនោះមានភាពខ្វះចន្លោះ ឬមិនស្របច្បាប់ណាមួយជាដើម។

ទន្ទឹមនឹងនេះផងដែរ យើងឃើញថា ប្រសិនបើការទំនាក់ទំនង ត្រូវបានគេតម្រូវអោយធ្វើតាមទម្រង់ជាផ្លូវការ នោះមានន័យថាត្រូវតែបញ្ជូនតាមរយៈទូរសារ។

យ៉ាងណាមិញ កាលបរិច្ឆេទនៃទំនាក់ទំនងអ្នកដាក់ពាក្យសុំ និងការិយាល័យអន្តរជាតិ អាចខុសគ្នា ដូចនេះ កាលបរិច្ឆេទដែលត្រូវយកមកគិត គឺកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិ បានទទួលការទំនាក់ទំនងនោះ។

**ខ.៣ ទំនាក់ទំនងតាមរយៈប្រព័ន្ធអេឡិចត្រូនិច**

ការទំនាក់ទំនងរវាងអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ ឬការិយាល័យជាតិជាមួយនឹងការិយាល័យអន្តរជាតិ រួមបញ្ចូលទាំងសេចក្តីអធិប្បាយនៃពាក្យសុំ អាចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយអេឡិចត្រូនិច។ លើសពីនេះទៅទៀត ការទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិច អាចធ្វើឡើងតាមការព្រមព្រៀងគ្នារវាងការិយាល័យអន្តរជាតិ និងការិយាល័យជាតិដែលពាក់ព័ន្ធ។ ហើយការិយាល័យជាតិណាមួយ ដែលមានបំណងចង់អោយមានការទំនាក់ទំនង តាមរយៈប្រព័ន្ធអេឡិចត្រូនិច ត្រូវបង្ហាញជូនការិយាល័យអន្តរជាតិ អំពីអាសយដ្ឋានសារអេឡិចត្រូនិច ដែលត្រូវផ្ញើចូលមកការិយាល័យជាតិរបស់ខ្លួន។

ហើយមិនខុសពីការទំនាក់ទំនង តាមរយៈទូរសារនោះទេ កាលបរិច្ឆេទប្រសិទ្ធិភាពនៃទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិចនេះ គឺគិតចាប់ពីពេលដែលការិយាល័យអន្តរជាតិទទួលបានការទំនាក់ទំនងនោះ។ បន្ទាប់ពីនេះ ការិយាល័យអន្តរជាតិ ត្រូវតែជូនដំណឹងទៅអ្នកផ្ញើភ្លាមៗ អំពីការបានទទួល និងផ្តល់ពត៌មានអំពីភាពខ្វះចន្លោះនៃការបញ្ជូននោះ។

**គ. ការតំណាងនៅមុខការិយាល័យអន្តរជាតិ**

ដូចដែលយើងបានដឹងមកហើយថា ពាក្យសុំចុះបញ្ជីជាអន្តរជាតិ អាចត្រូវបានបញ្ជូនទៅការិយាល័យអន្តរជាតិដោយផ្ទាល់តែម្តង។ ហើយអ្នកដាក់ពាក្យសុំក៏អាចចាត់អោយមានអ្នកតំណាងដើម្បីធ្វើសកម្មភាពជំនួសគាត់ នៅពីមុខការិយាល័យអន្តរជាតិបានផងដែរ។

ចំពោះការអនុវត្តប្រព័ន្ធឡាអេ គឺទាក់ទងតែការតំណាង នៅពីមុខការិយាល័យអន្តរជាតិតែប៉ុណ្ណោះ។ ចំណែកឯការចាត់តាំងអ្នកតំណាង នៅចំពោះមុខការិយាល័យនៃរដ្ឋហត្ថលេខី គឺស្ថិតនៅក្រៅប្រព័ន្ធឡាអេ តែវាស្ថិតនៅលើច្បាប់ និងការអនុវត្តរបស់រដ្ឋហត្ថលេខីដែលពាក់ព័ន្ធ។

ទាក់ទងទៅនឹងអ្នកតំណាង ដែលត្រូវចាត់តាំងនៅចំពោះមុខការិយាល័យអន្តរជាតិ ប្រព័ន្ធឡាអេ គឺមិនតម្រូវអោយមានជំនាញ សញ្ញាតិ ឬលំនៅដ្ឋានអ្វីនោះទេ។

លើសពីនេះទៀត រាល់ការទំនាក់ទំនងដែលធ្វើដោយអ្នកតំណាង គឺមានអានុភាពដូចគ្នាទៅនឹងការទំនាក់ទំនង ដែលធ្វើដោយអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិទៅកាន់ការិយាល័យអន្តរជាតិ។ ស្រដៀងគ្នានេះដែរ នៅក្នុងករណីដែលអវត្តមានអ្នកតំណាង នោះការិយាល័យអន្តរជាតិ អាចបញ្ជូននូវរាល់ទំនាក់ទំនងទៅអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិបាន។

ជាទូទៅ នៅពេលដែលអ្នកតំណាងត្រូវបានចាត់តាំង ការិយាល័យអន្តរជាតិ អាចបញ្ជូននូវការទំនាក់ទំនងទៅកាន់អ្នកតំណាងនោះតែម្តង តែក៏មានករណីលើកលែងមួយចំនួនផងដែរដូចជា៖

-នៅពេលដែលមានការលុបចោល នៃការចាត់តាំងអ្នកតំណាង ការិយាល័យអន្តរជាតិជូនដំណឹងទៅទាំងអ្នកដាក់ពាក្យសុំចុះបញ្ជី ឬម្ចាស់សិទ្ធិគំនូរឧស្សាហកម្ម និងអ្នកតំណាង

-ក្នុងរយៈពេល ៦ខែ មុនផុតកំណត់នៃរយៈពេល ៥ឆ្នាំ នៃការការពារ ការិយាល័យអន្តរជាតិផ្ញើការរាយការណ៍មិនផ្លូវការមួយទៅអ្នកកាន់កាប់ និងអ្នកតំណាងរបស់គាត់

- នៅពេលដែលមានការបង់កម្រៃមិនបានគ្រប់គ្រាន់ សម្រាប់ការចុះបញ្ជីសារឡើងវិញនោះការិយាល័យអន្តរជាតិ រាយការណ៍ទៅអ្នកកាន់កាប់ និងអ្នកតំណាងរបស់គាត់។

### គ.១ នៅក្នុងពាក្យសុំអន្តរជាតិ

អ្នកតំណាងអាចត្រូវបានចាត់តាំង នៅក្នុងការដាក់ពាក្យសុំអន្តរជាតិ ដោយបង្ហាញនូវឈ្មោះ និងអាសយដ្ឋាននៃអ្នកតំណាងនោះ នៅក្នុងចំនុចទី៥ នៃទម្រង់ពាក្យសុំចុះបញ្ជីជាអន្តរជាតិ ឬនៅក្នុងផ្នែកស្រដៀងនេះ ( corresponding section ) នៃអ៊ី-ហ្វាលលីង។ ដើម្បីអោយការចាត់តាំងជាមួយនឹងអ្នកតំណាងនោះមានប្រសិទ្ធិភាព អ្នកដាក់ពាក្យសុំនោះត្រូវតែចុះហត្ថលេខា និងមានការទទួលដឹងឮពីមេធាវីផងដែរ។

### គ.២ នៅក្នុងសំណើនៃការផ្លាស់ប្តូរ

អ្នកតំណាងអាចត្រូវបានចាត់តាំង ក្នុងករណីដែលមានសំណើនៃការផ្លាស់ប្តូរ ដូចជាការផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋាននៃម្ចាស់សិទ្ធីជាដើម។ ហើយគួរតែមាននូវឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាង អមជាមួយនឹងការទទួលស្គាល់ដោយមេធាវីផងដែរ ដើម្បីអោយការតំណាងនោះមានប្រសិទ្ធិភាព។ យ៉ាងណាមិញ គេពុំទទួលយកសំណើនៃការផ្លាស់ប្តូរនេះ តាមរយៈការបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិចនោះទេ។

### គ.៣ ការចាត់តាំងនៅក្នុងទំនាក់ទំនងផ្សេងទៀត

ការចាត់តាំងអ្នកតំណាង អាចត្រូវបានធ្វើឡើងនៅក្នុងទំនាក់ទំនងផ្សេងទៀត ក្រៅពីទំនាក់ទំនងទាំងពីរខាងលើ។ ទំនាក់ទំនងមួយនេះ ត្រូវតែចុះហត្ថលេខាដោយម្ចាស់សិទ្ធិ។

ការទំនាក់ទំនងអាចធ្វើតាមរយៈសំបុត្រធម្មតា ដោយគ្រាន់តែបង្ហាញយ៉ាងច្បាស់លាស់អំពីបុគ្គលដែលធ្វើការចាត់តាំង ក៏ដូចជាឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលត្រូវបានគេចាត់តាំង និងពាក្យសុំចុះបញ្ជីជាអន្តរជាតិ ឬការចុះបញ្ជីដែលពាក់ព័ន្ធ។ ទោះបីវាពុំមែនជាកាតព្វកិច្ចក៏ដោយ ក៏ការិយាល័យអន្តរជាតិបានបង្កើតនូវទម្រង់មិនផ្លូវការមួយ ដើម្បីជាភាពងាយស្រួលដល់អ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ។

ការចាត់តាំងបែបនេះ អាចទាក់ទងទៅនឹងពាក្យសុំចុះបញ្ជីជាអន្តរជាតិ ដែលអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ ឬអ្នកតំណាងត្រូវបង្ហាញអោយបានច្បាស់លាស់។

ក្រៅពីនេះ ទាក់ទងទៅនឹងបញ្ហាអ្នកតំណាង គឺនៅមានចំនុចផ្សេងៗជាច្រើនទៀតដែលពាក់ព័ន្ធ ចំនុចទាំងនោះមានដូចជា៖

- **អ្នកតំណាងតែម្នាក់៖** មានតែអ្នកតំណាងតែម្នាក់គឺគ្រប់គ្រាន់ហើយ សម្រាប់ធ្វើសកម្មភាពជំនួសឱ្យអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ។ ហើយនៅក្នុងករណីដែលមានអ្នកតំណាងច្រើននាក់ នោះត្រូវបានបង្ហាញដូចគ្នានៅក្នុងពាក្យសុំ ឬការចុះបញ្ជីជាអន្តរជាតិ។ អ្នកតំណាងដែលបង្ហាញដំបូងគេនៅក្នុងពាក្យសុំ ឬការចុះបញ្ជីជាអន្តរជាតិ ត្រូវបានគេចាត់ទុកថា បានចាត់តាំង។ ឧទាហរណ៍ នៅពេលដែលក្រុមហ៊ុនមេធាវីត្រូវបានចាត់តាំង នោះត្រូវបានគេចាត់ទុកថា ជាអ្នកតំណាងតែម្នាក់គត់។

- **ការចាត់តាំងដែលមិនត្រឹមត្រូវ៖** នៅពេលការចាត់តាំងអ្នកតំណាងមិនឆ្លើយតបទៅនឹងលក្ខខណ្ឌដែលគេតម្រូវ ការិយាល័យអន្តរជាតិចាត់ទុកការចាត់តាំងនេះថា ជាការចាត់តាំងដែលមិនត្រឹមត្រូវ ហើយការិយាល័យអន្តរជាតិ នឹងផ្ញើនូវការទំនាក់ទំនងដែលពាក់ព័ន្ធ ទៅកាន់អ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ ឬអ្នកតំណាង ដែលធ្លាប់ត្រូវបានគេចាត់តាំងពីមុន ប្រសិនបើការកែតម្រូវកំហុសមិនបានធ្វើឡើង។

- **ការថតចម្លង និងប្រកាសអំពីការចាត់តាំង៖** ប្រសិនបើការចាត់តាំងអ្នកតំណាងឆ្លើយតបទៅនឹងអ្វីដែលគេតម្រូវ ការិយាល័យអន្តរជាតិថតចម្លងអំពីការពិតនោះ ជាមួយនឹងឈ្មោះ និងអាសយដ្ឋាននៃអ្នកតំណាង និងអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិនៅក្នុងការចុះឈ្មោះជាអន្តរជាតិ។

- **ការលុបចោលការតំណាង:** ការថតចម្លងនូវអ្នកតំណាង ត្រូវបានលុបចោលនៅពេលដែលទទួលបាននូវសំណើមួយ ដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ ឬអ្នកតំណាងនោះផ្ទាល់តែម្តង។ សំណើនៃការលុបចោលនេះ អាចធ្វើតាមមធ្យោបាយពីរ គឺនៅលើសំបុត្រធម្មតា ឬនៅលើទម្រង់មិនផ្លូវការ DM/9 នៃទម្រង់អ៊ី-ហ្វាលលីង។

ការលុបចោលនឹងមានប្រសិទ្ធិភាព នៅពេលកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិទទួលបានការទំនាក់ទំនងដែលនាំទៅរកការលុបចោលនោះ។

**ឃ. ការត្រួតពិនិត្យជាផ្លូវការដោយការិយាល័យអន្តរជាតិ**

ក្រោយពីទទួលបាននូវពាក្យសុំចុះបញ្ជីជាអន្តរជាតិ ការិយាល័យអន្តរជាតិត្រូវត្រួតពិនិត្យថា តើពាក្យសុំនោះបំពេញគ្រប់លក្ខខណ្ឌជាផ្លូវការដែលតម្រូវហើយឬនៅ មានដូចជា គុណភាពនៃគំនូរ (គ្រប់ជ្រុងជ្រោយ ឬនៅ) និងការបង់កម្រៃដែលគេតម្រូវជាដើម។ ទន្ទឹងនឹងនេះ នៅពេលដែលបានពិនិត្យឃើញថា ពាក្យសុំនេះមិនត្រឹមត្រូវទេ អ្នកដាក់ពាក្យសុំត្រូវបានគេផ្តល់ពត៌មានឲ្យ ដោយការិយាល័យអន្តរជាតិ នូវរាល់កំហុសទាំងឡាយដែលត្រូវតែកែតម្រូវ នៅក្នុងរយៈពេលបានកំណត់ជាក់លាក់មួយ ដែលជាទូទៅគឺ ៣ខែ ហើយប្រសិនបើពុំកែតម្រូវកំហុស ក្នុងរយៈពេលកំណត់ទេ នោះពាក្យសុំ ត្រូវបានគេចាត់ទុកថា ត្រូវបានបោះបង់ចោល។

ការិយាល័យអន្តរជាតិពុំធ្វើការវាយតម្លៃ ឬត្រួតពិនិត្យភាពថ្មីនៃគំនូរនោះទេ ហើយក៏ពុំមានសិទ្ធិបដិសេធចោល នូវពាក្យសុំចុះបញ្ជីជាអន្តរជាតិណាមួយ ដែលទាក់ទងទៅនឹងបញ្ហានេះដែរ ពីព្រោះការត្រួតពិនិត្យនេះ គឺត្រូវធ្វើឡើងដោយការិយាល័យជាតិនៃរដ្ឋហត្ថលេខីនីមួយៗ។

បើពិនិត្យឃើញថា ពុំមានកំហុសទេ ការិយាល័យអន្តរជាតិត្រូវចុះបញ្ជីគំនូរឧស្សាហកម្មភ្លាម នៅពេលដែលទទួលបានពាក្យសុំ ឬនៅពេលមានការស្នើសុំឱ្យធ្វើការកែតម្រូវ។ បន្ទាប់ពីបានទទួលការកែតម្រូវដែលបានស្នើសុំ ការិយាល័យអន្តរជាតិត្រូវធ្វើការចុះបញ្ជីគំនូរឧស្សាហកម្មភ្លាមដែរ។[73] ហើយការិយាល័យអន្តរជាតិត្រូវទទួលចុះបញ្ជី ទោះបីជាមាន ឬគ្មានការពន្យារចុះផ្សាយក៏ដោយ។[74] បន្ទាប់ពីបានចុះបញ្ជីភ្លាម ការិយាល័យអន្តរជាតិ ត្រូវផ្ញើច្បាប់ចម្លងនៃការចុះបញ្ជីអន្តរជាតិ ជាមួយនឹងសេចក្តីអះអាងដែលពាក់ព័ន្ធ ឯកសារ ឬរូបសំណាកដែលបានភ្ជាប់ក្នុងពាក្យសុំអន្តរជាតិ ទៅការិយាល័យជាតិនីមួយៗ ដែលបានជូនដំណឹងមកកាន់ការិយាល័យអន្តរជាតិថា ការិយាល័យជាតិខ្លួនចង់បានច្បាប់ចម្លងនេះ ហើយការិយាល័យនេះត្រូវបានជ្រើសរើសក្នុងពាក្យសុំអន្តរជាតិ។[75]

**ង. ការត្រួតពិនិត្យពាក្យសុំដោយការិយាល័យជាតិនៃរដ្ឋហត្ថលេខី**

ចំពោះការចុះបញ្ជីជាអន្តរជាតិនៅក្នុងព្រឹត្តិបត្រ ការិយាល័យជាតិនៃរដ្ឋហត្ថលេខី អាចបន្តការត្រួតពិនិត្យ ទៅតាមការកំណត់របស់ច្បាប់ជាតិរបស់ខ្លួនបាន។ ជាមួយគ្នានេះដែរ ជាលក្ខណៈពិសេសនៃប្រព័ន្ធឡាអេ ដែលអនុញ្ញាតអោយរដ្ឋហត្ថលេខីនីមួយៗ មានសិទ្ធិបដិសេធទៅលើការការពារណាមួយនៅក្នុងដែនដីរបស់ខ្លួន ចំពោះគំនូរឧស្សាហកម្មទាំងឡាយណា ដែលមិនបំពេញនូវលក្ខខណ្ឌនៃការការពារ ដែលផ្តល់អោយដោយច្បាប់ជាតិរបស់រដ្ឋហត្ថលេខីនោះ។ ជាពិសេសគឺ

[73] មាត្រា៨ នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម០២ កក្កដា ១៩៩៩។

[74] មាត្រា១១ នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម០២ កក្កដា ១៩៩៩។

[75] មាត្រា១០ (១) និងមាត្រា១០ (៥)នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម០២ កក្កដា ១៩៩៩។

ពាក់ព័ន្ធទៅនឹងខ្លឹមសារបន្ថែមនៃសំណុំលិខិតស្នើសុំអន្តរជាតិដែលច្បាប់កំណត់ [76] ឬតាមការប្តឹងជំទាស់ពីភាគីទីបី។[77] យ៉ាងណាមិញ ការបដិសេធរបស់ការិយាល័យជាតិនៃរដ្ឋហត្ថលេខី មិនអាចសំអាងទៅលើការមិនគោរពលក្ខខណ្ឌនៃទម្រង់ជាផ្លូវការនោះទេ ព្រោះការត្រួតពិនិត្យលើទម្រង់នេះគឺត្រូវបានធ្វើដោយការិយាល័យអន្តរជាតិរួចរាល់អស់ហើយ។

ជាងនេះទៅទៀត រដ្ឋហត្ថលេខីក៏អាចបដិសេធក្នុងការផ្តល់ការការពារផងដែរ ប្រសិនបើអ្នកដាក់ពាក្យសុំ មិនបានកែតម្រូវកំហុស តាមការអញ្ជើញតាមពេលកំណត់ទេ ហើយពាក្យសុំត្រូវបានចាត់ទុកថាមិនបានកំណត់អំពីការជ្រើសរើសភាគីហត្ថលេខីនោះទេ។[78]

ម្យ៉ាងវិញទៀត រាល់ការបដិសេធនូវការផ្តល់ការការពារ ត្រូវតែជូនដំណឹងទៅការិយាល័យអន្តរជាតិក្នុងរយៈពេល៦ខែ ចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយការចុះបញ្ជីជាអន្តរជាតិ នៅលើគេហទំព័ររបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ ក៏ប៉ុន្តែ ក្រោមច្បាប់ឆ្នាំ១៩៩៩ បានកំណត់ថារាល់ការិយាល័យជាតិទាំងឡាយណា ដែលជាការិយាល័យត្រួតពិនិត្យភាពថ្មី អាចផ្តល់លទ្ធភាពបដិសេធក្នុងការការពារ និងជូនដំណឹងទៅការិយាល័យអន្តរជាតិថា រយៈពេលបដិសេធ៦ខែ ត្រូវបានជំនួសដោយ១២ខែ វិញ។ ប្រសិនបើ មិនបានជូនដំណឹងអំពីការបដិសេធក្នុងរយៈពេលនេះទេការតម្កល់ជាអន្តរជាតិ ត្រូវតែមានអានុភាពនៅក្នុងរដ្ឋនោះ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់។ រយៈពេល៦ខែ នេះ ត្រូវគិតចាប់ពីកាលបរិច្ឆេទ ដែលការិយាល័យជាតិទទួលបានការចុះផ្សាយនៅក្នុងព្រឹត្តិបត្រ ដែលមានចុះផ្សាយនូវការចុះបញ្ជីតម្កល់គំនូរជាអន្តរជាតិ។ ស្របពេលជាមួយគ្នានេះដែរ ការិយាល័យជាតិ ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនេះ ទៅអ្នកដាក់ពាក្យសុំ។[79]

រាល់ការបដិសេធនឹងមានអានុភាព ទៅលើតែដែនដីនៃរដ្ឋហត្ថលេខី ដែលការិយាល័យជាតិនោះបដិសេធតែប៉ុណ្ណោះ។

បន្ថែមពីលើនេះទៀត ការប្រកាសមោឃភាព ឬបដិសេធអំពីអានុភាពលើផ្នែកណាមួយ ឬទាំងអស់នៃការចុះបញ្ជីជាអន្តរជាតិ នៅក្នុងដែនដីរបស់រដ្ឋហត្ថលេខី ដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីជ្រើសរើស មិនអាចប្រកាសបាន ដោយគ្មានទុកឱកាសសមរម្យឱ្យម្ចាស់សិទ្ធិមានលទ្ធភាព ក្នុងការការពារសិទ្ធិរបស់ខ្លួននោះទេ។[80]

ដូចនេះ ទន្ទឹមនឹងការមានសិទ្ធិបដិសេធរបស់ការិយាល័យជាតិណាមួយ អ្នកដាក់ពាក្យសុំក៏មានសិទ្ធិដូចគ្នាផងដែរ គឺគាត់អាចបញ្ជូនសំណួរដោយផ្ទាល់ទៅការិយាល័យជាតិនោះ ទាក់ទងទៅ

[76] មាត្រា ៥ (២) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩។

[77] មាត្រា៨ ចំណុច (១) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[78] មាត្រា៨ ចំណុច (២) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

[79] មាត្រា៨ (២) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[80] មាត្រា១៥ នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

នឹងការបដិសេធ។ ហើយនីតិវិធីបន្ទាប់ ទាក់ទងទៅនឹងការិយាល័យជាតិតែប៉ុណ្ណោះ គឺការស្នើសុំប្រឆាំងទៅនឹងការកាន់កាប់ ដែលត្រូវធ្វើទៅមន្ត្រីមានសមត្ថកិច្ចនៃរដ្ឋនោះ ជាមួយនឹងរយៈពេលកំណត់ជាក់លាក់មួយ និងយោងទៅតាមលក្ខខណ្ឌច្បាប់ ដែលបានដាក់ឡើងនៅក្នុងរដ្ឋនោះ។

ហើយទោះជាយ៉ាងណាក៏ដោយ ការបដិសេធដែលធ្វើឡើងដោយការិយាល័យជាតិ ត្រូវតែជាកម្មវត្ថុននៃការស្នើសុំឱ្យត្រួតពិនិត្យឡើងវិញ ឬការប្ដឹងជំទាស់។ ហើយសេចក្ដីជូនដំណឹងអំពីការបដិសេធត្រូវបញ្ជាក់អំពីៈ

-មូលហេតុដែលបង្ហាញថា គំនូរនោះមិនបានបំពេញតាមលក្ខខណ្ឌរបស់ច្បាប់ជាតិ

-កាលបរិច្ឆេទរយៈពេល០៦ខែ នៃការជូនដំណឹងទៅកាន់ការិយាល័យអន្តរជាតិ ក្នុងករណីបដិសេធកិច្ចការពារ[81]

-រយៈពេលអនុញ្ញាតចំពោះសំណើសុំឱ្យមានការត្រួតពិនិតឡើងវិញ ឬការធ្វើបណ្ដឹងជំទាស់

-អាជ្ញាធរដែលទទួលសំណើសុំ ឬការធ្វើបណ្ដឹងជំទាស់។[82]

ការិយាល័យអន្តរជាតិ ត្រូវតែបញ្ជូនជាបន្ទាន់នូវច្បាប់ចម្លង នៃសេចក្ដីជូនដំណឹងអំពីការបដិសេធទៅអ្នកដាក់ពាក្យសុំ។

ម្យ៉ាងទៀត នៅពេលដែលការិយាល័យជាតិ រកពុំឃើញនូវចំនុចសម្រាប់បដិសេធការការពារទេ មុនរយៈពេលបដិសេធទៅលើពាក្យសុំ ការិយាល័យជាតិអាចពិភាក្សា ទៅលើស្ថានភាពនៃការផ្ដល់ការពារ។

ករណីការចុះបញ្ជីអន្តរជាតិ ត្រូវបានធ្វើមោឃភាព នោះត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ នៅក្នុងដែនដីរបស់ភាគីហត្ថលេខី ប្រសិនបើការិយាល័យបានដឹងអំពីមោឃភាពនេះ។

## កថាខណ្ឌទី២ នីតិវិធីបន្ទាប់ពីទទួលបានការការពារ

### ក. ការចុះផ្សាយ

នៅពេលដែលពាក្យសុំចុះបញ្ជីអន្តរជាតិ ត្រូវបានបំពេញគ្រប់នូវលក្ខខណ្ឌដែលបានតម្រូវហើយ ការិយាល័យអន្តរជាតិត្រូវដាក់បញ្ចូល ទៅក្នុងការចុះឈ្មោះជាអន្តរជាតិ និងធ្វើការចុះផ្សាយនៅក្នុងព្រឹត្តិបត្រ ឬក៏បញ្ជីគំនូរអន្តរជាតិ។ ការចុះផ្សាយនេះ ត្រូវបានចាត់ទុកថា មានលក្ខណៈសាធារណៈគ្រប់គ្រាន់ ហើយមិនតម្រូវអោយមានការផ្សាយជាសាធារណៈផ្សេងទៀត ពីម្ចាស់សិទ្ធិឡើយ។ ហើយការចុះផ្សាយដែលធ្វើឡើងដោយការិយាល័យអន្តរជាតិ គឺធ្វើនូវរៀងរាល់ថ្ងៃសុក្រ

[81] មាត្រា៨ (២) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[82] មាត្រា៨ (៣) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

នៅលើគេហទំព័ររបស់អង្គការកម្មសិទ្ធិពិភពលោក និងមានផ្ទុកនូវរាល់ទិន្នន័យដែលពាក់ព័ន្ធទៅនឹងការចុះបញ្ជីជាអន្តរជាតិនោះ រួមជាមួយនឹងរូបគំនូរនៃគំនូរឧស្សាហកម្មនោះផងដែរ។

ការិយាល័យអន្តរជាតិ ត្រូវផ្ញើច្បាប់ចម្លងអំពីការចុះផ្សាយការចុះបញ្ជីអន្តរជាតិ ទៅកាន់ការិយាល័យជ្រើសរើសនីមួយៗ។[83]

មុនការចុះផ្សាយ ការសម្ងាត់នានានៃពាក្យសុំអន្តរជាតិ និងការចុះបញ្ជីអន្តរជាតិនីមួយៗ មិនត្រូវបានបញ្ចេញដោយការិយាល័យអន្តរជាតិ ឬការិយាល័យជាតិជ្រើសតាំងឡើយ។

ម្យ៉ាងវិញទៀត ការថតចម្លងការចុះឈ្មោះជាអន្តរជាតិ និងចុះផ្សាយនៅក្នុងព្រឹត្តិបត្រនូវរាល់ការចុះបញ្ជីជាអន្តរជាតិ និងរាល់ទិន្នន័យដែលត្រូវថតចម្លង និងបោះផ្សាយដែលទាក់ទងទៅនឹងការចុះបញ្ជីអន្តរជាតិ ត្រូវតែជាភាសាអង់គ្លេស បារាំង ឬអេស្ប៉ាញ។

ទាក់ទងនឹងបញ្ហានៃការចុះផ្សាយខាងលើ ក៏នៅមានចំនុចពាក់ព័ន្ធមួយចំនួនទៀតដែរ គឺ៖

**ក.១ ការបកប្រែ**

ការបកប្រែចាំបាច់នៃការថតចម្លង ដែលត្រូវបង្កើតក្នុងការិយាល័យអន្តរជាតិ និងការចុះផ្សាយនៅក្នុងព្រឹត្តិបត្រ គឺត្រូវបានកំណត់ដោយការិយាល័យអន្តរជាតិ។ អ្នកដាក់ពាក្យសុំ អាចដាក់ឧបសម្ព័ន្ធទៅក្នុងពាក្យសុំអន្តរជាតិ ទៅលើការបកប្រែដែលបានស្នើសុំ នូវរាល់អត្ថបទដែលផ្ទុកទៅក្នុងពាក្យសុំអន្តរជាតិ។ ប្រសិនបើការបកប្រែដែលបានស្នើសុំ ត្រូវបានពិចារណាថា មិនត្រឹមត្រូវដោយការិយាល័យអន្តរជាតិ នោះការិយាល័យអន្តរជាតិនឹងធ្វើការកែតម្រូវ បន្ទាប់ពីបានអញ្ជើញអ្នកដាក់ពាក្យសុំអោយបង្កើតការអង្កេត កែប្រែទៅលើការកែតម្រូវដែលបានស្នើ ហើយការកែកំហុសនោះ គឺមានរយៈពេល១ខែ ចាប់ពីពេលដែលធ្វើការអញ្ជើញ។

**ក.២ ការពន្យារការចុះផ្សាយ**

ការពន្យាការចុះផ្សាយ គឺត្រូវធ្វើស្របទៅតាមចំនុចដូចខាងក្រោម៖

១-នៅពេលច្បាប់របស់ភាគីហត្ថលេខី ចែងអំពីការពន្យារចុះផ្សាយគំនូរឧស្សាហកម្មក្នុងរយៈពេលដែលតិចជាងរយៈពេលកំណត់ ភាគីហត្ថលេខីនោះ ត្រូវជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្ដីប្រកាសមួយ អំពីរយៈពេលដែលអាចអនុញ្ញាតបាននៃការពន្យារនេះ

២-នៅពេលច្បាប់របស់ភាគីហត្ថលេខី មិនបានចែងអំពីការពន្យារការចុះផ្សាយ នៃគំនូរឧស្សាហកម្មទេ ភាគីហត្ថលេខីត្រូវជូនដំណឹងទៅអគ្គនាយកអំពីបញ្ហានេះ ដោយតាមរយៈសេចក្ដីប្រកាស។[84]

---

[83] មាត្រា១០ (៣) នៃច្បាប់ហ្សឺណែវស្ដីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

[84] មាត្រា១១ (១) នៃច្បាប់ហ្សឺណែវស្ដីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

នៅពេលពាក្យសុំអន្តរជាតិមានពាក្យសុំពន្យាការចុះផ្សាយ ត្រូវធ្វើការចុះផ្សាយៈ

- នៅពេលផុតកំណត់ ប្រសិនបើគ្មានរដ្ឋហត្ថលេខី ត្រូវបានជ្រើសរើសនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិបានប្រកាសតាមកថាខណ្ឌ១ ឬ

- នៅពេលរដ្ឋហត្ថលេខីណាមួយ ត្រូវបានជ្រើសរើសក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានប្រកាសតាមកថាខណ្ឌ១ (ក) នៅពេលផុតនូវរយៈពេលដែលបានជូនដំណឹង ក្នុងសេចក្តីប្រកាសនេះ ឬនៅពេលមានភាគីហត្ថលេខីជ្រើសរើសច្រើនជាងមួយនៅពេលផុតកំណត់រយៈពេលខ្លីបំផុត ដូចបានជូនដំណឹងក្នុងសេចក្តីប្រកាស។[85]

៣- នៅពេលមានការស្នើសុំការពន្យាការចុះផ្សាយ ហើយភាគីហត្ថលេខីណាមួយដែលត្រូវបានជ្រើសរើស នៅក្នុងសំណុំពាក្យសុំអន្តរជាតិបាន ប្រកាសតាមកថាខណ្ឌ១ (ខ) ការពន្យាការចុះផ្សាយ មិនអាចធ្វើឡើងតាមច្បាប់របស់ខ្លួនបានឡើយ។

លើកលែងករណីខាងក្រោម ការិយាល័យអន្តរជាតិត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំ។ ការិយាល័យអន្តរជាតិ ត្រូវបដិសេធពាក្យសុំពន្យារការចុះផ្សាយ ប្រសិនបើក្នុងរយៈពេលដែលបានកំណត់។ អ្នកដាក់ពាក្យសុំបានដកការជ្រើសរើសភាគីហត្ថលេខី តាមរយៈលិខិតជាលាយលក្ខណ៍អក្សរទៅកាន់ការិយាល័យអន្តរជាតិ។

ហើយជំនួសឱ្យការភ្ជាប់រូបថតនៃគំនូរឧស្សាហកម្ម នៅពេលដែលពាក្យសុំអន្តរជាតិត្រូវបានភ្ជាប់មកជាមួយ ដោយរូបសំណាកគំនូរឧស្សាហកម្ម ការិយាល័យអន្តរជាតិ ត្រូវបដិសេធការជ្រើសរើសរដ្ឋហត្ថលេខីនេះ និងត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីរឿងនេះ។[86]

ជាងនេះទៅទៀត ពេលណាក៏បាន ក្នុងរយៈពេលនៃការពន្យារចំនុចលេខ២ ខាងលើម្ចាស់សិទ្ធិអាចស្នើសុំឲ្យចុះផ្សាយ នូវគំនូរឧស្សាហកម្មណាមួយ ឬទាំងអស់ ដែលជាកម្មវត្ថុនៃការចុះផ្សាយជាអន្តរជាតិ។ នៅក្នុងករណីនេះ រយៈពេលពន្យារគំនូរឧស្សាហកម្មមួយ ឬច្រើនត្រូវបានចាត់ទុកថា ផុតរយៈពេលតាមកាលបរិច្ឆេទ ដែលការិយាល័យអន្តរជាតិទទួលបានសំណើនេះ។

ហើយពេលណាក៏បាន ក្នុងរយៈពេលនៃការពន្យារតាមចំនុចលេខ២ ម្ចាស់សិទ្ធិក៏អាចស្នើសុំទៅការិយាល័យអន្តរជាតិ ដើម្បីផ្តល់ឱ្យភាគីទីបី ដែលបានបញ្ជាក់ដោយម្ចាស់សិទ្ធិ នូវទម្រង់នៃគំនូរឧស្សាហកម្មណាមួយ ឬទាំងអស់ ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ឬអនុញ្ញាតឱ្យភាគីនេះមានសិទ្ធិលើគំនូរឧស្សាហកម្មនេះ។[87]

[85] មាត្រា១១ (២) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

[86] មាត្រា១១ (៣) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

[87] មាត្រា១១ (៤) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

ទន្ទឹមនឹងនេះ ពេលណាក៏បាន ក្នុងរយៈពេលនៃការពន្យារតាមចំនុចលេខ២ ប្រសិនបើម្ចាស់សិទ្ធិបានបោះបង់ការចុះបញ្ជីអន្តរជាតិ ចំពោះភាគីហត្ថលេខីជ្រើសរើសទាំងអស់ នោះគំនូរឧស្សាហកម្មមួយ ឬច្រើនដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ មិនត្រូវបានចុះផ្សាយឡើយ។

ហើយពេលណាក៏បាន នៅក្នុងរយៈពេលនៃការពន្យារតាមចំនុចលេខ២ ប្រសិនបើម្ចាស់សិទ្ធិកម្រិតនូវគំនូរឧស្សាហកម្ម មួយឬច្រើន ដែលជាកម្មវត្ថុនៃការចុះបញ្ជីជាអន្តរជាតិ មិនត្រូវបានចុះផ្សាយឡើយ។[88]

ពេលផុតកំណត់រយៈពេលពន្យារ ការិយាល័យអន្តរជាតិ ត្រូវចុះផ្សាយចុះបញ្ជីអន្តរជាតិដែលជាកម្មវត្ថុនៃការបង់កម្រៃកំណត់។ ប្រសិនបើកម្រៃមិនទាន់បានបង់តាមការកំណត់ទេ ឬពុំបានភ្ជាប់នូវចំនួនរូបគំនូរនោះទេ ការចុះបញ្ជីអន្តរជាតិនឹងត្រូវលុបចោល ហើយមិនត្រូវធ្វើការចុះផ្សាយឡើយ។[89]

**ខ. ការផ្លាស់ប្តូរនៅក្នុងការចុះឈ្មោះជាអន្តរជាតិ**

ការផ្លាស់ប្តូរខាងក្រោម អាចនឹងប៉ះពាល់ទៅដល់ការចុះបញ្ជីជាអន្តរជាតិ ហើយវាក៏ត្រូវបានគេថតចម្លង នៅក្នុងការចុះឈ្មោះជាអន្តរជាតិផងដែរ ដែលការផ្លាស់ប្តូរនោះមានដូចជាៈ

-ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់កម្មសិទ្ធិ

-ការផ្លាស់ប្តូរភាពជាម្ចាស់នៃការចុះបញ្ជីជាអន្តរជាតិ (នៅក្នុងរដ្ឋហត្ថលេខីទាំងអស់ ឬមួយចំនួន និងចំពោះគំនូរទាំងអស់ ឬមួយចំនួន)

-ការតែងតាំងអ្នកតំណាងនៃអ្នកដាក់ពាក្យសុំ

-ការបដិសេធនូវរាល់គំនូរឧស្សាហកម្មទាំងអស់ ដែលជាប្រធាននៃការចុះបញ្ជីជាអន្តរជាតិនៅក្នុងរដ្ឋហត្ថលេខីទាំងអស់ ឬមួយចំនួន

-ការកំណត់ចំពោះគំនូរឧស្សាហកម្មមួយចំនួន ដែលជាប្រធាននៃការចុះបញ្ជីជាអន្តរជាតិនៅក្នុងរដ្ឋហត្ថលេខីទាំងអស់ ឬមួយចំនួន

-ការប្រកាសមោឃភាព នៃអានុភាពនៃការចុះបញ្ជីអន្តរជាតិ នៅក្នុងដែនដីនៃរដ្ឋហត្ថលេខីចំពោះគំនូរឧស្សាហកម្មណាមួយ ឬទាំងអស់ ជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ដោយអាជ្ញាធរមានសមត្ថកិច្ច របស់ភាគីហត្ថលេខីជ្រើសរើស។[90]

សំណើដែលទាក់ទងទៅនឹងការថតចម្លងនេះ ត្រូវតែបង្ហាញទៅការិយាល័យអន្តរជាតិ នៅលើទម្រង់ផ្លូវការដ៏ត្រឹមត្រូវ និងអមជាមួយនឹងកម្រៃដែលគេកំណត់ផងដែរ។ ហើយពត៌មានទាក់ទង

[88] មាត្រា១១ (៥) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

[89] មាត្រា១១ (៦) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

[90] មាត្រា១៦ (៣) នៃច្បាប់ហ្សឺណែវស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ០២ កក្កដា ១៩៩៩។

ទៅនឹងការផ្លាស់ប្តូរនេះ គឺត្រូវបានគេដាក់បញ្ចូលទៅក្នុងការចុះឈ្មោះជាអន្តរជាតិ និងចុះផ្សាយនៅក្នុងព្រឹត្តិបត្រដើម្បីជាពត៌មានដល់តតិយជន។

**គ. រយៈពេលនៃការការពារ និងការចុះបញ្ជីសារឡើងវិញ**

ការចុះបញ្ជីជាអន្តរជាតិ មានសុពលភាពសម្រាប់ការការពារជាលើកដំបូង ក្នុងរយៈពេល ៥ ឆ្នាំ។ ហើយវាអាចត្រូវបានចុះបញ្ជីសារឡើងវិញម្តង ឬច្រើនដង អាស្រ័យទៅតាមការកំណត់នៅក្នុងច្បាប់របស់រដ្ឋហត្ថលេខីនីមួយៗ ដែលរយៈពេលការពារម្តងៗ គឺ ៥ឆ្នាំដូចៗគ្នា។[91]

តែចំពោះគំនូរដែលជាកម្មវត្ថុនៃការតម្កល់ថ្នាក់ជាតិ ប្រសិនបើច្បាប់ជាតិនៃរដ្ឋហត្ថលេខីចែងឱ្យការពារ ក្នុងរយៈពេលលើសពី ១០ឆ្នាំ ទោះបីជាមាន ឬគ្មានការចុះបញ្ជីសារឡើងវិញក៏ដោយ ក៏ត្រូវផ្តល់កិច្ចការពារក្នុងរយៈពេលដូចគ្នាក្នុងរដ្ឋនោះ ចំពោះគំនូរទាំងឡាយណា ដែលជាកម្មវត្ថុនៃការតម្កល់ជាអន្តរជាតិ ដោយឈរទៅលើមូលដ្ឋាននៃការតម្កល់ជាអន្តរជាតិ និងការចុះបញ្ជីសារឡើងវិញ។[92]

នៅពេលដែលផុតកំណត់នៃការកាពារជាអន្តរជាតិ នោះការការពារនៅក្នុងដែនដីជាតិ ក៏ផុតកំណត់ដែរ លុះត្រាតែច្បាប់ជាតិនៃរដ្ឋនោះ ចែងឱ្យមានការបន្តការការពារ។

ហើយសំណើសម្រាប់ការចុះបញ្ជីសារឡើងវិញ ត្រូវតែជូនដំណឹងទៅការិយាល័យអន្តរជាតិជាមួយនឹងការបង់កម្រៃនៃការចុះបញ្ជីសារឡើងវិញ។ ទន្ទឹមនឹងនេះផងដែរ ការចុះបញ្ជីសារឡើងវិញ អាចធ្វើតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដែលគេហៅថាទម្រង់ អ៊ី-រីញូវ៉ល (E-renewal) ដែលអាចរកបាននៅលើគេហទំព័ររបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

សម្រាប់ការចុះបញ្ជីសារឡើងវិញ គឺអាចធ្វើឡើងចំពោះគំនូរឧស្សាហកម្មមួយផ្នែក ឬទាំងអស់ និងនៅក្នុងរដ្ឋហត្ថលេខីណាមួយ ឬទាំងអស់។[93] ការចុះបញ្ជីសារឡើងវិញនេះ គឺតម្រូវឲ្យអ្នកកាន់កាប់បង់កម្រៃដូចមានកំណត់នៅក្នុងបទបញ្ជា ក្នុងឆ្នាំចុងក្រោយនៃរយៈពេល ៥ឆ្នាំ ម្តង។[94]

ប្រសិនបើការចុះបញ្ជីសារឡើងវិញណា មានការបង់កម្រៃបន្ថែម ដែលបានកំណត់ដោយបទបញ្ជា ត្រូវផ្តល់រយៈពេលអនុគ្រោះ ៦ខែ។[95]

ទន្ទឹមនឹងនេះផងដែរ ការិយាល័យអន្តរជាតិ ត្រូវកត់ត្រា និងបោះពុម្ពផ្សាយការចុះបញ្ជីសារឡើងវិញ។[96]

---

[91] មាត្រា១១ (១) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[92] មាត្រា១១ (២) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[93] មាត្រា១០ (៤) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[94] មាត្រា១០ (១) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[95] មាត្រា១០ (២) នៃច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០។

New telephone: .................................... New fax: ....................................

New e-mail address: ....................................................................................................

**4** SIGNATURE AND/OR SEAL OF THE REPRESENTATIVE

(a) Name: ....................................................................................................

(b) Signature and/or seal: ....................................................................................................

(c) Date of signature (dd/mm/yyyy): ....................................................................................................

Name of the person to contact, if necessary: ....................................................................................................

DM/9(E)

HAGUE AGREEMENT

CONCERNING THE INTERNATIONAL REGISTRATION OF INDUSTRIAL DESIGNS

**CANCELLATION OF RECORDING OF APPOINTMENT OF A REPRESENTATIVE**

## IMPORTANT

1. The use of this form is not compulsory. It is made available for the convenience of holders of international registrations.
2. This form may relate to one or more international registrations of the same holder and representative of that holder.
3. The recording of a cancellation of the recording of a representative is exempt from the payment of a fee.

This cover page must not be sent to the International Bureau.

World Intellectual Property Organization
34, chemin des Colombettes, P.O. Box 18,
1211 Geneva 20, Switzerland
Tel.: +41 (0)22 338 91 11
Fax (The Hague Registry): +41 (0)22) 740 14 29
e-mail: intreg.mail@wipo.int – Internet: http://www.wipo.int

# DM/9(E)

## CANCELLATION OF RECORDING OF APPOINTMENT OF A REPRESENTATIVE

| For use by the holder/representative | For use by the International Bureau |
|---|---|
| Reference: .............................................. | |

**1** PERSON REQUESTING THE CANCELLATION OF APPOINTMENT OF THE REPRESENTATIVE

(a) Identify the person requesting the present cancellation by checking the appropriate box:

(i) Holder ☐
(ii) Representative of the holder ☐

(b) Name (as recorded in the International Register): ..............................................

Name of the person to contact, if necessary: ..............................................

**2** INTERNATIONAL REGISTRATION NUMBER(S)

Indicate below the international registration number(s) concerned by the cancellation of recording of appointment of the representative:

| | | | |
|---|---|---|---|
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |
| .............. | .............. | .............. | .............. |

**3** SIGNATURE AND/OR SEAL

Signature: ..............................................

Date of signature (dd/mm/yyyy): ..............................................

# ប្រកាស

# ស្ដីពី

# នីតិវិធីចុះបញ្ជីគំនូរ

# ឧស្សាហកម្ម

# ២០០៦

ណែនាំនិងឧបត្ថម្ភដោយ

-ឯកឧត្តម ជីវ សុខហាក់

-ឯកឧត្តម ប៊ុន ហុន ចំនួន៨00$

-ឯកឧត្តម កើត រិទ្ធ

-លោក តាន់ សេណារ៉ុខ

ឯកសារនេះត្រូវបានការពារ
ដោយច្បាប់នៃព្រះរាជាណា-
ចក្រកម្ពុជាតាមមាត្រា៣និង
មាត្រា១១ នៃច្បាប់ស្តីពីម៉ាក
ពាណិជ្ជនាម និងអំពើនៃការ
ប្រកួតប្រជែងមិនស្មោះត្រង់
ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
N° ៧០៧ ឧរថ-កសក-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពី
## នីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្របក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការតម្លើងការិយាល័យកម្មសិទ្ធិឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសទៅជា នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង



៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញប្រកាសលេខ ៤៨៧ ឧរថ.បល.ប្រក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- តាមសំណូមពរចាំបាច់របស់ក្រសួង

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- ការកំណត់លក្ខណៈរបស់ប្រកាស**

ប្រកាសនេះត្រូវចាត់ទុកជាបទបញ្ញានៃការអនុវត្តន៍ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មអនុលោមតាមមាត្រា ១៣០ នៃ ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ។

**ប្រការ ២.- ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី**

នាយកដ្ឋានទទួលចុះបញ្ជីត្រូវ ទទួល ពិនិត្យសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម និង ចុះបញ្ជីគំនូរឧស្សាហកម្ម ដើម្បីការពារកម្មសិទ្ធិបញ្ញារបស់អ្នកបង្កើតស្នាដៃគំនូរឧស្សាហកម្ម អនុលោមតាមច្បាប់ ។

**ប្រការ ៣.- ការបកស្រាយ**

នៅក្នុងប្រកាសនេះពាក្យដូចខាងក្រោមត្រូវបានបកស្រាយ :

-**ច្បាប់** គឺច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ។

- **រដ្ឋមន្ត្រី** គឺរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

- **មន្ត្រីកាន់កាប់បញ្ជី** គឺប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។

- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** គឺនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។

- **អនុសញ្ញាទីក្រុងប៉ារីស** គឺអនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីសស្តីពីការការពារ កម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ហើយបានកែសម្រួលចុងក្រោយ ។

-**សំណុំលិខិតស្នើសុំដំបូង** គឺជាសំណុំលិខិតស្នើសុំដែលបានដាក់មុន ឬបានសុំចុះបញ្ជីមុន ។

# ផ្នែកទី ២

## នីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម

**ប្រការ ៤.- ចំណាត់ថ្នាក់នៃគំនូរឧស្សាហកម្ម**

មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាមចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលបានអនុម័តក្រោមកិច្ចព្រមព្រៀងទីក្រុងឡូកាណូ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៦៨ ហើយបានកែសម្រួលបោះពុម្ពជាបន្តបន្ទាប់ សម្រាប់បម្រើគោលបំណងពាក់ព័ន្ធនឹងការចុះបញ្ជី និងការបោះពុម្ពផ្សាយគំនូរឧស្សាហកម្ម ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវរកឯកសារដែលបានរក្សាទុកតាមចំណាត់ថ្នាក់។

**ប្រការ ៥.- សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម**

សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោមៈ-

១-អនុលោមតាមមាត្រា ៩៥ នៃច្បាប់ សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដែលរួមមាន ពាក្យសុំ គំនូសបង្ហាញ រូបថត ឬគំនូសតាងសមស្របផ្សេងៗទៀត ជាតំណាងនៃវត្ថុ ដែលបង្កើតឡើងពីគំនូរឧស្សាហកម្ម និងការចង្អុលបង្ហាញប្រភេទផលិតផលដែលគំនូរឧស្សាហកម្ម ត្រូវបានយកមកប្រើប្រាស់ ត្រូវដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ហើយត្រូវបង់កម្រៃ តាមការកំណត់ ។

២-ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមគំរូពាក្យសុំលេខ ១គឧ ដែលមានភ្ជាប់ក្នុង**ឧបសម្ព័ន្ធ ក** នៃប្រកាសនេះ ។

៣-សំណុំលិខិតស្នើសុំត្រូវបញ្ជាក់អំពី ឈ្មោះ អសយដ្ឋាន សញ្ជាតិ ទីលំនៅ របស់អ្នកដាក់ពាក្យសុំម្នាក់ៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ។

៤-ក្នុងករណីអ្នកដាក់ពាក្យសុំជាអ្នកបង្កើតស្នាដៃ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអានុភាពនោះ ហើយក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនមែនជាអ្នកបង្កើតស្នាដៃទេនោះ ពាក្យសុំត្រូវមានបញ្ជាក់អំពីឈ្មោះ និងអសយដ្ឋានរបស់អ្នកបង្កើតស្នាដៃ ពោលគឺអ្នកគូសគំនូរឧស្សាហកម្មម្នាក់ៗ ព្រមទាំងភ្ជាប់មកជាមួយ នូវឯកសារដែលបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ចំពោះការចុះបញ្ជីគំនូរឧស្សាហកម្ម ។

៥-ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ ពាក្យសុំត្រូវបញ្ជាក់ផងដែរអំពីឈ្មោះ និងអសយដ្ឋានរបស់ភ្នាក់ងារនោះ ។

៦-ការស្នើសុំដោយអ្នកដាក់ពាក្យសុំសម្រាប់ពន្យារពេលនៃការបោះពុម្ពផ្សាយគំនូរ

ឧស្សាហកម្ម ឬគំនូរដែលមាននៅក្នុងសំណុំលិខិតស្នើសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់អំពីរយៈពេល នៃការសុំពន្យារនោះ ។

**ប្រការ ៦.~ ចំនួន ទំហំនៃក្រាហ្វិចគាង និង រូបសំណាកគាងឱ្យរូបពិត**

ចំនួន និងទំហំនៃក្រាហ្វិចតាង និងរូបសំណាកតាងឱ្យរូបពិត ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោមៈ-

១~សំណុំលិខិតស្នើសុំត្រូវតែភ្ជាប់មកជាមួយនូវ :

ក-ក្រាហ្វិចតាង ចំនួនបួន(៤)ច្បាប់ ឬគំនូសបង្ហាញ ឬគំនូសផ្ទាប់ចម្លងតាម ចំនួន(៤)ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្មជាទម្រង់ពីរខ្នាត ឬ

ខ-ក្រាហ្វិចតាង ចំនួនបួន(៤)ច្បាប់ ឬគំនូសបង្ហាញ ឬគំនូសចម្លងតាម នៃផ្នែកខុសៗគ្នានីមួយៗរបស់គំនូរឧស្សាហកម្ម ចំនួនបួន(៤)ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្មជាទម្រង់បីខ្នាត និង

គ-គំនូរបោះពុម្ពនៅលើសន្លឹកក្រដាសដែលមិនត្រូវមានខ្នាតធំលើសពីទំហំ ១៧,០ស.ម X ២៦,២ស.ម ឡើយ ។

២~រូបសំណាកតាងឱ្យរូបពិតរបស់គំនូរឧស្សាហកម្មមិនត្រូវមានខ្នាតធំលើសពីទំហំ ២០ស.ម X ២០ស.ម X ២០ស.ម ឡើយ ។ ក្រាហ្វិចតាង គំនូសបង្ហាញ ឬគំនូសចម្លងតាមនៃគំនូរឧស្សាហកម្មមិនត្រូវមានខ្នាតធំលើសពីទំហំ ១០ស.ម X ២០ស.ម ឡើយ ។ គំនូសតាង គំនូសបង្ហាញ ឬគំនូសចម្លងតាមទាំងនោះត្រូវគូសនៅលើក្រដាសក្រាស់រឹង ដែលមានទំហំអា៤ ចំនួនបួន(៤)សន្លឹក ។ គំនូសបង្ហាញ និងគំនូសចម្លងតាម ត្រូវគូសដោយទឹកខ្មៅពណ៌ខ្មៅ ។

**ប្រការ ៧.~ ភាសានៃឯកសារ និងការបកប្រែ**

ភាសានៃឯកសារ និងការបកប្រែ ត្រូវអនុវត្តដូចខាងក្រោមៈ-

១~សំណុំលិខិតស្នើសុំ និងឯកសារណាមួយដែលបង្កើតបានជាផ្នែកមួយ នៃសំណុំលិខិតស្នើសុំ ឬឯកសារណាមួយបានដាក់ជូននាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ឬមន្ត្រីកាន់កាប់បញ្ជី អនុលោមតាមច្បាប់ ប្រកាសនេះ និងបទបញ្ញាពាក់ព័ន្ធត្រូវធ្វើជាភាសាខ្មែរ ។

២~សម្រាប់គោលបំណងនៃការស្រាវជ្រាវ និងការពិនិត្យ ក្នុងករណីសំណុំលិខិតស្នើសុំ និងឯកសារដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ដែលបានសរសេរជាភាសាខ្មែរ ឬជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ត្រូវបកប្រែជាភាសាអង់គ្លេស ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេលប្រាំមួយ (៦) ខែគិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី ។

៣~សម្រាប់គោលបំណងនៃការវិនិច្ឆ័យ ការការពារ និងការអនុវត្តន៍ច្បាប់ ក្នុង

ករណី សំណុំលិខិតស្នើសុំដែលសរសេរជាភាសាបរទេសក្រៅពីភាសាខ្មែរ ត្រូវបកប្រែជាភាសាខ្មែរ ហើយ ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេលប្រាំមួយ (៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី ។

**ប្រការ ៨.- ការបញ្ជាក់ឈ្មោះ សញ្ជាតិ អសយដ្ឋាន និងលំនៅដ្ឋាន**

ការបញ្ជាក់ឈ្មោះ អសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋាន ត្រូវបញ្ជាក់ដូចខាងក្រោមៈ-

១.ត្រង់ចំណុចឈ្មោះរបស់រូបវន្តបុគ្គលត្រូវបញ្ជាក់ដោយ នាមត្រកូល នាមខ្លួន សញ្ជាតិ និង អសយដ្ឋាន របស់បុគ្គលនោះ ។ ឈ្មោះរបស់នីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញជាផ្លូវការរបស់នីតិបុគ្គលនោះ ។

២.ត្រង់ចំណុចសញ្ជាតិត្រូវបញ្ជាក់ឈ្មោះប្រទេសដែលបុគ្គលនោះជាជនជាតិ ។ នីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះប្រទេសដែលនីតិបុគ្គលនោះត្រូវបានបង្កើតនៅក្រោមច្បាប់នៃប្រទេសនោះ ព្រមទាំងការិយាល័យដែលបានចុះបញ្ជីរួចហើយរបស់នីតិបុគ្គលនោះ ។

៣.ត្រង់ចំណុចអសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់តាមវិធីណាមួយដើម្បីបំពេញការតម្រូវជាធម្មតា សម្រាប់ការបញ្ជូនតាមប្រៃសណីយ៍បានឆាប់ទៅដល់អសយដ្ឋានដែលបញ្ជាក់នោះ ហើយក្នុងករណីណាមួយក៏ដោយ ក៏ត្រូវបញ្ជាក់ផងដែរនូវអង្គភាពរដ្ឋបាលពាក់ព័ន្ធរួមទាំងលេខផ្ទះ ប្រសិនបើមាន ។ អសយដ្ឋានត្រូវមានបញ្ជាក់ លេខទូរស័ព្ទ លេខទូរសារ និងអសយដ្ឋាន អ៊ីមែលផងដែរ ។

៤.ត្រង់ចំណុចលំនៅដ្ឋានត្រូវបានបញ្ជាក់ឈ្មោះប្រទេស ដែលបុគ្គលនោះជាជនមានលំនៅដ្ឋានជាប់លាប់ ។

៥.គ្រប់អ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវផ្តល់ឱ្យមន្ត្រីកាន់កាប់បញ្ជីនូវអសយដ្ឋានសម្រាប់ទំនាក់ទំនងនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គោលបំណងនៃសំណុំលិខិតស្នើសុំរបស់គាត់ ។

**ប្រការ ៩.- ការប្តូរឈ្មោះ សញ្ជាតិ និងអសយដ្ឋាន**

ការប្តូរឈ្មោះ សញ្ជាតិ និងអសយដ្ឋាន ត្រូវអនុវត្តដូចខាងក្រោមៈ-

១.សំណើសុំដោយម្ចាស់ ឬដោយអ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដើម្បីប្តូរឈ្មោះ សញ្ជាតិ អសយដ្ឋាន ឬអសយដ្ឋានសម្រាប់ទាក់ទងដែលបានកត់ត្រាចំពោះគំនូរឧស្សាហកម្ម ឬនៅក្នុងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មរបស់ខ្លួន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២.មុននឹងអនុវត្តតាមសំណើក្នុងការប្តូរឈ្មោះ ឬសញ្ជាតិ មន្ត្រីកាន់កាប់បញ្ជីអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំ ផ្តល់ភស្តុតាងសមស្របពាក់ព័ន្ធទៅនឹងការប្តូរនេះ ។

៣-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណើនោះសមស្រប មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តការប្តូរនោះលើគំនូរឧស្សាហកម្ម ឬក៏លើសំណុំលិខិតស្នើសុំការចុះបញ្ជីគំនូរឧស្សាហកម្ម ហើយក្នុងករណីដែលឈ្មោះ សញ្ជាតិ ឬអសយដ្ឋាន ត្រូវបានកត់ត្រារួចហើយនៅក្នុងបញ្ជី បញ្ជីនោះក៏ត្រូវតែកត់ត្រាការប្តូរនោះឱ្យបានត្រឹមត្រូវ ។

**ប្រការ ១០.- ការចុះហត្ថលេខា**

ការចុះហត្ថលេខាត្រូវអនុវត្តដូចខាងក្រោម:-

១- ឯកសារដែលរៀបចំដើម្បីចុះហត្ថលេខាជូសមុខឱ្យ ឬក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ក្រុមហ៊ុន និងដៃគូទាំងអស់ ជាឈ្មោះពេញ ហើយត្រូវបានចុះហត្ថលេខា ដោយអ្នកទាំងអស់នោះ ឬដោយដៃគូណាមួយ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចុះហត្ថលេខា ដោយបញ្ជាក់ថា ដៃគូនោះចុះហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬចុះហត្ថលេខា ដោយបុគ្គលណាម្នាក់ផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ ។ ឯកសារដែលបានរៀបចំដើម្បីចុះហត្ថលេខាជូសមុខឱ្យ ឬក្នុងនាមអង្គភាពសាជីវកម្ម ត្រូវចុះហត្ថលេខាដោយនាយក ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ណាមួយផ្សេងទៀត របស់អង្គភាពសាជីវកម្មនោះ ឬដោយបុគ្គលណាមួយផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ និងប្រថាប់ត្រារបស់អង្គភាពសាជីវកម្មនោះផង ។ ឯកសារដែលរៀបចំឡើងដើម្បីចុះហត្ថលេខាជូសមុខឱ្យ ឬក្នុងនាមសមាគមនៃបុគ្គលច្រើននាក់ អាចត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា ។

២- ក្នុងករណីដែលយល់ថាចាំបាច់ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើសុំឱ្យផ្តល់ភស្តុតាងនៃការអនុញ្ញាតឱ្យចុះហត្ថលេខា ។

**ប្រការ ១១.- ការប្រកាសអាទិភាព**

ការប្រកាសដែលអះអាងអំពីអាទិភាពនៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម យោងតាមមាត្រា ១០០ នៃច្បាប់ ត្រូវអនុវត្តដូចខាងក្រោម:-

១-សេចក្តីប្រកាសដែលបានអះអាងយោងតាមមាត្រា ២៧ នៃច្បាប់ ត្រូវធ្វើឡើងនៅពេលដាក់សំណុំលិខិតស្នើសុំគំនូរឧស្សាហកម្ម ហើយត្រូវបញ្ជាក់អំពី :

ក-កាលបរិច្ឆេទនៃការសុំចុះបញ្ជីរបស់សំណុំលិខិតស្នើសុំដំបូង ។

ខ-លេខនៃសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច ២ នៃប្រការនេះ ។

គ-និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលត្រូវបានដាក់ចំពោះសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច ៣ នៃប្រការនេះ ។

ឃ-ឈ្មោះប្រទេសដែលបានទទួលការសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំដំបូង ឬឈ្មោះប្រទេសមួយឬច្រើន ដែលបានទទួលការសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំនោះ ក្នុងករណីដែលសំណុំលិខិតស្នើសុំដំបូង ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ ។

ង-ឈ្មោះការិយាល័យដែលបានទទួលការសុំចុះបញ្ជីនៃ សំណុំលិខិតស្នើសុំដំបូង ក្នុងករណីសំណុំលិខិតស្នើសុំដំបូង ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ ។

២~ក្នុងករណីនាពេលដាក់សេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះ លេខនៃសំណុំលិខិតស្នើសុំដំបូង មិនត្រូវបានដឹងទេនោះ លេខនេះត្រូវតែផ្តល់ឱ្យក្នុងរយៈពេល បី(៣)ខែ ក្រោយកាលបរិច្ឆេទនៃការដាក់សំណុំលិខិតស្នើសុំ នៅនាយកដ្ឋានចុះបញ្ជីអាទិភាពនោះត្រូវបានសុំចុះបញ្ជី ។

៣~ក្នុងករណីនាពេលដាក់សេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះ និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិ នៃគំនូរឧស្សាហកម្ម មិនត្រូវបានកំណត់ឱ្យចំពោះសំណុំលិខិតស្នើសុំដំបូង ឬមិនទាន់បានកំណត់ឱ្យនៅឡើយ អ្នកដាក់ពាក្យសុំ ត្រូវថ្លែងបញ្ជាក់អំពីហេតុការណ៍នេះនៅក្នុងសេចក្តីប្រកាសនោះ ហើយត្រូវផ្តល់និមិត្តសញ្ញានេះយ៉ាងឆាប់ខណៈដែលវាត្រូវបានកំណត់ ។

៤~អ្នកដាក់ពាក្យសុំអាចកែតម្រូវអត្ថបទនៃសេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះ នាពេលណាមួយមុនការចុះបញ្ជីគំនូរឧស្សាហកម្ម ។

៥~យោងតាមមាត្រា ២៨ នៃច្បាប់ រយៈពេលសម្រាប់ការផ្តល់ឯកសារចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើមនៃសំណុំលិខិតស្នើសុំដំបូង ត្រូវមានរយៈពេល បី(៣) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំដោយមន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណី ដែលឯកសារចម្លងនៃសំណុំលិខិតស្នើសុំត្រូវបានប្រគល់រួចហើយ សម្រាប់ការដាក់សំណុំលិខិតស្នើសុំផ្សេងទៀត អ្នកដាក់ពាក្យសុំអាចឆ្លើយតប ដោយធ្វើសេចក្តីយោងទៅលើការដាក់សំណុំ លិខិតស្នើសុំផ្សេងទៀតនោះ ។

៦~ក្នុងករណីសំណុំលិខិតស្នើសុំដំបូង សរសេរជាភាសាផ្សេងក្រៅពីភាសាខ្មែរ អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែនៃសំណុំលិខិតស្នើសុំនោះ ជាភាសាខ្មែរ ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំរបស់មន្ត្រីកាន់កាប់បញ្ជី ។

៧~ទោះបីជាគ្មានការស្នើសុំពីមន្ត្រីកាន់កាប់បញ្ជីក៏ដោយ ក៏អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ឱ្យនូវសំណុំលិខិតស្នើសុំដំបូង ចំនួនមួយ(១)ច្បាប់ ជាមួយសេចក្តីបកប្រែសំណុំលិខិតនោះ

ចំនួនមួយ(១)ច្បាប់ ។

**ប្រការ ១២.- ការដកហូតយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ**

ការដកហូតយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ ត្រូវអនុវត្តដូចខាងក្រោម:-

១-សំណុំលិខិតស្នើសុំត្រូវសុំដកយកវិញបាន ដោយសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ។

២-កម្រៃពាក់ព័ន្ធនឹងការដាក់សំណុំលិខិតស្នើសុំមិនត្រូវបានប្រគល់ឱ្យវិញទេ ប្រសិនបើសំណុំលិខិតស្នើសុំ ត្រូវបានដកយកទៅវិញ ។

៣-ការកែតម្រូវណាមួយ នៃសំណុំលិខិតស្នើសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

៤-សំណុំលិខិតស្នើសុំគំនូរឧស្សាហកម្មដែលត្រូវបានដកហូតយកទៅវិញ បានបោះបង់ចោល ឬត្រូវបានបដិសេធ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ៤(គ)(៤) ស្តីពីសិទ្ធិអាទិភាពនៃអនុសញ្ញាក្រុងប៉ារីស តាមការសមស្រប ។

**ប្រការ ១៣.- ការចុះលេខ និងការគូសសញ្ញា**

ការចុះលេខ និងការគូសសញ្ញា ត្រូវអនុវត្តដូចខាងក្រោម:-

១-នៅពេលទទួលសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សំគាល់នៅលើឯកសារនីមួយៗនៃសំណុំលិខិតស្នើសុំ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួល និងលេខសំណុំលិខិតស្នើសុំ ដែលផ្តើដោយអក្សរ "គជ " បន្ទាត់ទ្រេត"/" អក្សរ "គឱ " បន្ទាត់ទ្រេត"/" លេខពីរខ្ទង់ចុងក្រោយនៃឆ្នាំដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត"/" និងលេខចំនួនប្រាំខ្ទង់ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល ។ ក្នុងករណីដែលឯកសារកែតម្រូវណាមួយ ឬឯកសារដែលបានដាក់ក្រោយផ្សេងទៀត ត្រូវបានទទួលនៅលើកាលបរិច្ឆេទខុសគ្នា មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សំគាល់ផងដែរ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលនោះនៅកន្លែងសមស្របរបស់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម (គំរូពាក្យសុំលេខ ១គឱ) ។

២-លេខសំណុំលិខិតស្នើសុំដែលមានចែងក្នុងចំណុចទី១ នៃប្រការនេះ ត្រូវស្រង់យកមកដាក់នៅក្នុងការទាក់ទងពត៌មាន តាមលំដាប់លំដោយពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំ ។

**ប្រការ ១៤.- ការពិនិត្យ**

បន្ទាប់ពីអនុវត្តតាមការចែងក្នុងប្រការ ១៣ នៃប្រកាសនេះរួចហើយ ត្រូវអនុវត្តបន្តដូចខាងក្រោម:-

១-មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យថា តើសំណុំលិខិតស្នើសុំ បំពេញត្រឹមត្រូវតាមការ

តម្រូវរបស់មាត្រា ៩៥ នៃច្បាប់ឬទេ ។

២-ការអញ្ជើញឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវណាមួយតាមវាក្យខណ្ឌទី ២ នៃមាត្រា១០១ នៃច្បាប់ រួមជាមួយគ្នា និងមាត្រា ៣៤ នៃច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។ ការអញ្ជើញ ត្រូវមានបញ្ជាក់អំពីការកែតម្រូវ ឬការតម្រូវឱ្យកែ ហើយស្នើឱ្យដាក់ពាក្យសុំធ្វើការកែតម្រូវនោះ ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញនោះ ។

៣-នៅពេលយល់ព្រមលើកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ។ ប្រសិនបើសំណុំលិខិតស្នើសុំត្រូវបានចាត់ទុកថាមិនត្រូវទទួលចុះបញ្ជី ដូចមានចែងក្នុងមាត្រា ១០១ នៃច្បាប់ រួមជាមួយគ្នា និងមាត្រា ៣៤ នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយមានបញ្ជាក់ពីមូលហេតុផង ។

៤-ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៨៩ មាត្រា ៩០ មាត្រា ៩៣ មាត្រា ៩៥ និង មាត្រា ៩៦ នៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងមាត្រាទាំងនេះ មិនបានបំពេញត្រឹមត្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរធ្វើការកែតម្រូវ ដែលបានតម្រូវក្នុងរយៈពេល ពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ជាមួយនឹងការបង់កម្រៃតាមការកំណត់ ។ ប្រសិនបើអ្នកដាក់ពាក្យសុំ មិនបានអនុវត្តត្រឹមត្រូវ តាមការអញ្ជើញឱ្យធ្វើការកែតម្រូវនូវកំហុស ដែលមាននៅក្នុងសំណុំលិខិតស្នើសុំទេនោះ ឬថ្វីបើអ្នកដាក់ពាក្យសុំបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជីនូវការកែតម្រូវរួចហើយក៏ដោយ ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាលក្ខខណ្ឌខាងលើ មិនត្រូវបានបំពេញត្រឹមត្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធសំណុំលិខិតស្នើសុំ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយបញ្ជាក់អំពីមូលហេតុផង ។

៥-ការបដិសេធសំណុំលិខិតស្នើសុំ មិនមានឥទ្ធិពលដល់កាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំ ដែលនៅតែរក្សាសុពលភាពដដែល ។

៦-មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យសុំអំពីការសម្រេចយល់ព្រមចុះបញ្ជី ឬអំពីការសម្រេចបដិសេធសំណុំលិខិតស្នើសុំ ហើយក្នុងករណីដែលសម្រេចចុះបញ្ជីសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំបង់កម្រៃក្នុងការចុះបញ្ជី ក្នុងរយៈពេលមួយ(១)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង

**ប្រការ ១៥.~ ការចុះបញ្ជីគំនូរឧស្សាហកម្ម**

ការចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោម:-

១~អាស្រ័យដោយការបង់កម្រៃក្នុងការចុះបញ្ជី តាមរយៈពេលដែលបានកំណត់ក្នុង ចំណុច ៦ នៃប្រការ ១៤ នៃប្រកាសនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចុះបញ្ជីគំនូរឧស្សាហកម្មនោះ ស្របតាមមាត្រា១០៣ នៃច្បាប់ និងប្រកាសនេះ ។

២~មន្ត្រីកាន់កាប់បញ្ជីត្រូវចុះលេខសម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្មនីមួយៗ ទៅតាមលំដាប់លំដោយនៃការចុះបញ្ជី ។

៣~ការចុះបញ្ជីគំនូរឧស្សាហកម្មត្រូវរួមបញ្ចូលការបង្ហាញអំពីគំនូរឧស្សាហកម្ម និងត្រូវបញ្ជាក់អំពី :

ក- លេខនៃគំនូរឧស្សាហកម្ម

ខ- ឈ្មោះ និងអសយដ្ឋានរបស់ម្ចាស់ ដែលបានចុះបញ្ជីរួចហើយ

គ-ឈ្មោះ និងអសយដ្ឋានរបស់ភ្នាក់ងារតំណាង ប្រសិនបើមាន

ឃ-ឈ្មោះ និងអសយដ្ឋានរបស់អ្នកបង្កើត លើកលែងតែករណីដែលអ្នកបង្កើតស្នើសុំ មិនឱ្យដាក់ឈ្មោះរបស់គេក្នុងការចុះបញ្ជី

ង-ប្រសិនបើកាលបរិច្ឆេទអាទិភាពត្រូវបានអះអាង និងសេចក្ដីអះអាងត្រូវបានទទួលយកកាលបរិច្ឆេទអាទិភាព និងប្រទេសមួយ ឬប្រទេសច្រើនដែលបានទទួលការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំដំបូង និង

ច-ប្រភេទនៃផលិតផលដែលគំនូរឧស្សាហកម្មត្រូវយកទៅប្រើប្រាស់ ។

៤~ការបោះពុម្ពផ្សាយ នៃសេចក្ដីយោងចំពោះការចុះបញ្ជី នៃគំនូរឧស្សាហកម្ម អនុលោមតាមមាត្រា ១០៣ នៃច្បាប់ ត្រូវបញ្ជាក់ចំណុចពិសេសៗ ដូចមានចែងក្នុងចំណុច ៣ នៃប្រការនេះ ។

**ប្រការ ១៦.~ ការចុះបញ្ជីសារជាថ្មី**

ការចុះបញ្ជីសារជាថ្មី នៃគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោម:-

១~អនុលោមតាមមាត្រា ១០៩ នៃច្បាប់ ការចុះបញ្ជីសាឡើងវិញ អាចត្រូវធ្វើឡើងដោយម្ចាស់ ដែលបានចុះបញ្ជី ឬដោយភ្នាក់ងារតំណាងរបស់គាត់ ក្នុងរយៈពេលប្រាំមួយ(៦)ខែមុនការផុតកំណត់នៃការចុះបញ្ជី ។

២~ការចុះបញ្ជីសាឡើងវិញត្រូវធ្វើឡើងដោយមានការបង់កម្រៃក្នុងការចុះបញ្ជីសាឡើងវិញ ក្នុងរយៈពេលដែលបានកំណត់ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ឬក្នុងរយៈពេលអនុគ្រោះ ចំនួនប្រាំមួយ (៦) ខែ ដូចមានចែងក្នុងមាត្រា ១០៩ នៃច្បាប់ ដោយមានការបង់

កម្រៃបន្ថែម លើការយឺតយ៉ាវ ។

៣~ការចុះបញ្ជីសាឡើងវិញនៃគំនូរឧស្សាហកម្មត្រូវកត់ត្រានៅក្នុងបញ្ជី និងត្រូវបោះពុម្ពផ្សាយ ។

៤~មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចេញវិញ្ញាបនបត្រចុះបញ្ជីសាឡើងវិញ ជូនដល់ម្ចាស់ដែលបានចុះបញ្ជីដែលក្នុងនោះ ត្រូវមាន :

ក-លេខចុះបញ្ជីនៃគំនូរឧស្សាហកម្ម

ខ-កាលបរិច្ឆេទនៃការចុះបញ្ជីសាឡើងវិញ និងកាលបរិច្ឆេទនៃការផុតកំណត់

គ-ឈ្មោះ និងអសយដ្ឋានរបស់ម្ចាស់ដែលបានចុះបញ្ជី និង

ឃ-ការបញ្ជាក់អំពីប្រភេទនៃផលិតផល ដែលគំនូរឧស្សាហកម្មត្រូវបានចុះបញ្ជីរួចហើយ ។

**ប្រការ ១៧.~ ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាបណ្ណ**

ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាបណ្ណនៃគំនូរឧស្សាហកម្មត្រូវអនុវត្តដូចខាងក្រោមៈ-

១~អនុលោមតាមមាត្រា ១១៤ នៃច្បាប់ សំណើសុំធ្វើការកត់ត្រាការប្តូរម្ចាស់កម្មសិទ្ធិនៃគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីស្របតាមច្បាប់ ឬធ្វើការកត់ត្រាការប្តូរម្ចាស់កម្មសិទ្ធិនៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមគំរូពាក្យសុំដែលកំណត់ រួចដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ។

២~ការបោះពុម្ពផ្សាយស្តីពីការប្តូរម្ចាស់កម្មសិទ្ធិត្រូវបញ្ជាក់អំពី :

ក-ចំណងជើងនៃគំនូរឧស្សាហកម្មដែលបានការពារ

ខ-កាលបរិច្ឆេទសុំចុះបញ្ជី កាលបរិច្ឆេទអាទិភាពប្រសិនបើមាន និងកាលបរិច្ឆេទនៃការចុះបញ្ជី

គ-ម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិថ្មី និង

ឃ-លក្ខណៈនៃការប្តូរម្ចាស់កម្មសិទ្ធិ ។

៣~កិច្ចសន្យាអាជ្ញាប័ណ្ណដែលបានដាក់ជូនដើម្បីកត់ត្រាយោងតាមមាត្រា ១១៥ នៃច្បាប់ ត្រូវបង់កម្រៃតាមការកំណត់ ។

**ប្រការ ១៨.~ ភ្នាក់ងារ**

ភ្នាក់ងារ ត្រូវអនុវត្តដូចខាងក្រោមៈ-

១~អនុលោមតាមមាត្រា ១១៦ នៃច្បាប់ ការចាត់តាំងភ្នាក់ងារតំណាងត្រូវធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ប្រសិនបើមានអ្នកដាក់ពាក្យសុំលើសពីមួយនាក់ ។ អសយដ្ឋានរបស់ភ្នាក់ងារតំណាង

ត្រូវចាត់ទុកថាជាអសយដ្ឋានទាក់ទងដើម្បីបញ្ជូនដំណឹងទៅបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ ដែលបានចាត់តាំងភ្នាក់ងារនោះ សម្រាប់គោលបំណងទាំងឡាយដែលពាក់ព័ន្ធទៅនឹងច្បាប់ និងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ពន្ធ័ ។

២~លិខិតប្រគល់សិទ្ធិឱ្យភ្នាក់ងារ ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះត្រូវភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំ ឬដែលអាចត្រូវប្រគល់ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំនោះ ។

៣~ប្រសិនបើការចាត់តាំងភ្នាក់ងារ មិនត្រូវបានអនុវត្តដូចមានចែងក្នុងចំណុច ២ នៃប្រការនេះទេ ហើយមិនស្របតាមមាត្រា ១១៦ នៃច្បាប់ ចំណាត់ការជានីតិវិធីណាមួយ ដែលធ្វើដោយភ្នាក់ងារក្រៅពីការដាក់សំណុំលិខិតស្នើសុំចុះបញ្ជី ត្រូវចាត់ទុកថាមិនបានធ្វើឡើយ ។

៤~ការតម្រូវនានាពាក់ព័ន្ធភ្នាក់ងារតំណាងរបស់អ្នកដាក់ពាក្យសុំ ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ត្រូវចែងដោយបទប្បញ្ញត្តិដោយឡែក ដែលកំណត់ដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ១៩.~ ថ្ងៃលើកលែង**

កាលណាថ្ងៃចុងក្រោយសម្រាប់អនុវត្តអំពើណាមួយ ឬដំណើរចំណាត់ការណាមួយ ធ្លាក់ចំថ្ងៃដែលក្រុមហ៊ុន និងនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីមិនធ្វើការបំរើសាធារណជន ត្រូវចាត់ទុកថាស្របច្បាប់ចំពោះការអនុវត្តន៍អំពើ ឬដំណើរការនៅថ្ងៃដែលក្រុមហ៊ុន ឬនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដំណើរការបំរើសាធារណជន នៅថ្ងៃបន្ទាប់ពីថ្ងៃឈប់នោះ ។

**ប្រការ ២០.~ ការដកស្រង់ព័ត៌មានពីបញ្ជី និងការកែតម្រូវកំហុស**

ការដកស្រង់ពត៌មានពីបញ្ជី និងការកែតម្រូវកំហុស ត្រូវអនុវត្តដូចខាងក្រោមៈ-

១~ ការស្នើសុំច្បាប់ចម្លង ដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃការដកស្រង់ពត៌មានពីបញ្ជី ឬការស្នើសុំថតចម្លងឯកសារផ្សេងៗ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ។

២~ការកែតម្រូវកំហុស យោងតាមមាត្រា ១២០ នៃច្បាប់ អាចត្រូវបានធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយបានបំពេញល័ក្ខខ័ណ្ឌទាំងឡាយ ដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសមស្រប ឬតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី ។ ការកែតម្រូវទាំងឡាយដែលបានធ្វើឡើងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលពាក់ព័ន្ធទាំងឡាយ ហើយក្នុងករណីចាំបាច់ត្រូវបោះពុម្ពផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី ។

**ប្រការ ២១.~ សវនាការ**

សវនាការ ត្រូវអនុវត្តដូចខាងក្រោមៈ-

១~មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិណាមួយដែលបានផ្ដល់ឱ្យមន្ត្រីកាន់កាប់បញ្ជី ដោយច្បាប់ ឬដោយប្រកាសនេះ ចំពោះបុគ្គលណាម្នាក់ ដោយមិនអនុគ្រោះ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលនោះ អំពីឱកាសសម្រាប់សវនាការ ហើយបញ្ជាក់អំពីពេលវេលាកម្រិតមិនតិចជាងមួយ(១)ខែ សម្រាប់ការដាក់ពាក្យសុំធ្វើសវនាការនោះ ។

២~ពាក្យសុំធ្វើសវនាការត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

៣~នៅពេលទទួលពាក្យសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ និងពេលវេលាធ្វើសវនាការ មិនតិចជាងរយៈពេល ពីរ(២)សប្ដាហ៍ មុនកាលបរិច្ឆេទកំណត់ធ្វើសវនាការ ទៅបុគ្គលដែលបានដាក់ពាក្យសុំ និងបុគ្គលពាក់ព័ន្ធផ្សេងៗទៀត ។

**ប្រការ ២២.~ សេវាកម្មដោយសំបុត្រ**

សេវាកម្មដោយសំបុត្រ ត្រូវអនុវត្តដូចខាងក្រោមៈ-

១~សេចក្ដីជូនដំណឹងណាមួយ សំណុំលិខិតស្នើសុំ ឬឯកសារផ្សេងៗទៀត ដែលបានធ្វើតាមប្រៃសណីយ៍ជូនមន្ត្រីកាន់កាប់បញ្ជី ត្រូវចាត់ទុកថាបានប្រគល់ បានផ្ដល់បានធ្វើ ឬបានដាក់សំណុំលិខិតស្នើសុំនៅពេលដែលឯកសារទាំងនោះ ត្រូវបានប្រគល់តាមរបៀបធម្មតានៃប្រៃសណីយ៍ ។ ដើម្បីបញ្ជាក់ជាភស្តុតាងអំពីការបញ្ជូននេះ ត្រូវតែបង្ហាញភស្តុតាងគ្រប់គ្រាន់ថាលិខិតដែលរួមមានសេចក្ដីជូនដំណឹង សំណុំលិខិតស្នើសុំ ឬឯកសារផ្សេងៗខាងលើនោះ បានសរសេរអាសយដ្ឋានយ៉ាងត្រឹមត្រូវ និងបានធ្វើតាមលិខិតអនុសិដ្ឋ ។

២~ចំណុច ១ នៃប្រការនេះ មិនត្រូវបានយកមកអនុវត្តចំពោះការយល់ព្រមទទួលស្គាល់កាលបរិច្ឆេទសុំចុះបញ្ជីឡើយ ។

**ប្រការ ២៣.~ ភស្តុតាង**

ភស្តុតាង ត្រូវអនុវត្តដូចខាងក្រោមៈ-

១~អនុលោមតាមប្រកាសនេះ ភស្តុតាងដែលត្រូវដាក់ជូនពិនិត្យ ត្រូវធ្វើឡើងតាមរយៈលិខិតប្រកាសស្របច្បាប់ ឬតាមរយៈលិខិតសច្ចាប្រណិធាន ។

២~ក្នុងករណីដោយឡែកណាមួយ ប្រសិនបើពិនិត្យឃើញថាជាការសមស្រប មន្ត្រីកាន់កាប់បញ្ជីអាចទទួលយកភស្តុតាងផ្ទាល់មាត់ជំនួស ឬបន្ថែមលើភស្តុតាងខាងលើ និងត្រូវអនុញ្ញាតឱ្យសាក្សីណាមួយអាចចូលរួមធ្វើការចោទសួរឆ្លើយឆ្លង អំពីលិខិតសច្ចាប្រណិធាន ឬលិខិត

ប្រកាសរបស់គេ ។

**ប្រការ ២៤.- លិខិតប្រកាសស្របច្បាប់**

លិខិតប្រកាសស្របច្បាប់ ត្រូវអនុវត្តដូចខាងក្រោមៈ-

១-លិខិតប្រកាសស្របច្បាប់ ឬលិខិតសច្ចាប្រណិធានណាមួយ ដែលដាក់ជូនសម្រាប់ពិនិត្យស្របតាមច្បាប់ និងប្រកាសនេះ ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីណាម្នាក់ដែលបានទទួលសិទ្ធិតាមច្បាប់នៅទីកន្លែងណាមួយនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាត់ចែងការធ្វើសច្ចាប្រណិធានសម្រាប់គោលបំណងនៃដំណើរការស្របច្បាប់ណាមួយខាងផ្លូវច្បាប់ ។

២-លិខិតប្រកាសស្របច្បាប់ ឬលិខិតសច្ចាប្រណិធានដែលធ្វើនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីស្ថានកុងស៊ុល ឬមន្ត្រីស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ។

**ប្រការ ២៥.- ព្រឹត្តិបត្រផ្លូវការ**

ចំណុចពិសេសទាំងឡាយរបស់គំនូរឧស្សាហកម្ម និងដំណើរការដទៃទៀត អនុលោមតាមច្បាប់ និងពត៌មានណាមួយផ្សេងទៀតដែលតម្រូវឱ្យបោះពុម្ពផ្សាយ អនុលោមតាមច្បាប់ ឬប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ ត្រូវបោះពុម្ពផ្សាយតាមការណែនាំរបស់មន្ត្រីកាន់កាប់បញ្ជី នៅក្នុងព្រឹត្តិបត្រផ្លូវការដែលនឹងត្រូវរៀបចំឡើង ។

**ប្រការ ២៦.- ការបង់កម្រៃ**

កម្រៃដែលត្រូវបង់សម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្ម ដូចមានចែងក្នុងប្រកាសនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ២៧.- ការដោះស្រាយទំនាស់**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម មានសមត្ថកិច្ចបង្កើតយន្តការដោះស្រាយទំនាស់ពាក់ពន្ធ័នឹងការចុះបញ្ជីគំនូរឧស្សាហកម្ម តាមការចាំបាច់ ។

**ប្រការ ២៨.- កិច្ចសហការ**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវសហការជាមួយអង្គការជាតិ និងអន្តរជាតិ និងស្ថាប័នពាក់ពន្ធ័ ដើម្បីជម្រុញការការពារកម្មសិទ្ធិឧស្សាហកម្ម និងអភិវឌ្ឍប្រពន្ធ័ចុះបញ្ជីគំនូរឧស្សាហកម្ម ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**ប្រការ ២៩.~ សមត្ថកិច្ចអនុវត្ត**

អគ្គធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម មានភារកិច្ចអនុវត្តក្របខណ្ឌសមត្ថកិច្ចរៀងៗខ្លួន ។

**ប្រការ ៣០.~ ប្រសិទ្ធិភាព**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ_សែម

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងយុត្តិធម៌
- រាជបណ្ឌិតសភាកម្ពុជា
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង
  " ដើម្បីជូនជ្រាបជាពត៌មាន "
- ដូចប្រការ ២៩ "ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ ក
[គំរូលេខ ១ គឧ]

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
អគ្គនាយកដ្ឋានឧស្សាហកម្ម
នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

# ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្មកម្ពុជា

យោងលេខ :

| សាម៉ីជនដែលបានចុះហត្ថលេខានេះ ស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មកម្ពុជា ចំពោះកម្មវត្ថុដូចខាងក្រោមនេះ : | សម្រាប់មន្ត្រីកាន់កាប់បញ្ជី |
|---|---|
| | កាលបរិច្ឆេទទទួល : |
| | លេខរបស់សំណុំលិខិតស្នើសុំ : |
| | កាលបរិច្ឆេទសុំចុះបញ្ជី : |

**ប្រអប់លេខ ១**

**ចំណងជើងនៃគំនូរឧស្សាហកម្ម** :..........................................................................................

..........................................................................................................................

**ប្រអប់លេខ ២**

**អ្នកដាក់ពាក្យសុំ(ទោះបីមិនមែនជាអ្នកបង្កើតស្នាដៃ/អ្នកគូរក៏ដោយ)** សូមប្រើប្រអប់នេះសម្រាប់បញ្ជាក់ប្រាប់ពីអ្នកដាក់ពាក្យសុំ ឬអ្នកណាម្នាក់ក៏បាន នៅក្នុងចំណោមអ្នកទាំងនោះ ប្រសិនបើអ្នកដាក់ពាក្យសុំមានគ្នាច្រើន ។ ប្រសិនបើមានគ្នាលើសពីមួយនាក់ (ឬអង្គភាពស្របច្បាប់លើសពីមួយឡើងទៅ) ដែលជាប់ពាក់ព័ន្ធសូមបន្តទៅប្រអប់បន្ថែម ។

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ/អ្នកគូរ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អសយដ្ឋាន :..........................................................................................

..........................................................................................................................

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់) :..........................................................................

លេខទូរសារ:.............................................. អសយដ្ឋានអ៊ីម៉ែល:..............................................

សញ្ជាតិ :.............................................. ប្រទេសស្នាក់នៅ:..............................................

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ/អ្នកគូរ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អសយដ្ឋាន :..........................................................................................

..........................................................................................................................

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់): ..........................................................................

លេខទូរសារ:.............................................. អសយដ្ឋានអ៊ីម៉ែល:..............................................

សញ្ជាតិ :.............................................. ប្រទេសស្នាក់នៅ: ..............................................

**ប្រអប់លេខ ៣**

**អ្នកបង្កើតស្នាដៃ/អ្នកគូរ** ត្រូវបំពេញក្នុងប្រអប់តូចដាច់ពីគ្នាទៅតាមបុគ្គលនីមួយៗ ។ ប្រសិនបើប្រអប់តូចទាំងពីរនោះពុំមានកន្លែងគ្រប់គ្រាន់ទេ សូមបន្តទៅ "ប្រអប់បន្ថែម" (បំពេញនៅទីនេះសម្រាប់បុគ្គលបន្ថែមម្នាក់ៗដូចគ្នា និងការបញ្ជាក់នៃសំណើទាំងនោះ ក្នុងប្រអប់តូចទាំងពីរខាងក្រោម) ឬប្រើ "សន្លឹកបន្ត"

បុគ្គលក្នុងប្រអប់នេះគឺជា ( គូសតែមួយប៉ុណ្ណោះ ) : ☐ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ/អ្នកគូរ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អាសយដ្ឋាន :..........

..........

ប្រសិនបើបុគ្គលដែលបានបញ្ជាក់ក្នុងប្រអប់តូចនេះគឺជាអ្នកដាក់ពាក្យសុំ ( ឬ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ/អ្នកគូរ ) ចូរបញ្ជាក់ផងដែរនូវ :

សញ្ជាតិ :.......... ប្រទេសស្នាក់នៅ:..........

បុគ្គលក្នុងប្រអប់នេះគឺជា ( គូសតែមួយប៉ុណ្ណោះ ) : ☐ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ/អ្នកគូរ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អាសយដ្ឋាន :..........

..........

ប្រសិនបើបុគ្គលដែលបានបញ្ជាក់ក្នុងប្រអប់តូចនេះគឺជាអ្នកដាក់ពាក្យសុំ ( ឬ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ/អ្នកគូរ ) ចូរបញ្ជាក់ផងដែរនូវ :

សញ្ជាតិ :.......... ប្រទេសស្នាក់នៅ:..........

**ប្រអប់លេខ ៤**

**ភ្នាក់ងារ (ប្រសិនបើមាន) ឬតំណាងរួម (ប្រសិនបើមាន) ៖ អាសយដ្ឋានសម្រាប់ជូនដំណឹង (ក្នុងករណីចាំបាច់) ៖**

អ្នកតំណាងរួមអាចត្រូវបានគេចាត់តាំងឡើងចំពោះតែក្នុងករណី ប្រសិនបើមានអ្នកដាក់ពាក្យសុំច្រើននាក់ និងប្រសិនបើពុំមានចាត់តាំងភ្នាក់ងារ : អ្នកតំណាងរួមត្រូវតែជាអ្នកណាម្នាក់នៃអ្នកដាក់ពាក្យសុំទាំងនោះ ។ បុគ្គលខាងក្រោមនេះ ( អាចរួមមានអង្គភាពស្របច្បាប់ណាមួយ ) ត្រូវបានចាត់តាំងជាភ្នាក់ងារ ឬ ជាតំណាងរួមដើម្បីអនុវត្ត ក្នុងនាមជាអ្នកដាក់ពាក្យសុំ ( ម្នាក់ ឬ ច្រើននាក់ ) នៅចំពោះមុខមន្ត្រីកាន់កាប់បញ្ជី ។

ឈ្មោះ និង អាសយដ្ឋានរួមទាំងលេខកូដប្រៃសណីយ៍របស់ភ្នាក់ងារ :..........

..........

លេខទូរស័ព្ទ ( រួមទាំងលេខកូដតំបន់ ):..........

លេខទូរសារ :.......... អាសយដ្ឋានអ៊ីម៉ែល:..........

**ប្រអប់លេខ ៥**

**គំនូសតាងនៃគំនូរឧស្សាហកម្ម ៖ រូបសំណាក**

សំណុំលិខិតនេះមានភ្ជាប់ដោយ

☐ គំនូសតាងចំនួនបួន(៤)ច្បាប់

☐ រូបសំណាកនៃគំនូរឧស្សាហកម្ម

☐ គំនូរបង្ហាញ ឬគំនូរព្រាងចំនួនបួន(៤)ច្បាប់

**ប្រអប់លេខ ៦**

**ផលិតផល**

ប្រភេទផលិតផលដែលប្រើប្រាស់ចំពោះគំនូរឧស្សាហកម្មមានដូចតទៅ :

..........

..................................................................................................................................................................................

..................................................................................................................................................................................

..................................................................................................................................................................................

..................................................................................................................................................................................

**ប្រអប់លេខ ៧**

**សេចក្តីអះអាងអំពីអាទិភាព (ប្រសិនបើមាន)** ។ សូមអះអាងអំពីអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេដូចតទៅ :

| ប្រទេស ឬការិយាល័យដែលបានដាក់សំណុំលិខិតស្នើសុំ : ( ប្រសិនបើសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវបញ្ជាក់អំពីឈ្មោះការិយាល័យ និង ឈ្មោះប្រទេសដែលសំណុំលិខិតស្នើសុំនោះបានដាក់) : | កាលបរិច្ឆេទសុំចុះបញ្ជី ( ថ្ងៃ,ខែ,ឆ្នាំ) | លេខសំណុំលិខិតស្នើសុំ | និមិត្តសញ្ញានៃចំណាត់ថ្នាក់អន្តរជាតិរបស់គំនូរឧស្សាហកម្ម |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |

លិខិតបញ្ជាក់អំពីសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ

☐ ត្រូវបានភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនេះ ☐ ត្រូវបានផ្តល់ជូនក្នុងរយៈពេលបី(៣) ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំ

**ប្រអប់លេខ ៨**

**ការត្រួតពិនិត្យឯកសារ(ត្រូវបំពេញដោយអ្នកដាក់ពាក្យសុំ)**

| សំណុំលិខិតស្នើសុំនេះរួមមាន : | សំណុំលិខិតស្នើសុំត្រូវមានឯកសារភ្ជាប់មកជាមួយដូចខាងក្រោម : |
|---|---|
| ១. ពាក្យសុំ ............................................ សន្លឹក | ១. ☐ លិខិតប្រគល់សិទ្ធិដោយឡែក / ចាត់តាំងភ្នាក់ងារតំណាង |
| ២. គំនូសបង្ហាញ ........................................ សន្លឹក | ២. ☐ លិខិតថតចម្លងនៃការប្រគល់សិទ្ធិទូទៅ |
| ៣. រូបថត/គំនូសតាង .................................... សន្លឹក | ៣. ☐ សេចក្តីថ្លែងបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ |
| ៤. រូបសំណាក........................................... សន្លឹក | ៤. ☐ សេចក្តីថ្លែងបញ្ជាក់អំពីការបង្ហាញឱ្យគេដឹងមួយចំនួនដែលមិនយកជាបានការ |
| | ៥. ☐ ឯកសារអាទិភាព ( សូមមើលប្រអប់លេខ ៧) |
| **សរុប:**.................................................. **សន្លឹក** | ៦. ☐ លិខិតបញ្ជាក់ថតចម្លងនៃសំណុំលិខិតស្នើសុំដំបូង |
| | ៧. ☐ សេចក្តីបកប្រែជាភាសាអង់គ្លេសនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ ដែលការអះអាងអាទិភាពត្រូវបានយកធ្វើជាមូលដ្ឋាន |
| គំនូរលេខ........................................នៃគំនូសបង្ហាញ ( ប្រសិនបើមាន) ត្រូវបានស្នើសុំភ្ជាប់ទៅនឹងខ្លឹមសារសង្ខេប ដើម្បីធ្វើការផ្សព្វផ្សាយ ។ | ៨. ☐ វិក័យបត្រនៃការបង់ប្រាក់ |
| | ៩. ☐ ឯកសារផ្សេងៗ ( សូមបញ្ជាក់) |

**ប្រអប់លេខ ៩**

**ការសុំពន្យារការបោះពុម្ពផ្សាយ**

តើអ្នកដាក់ពាក្យស្នើសុំពន្យារការចុះផ្សាយឬទេ? ☐ មាន ☐ គ្មានទេ

ប្រសិនបើមានរយៈពេលពន្យារគឺ :..........................................ខែ

**ប្រអប់លេខ ១០**

**ហត្ថលេខាអ្នកដាក់ពាក្យសុំ ឬភ្នាក់ងារ ព្រមទាំងត្រា ឈ្មោះ**

ហត្ថលេខា *.................................................................................................... ..............................................

(កាលបរិច្ឆេទ)

* ដាក់ឈ្មោះនៅក្រោមហត្ថលេខា

ប្រសិនបើពាក្យសុំនាពេលបច្ចុប្បន្នត្រូវបានចុះហត្ថលេខាដោយភ្នាក់ងារម្នាក់តំណាងឱ្យអ្នកដាក់ពាក្យសុំ នោះចាំបាច់ត្រូវមានលិខិតបញ្ជាក់ប្រគល់សិទ្ធិដោយឡែកមួយក្នុងការចាត់តាំងភ្នាក់ងារនោះ ដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ។ ប្រសិនបើមានដូចករណីនេះ សំណូមពរឱ្យប្រើលិខិតប្រគល់សិទ្ធិទូទៅមួយ (ដែលតំកល់ទុកនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម) លិខិតថតចម្លងនៃលិខិតប្រគល់សិទ្ធិត្រូវតែភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនេះ ។

**ត្រូវបំពេញដោយមន្ត្រីកាន់កាប់បញ្ជី**

១. កាលបរិច្ឆេទនៃការទទួលការកែតម្រូវ ឬកាលបរិច្ឆេទនៃការទទួលឯកសារដែលបានដាក់ក្រោយគេសម្រាប់ការបំពេញឱ្យគ្រប់គ្រាន់នូវសំណុំលិខិតស្នើសុំ :

២. កាលបរិច្ឆេទទទួលកម្រៃ :..........................................................................................................................................

ប្រអប់បន្ថែម ចូរប្រើប្រអប់នេះក្នុងករណីដូចតទៅ

(១) ប្រសិនបើមានគ្នាច្រើនជាងចំនួនបីនាក់ ត្រូវបានជាប់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំនិង / ឬអ្នកបង្កើតស្នាដៃ/អ្នកគូរ : ក្នុងករណីនេះចូរសរសេរប្រអប់បន្ថែមលេខ 3 និង បញ្ជាក់ឱ្យដឹងសម្រាប់បុគ្គលបន្ថែមម្នាក់ៗនូវប្រភេទពត៌មានដូចគ្នា ដូចដែលបានស្នើសុំឱ្យបំពេញនៅក្នុងប្រអប់លេខ ៣ ។

(២) ប្រសិនបើមានសំណុំលិខិតស្នើសុំអះអាងអាទិភាពលើសពីប្រាំឡើងទៅ : ក្នុងករណីនេះចូរបញ្ជាក់ក្នុងការបន្តរបស់ប្រអប់លេខ ៧ និងបញ្ជាក់បន្ថែមលើសំណុំលិខិតស្នើសុំដែលបានដាក់មុនគេនីមួយៗនោះនូវប្រភេទពត៌មានដូចគ្នា ដូចដែលបានតម្រូវឱ្យបំពេញនៅក្នុងប្រអប់លេខ ៧ ។

(៣) ប្រសិនបើនៅក្នុងប្រអប់ទាំងនោះគ្មានប្រអប់ទំនេរគ្រប់គ្រាន់សម្រាប់ផ្តល់ពត៌មាន ក្នុងករណីដូចនេះសូមសរសេរប្រអប់បន្តលេខ (ចូរសរសេរដាក់លេខនៃប្រអប់) ហើយសូមផ្តល់ពត៌មានក្នុងរបៀបដូចគ្នាដែលបានតម្រូវឱ្យបំពេញ ដោយយោងទៅតាមបញ្ហាដែលត្រូវអធិប្បាយនៅក្នុងប្រអប់ដែលពុំមានកន្លែងគ្រប់គ្រាន់នោះ ។